ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ការសម្លាប់ឡោណរបស់តាម៉ុក
- ប្រព័ន្ធសន្តិសុខខ្មែរក្រហម

លេខ៨ ខែសីហា ឆ្នាំ២០០០

# ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ៨ ខែសីហា ឆ្នាំ២០០០


## មាតិកា


-សំបុត្រៈ ម៉ុក........................................................ ១

**ផ្នែកឯកសារ**

-ទឹម សេន និងសកម្មភាពនៅតំបន់២៥..............................២

-ទំនាស់វណ្ណៈ និងការតស៊ូវណ្ណៈ.................................................៥

-ខ្ញុំចង់បានតែការពិត.........................................................៦

-រណ្តៅសាកសពប្រល័យពូជសាសន៍...................................១០

-អំពីលក្ខន្តិកៈបក្សកុម្មុយនិស្តកម្ពុជា...................................១៣

-បញ្ជីឈ្មោះមន្ត្រី និងបុគ្គលិកស្ថានទូតកម្ពុជានៅបរទេស........... ១៦

-ប្រវត្តិរូបបដិវត្តន៍សមមិត្ត គង់.........................................១៨

**ផ្នែកប្រវត្តិសាស្ត្រ**

-សោកនាដកម្មនៅភូមិកោះផល.............................................២២

-សម្ភេទពីមន្ទីរស-២១..................................................២៦

**ផ្នែកច្បាប់**

-គំរូមួយនៃភ័ស្តុតាងឯកសារ...........................................៣២

-វិធីបួនយ៉ាងក្នុងការវិនិច្ឆ័យអំពើទារុណកម្ម...........................៣៦

-រឿងក្តីរវាងអ៊ីស្រាអែល និងអេច្មក្មាន់............................ ៣៨

**វេទិកាពិភាក្សាជាសាធារណៈ**

-ការជំនុំជម្រះក្តីខ្មែរក្រហម...........................................៤១

-កេរដំណែល.................................................................៤២

-តើការលើកលែងទោសគឺជាតម្លៃនៃសន្តិភាព? ....................៤៦

-ស្នាដៃតាម៉ុក...............................................................៤៨

-ការទាមទារប្រវត្តិសាស្ត្រកម្ពុជាមកវិញ.............................. ៥១

**ទំព័រស្រាវជ្រាវរកគ្រួសារ**

-ការសម្លាប់រង្គាលនៅបឹងទន្លេសាប.................................. ៥៦

-មិនអាចបំភ្លេចបាន.......................................................៦០

**សិល្បៈខ្មែរក្រហម**

-**កំណាព្យខ្មែរក្រហមៈ** ទិដ្ឋភាពថ្មីនៃជនបទកម្ពុជា..............ក្របក្រោ




អតីតផ្ទះតាម៉ុកនៅទីរួមខេត្តតាកែវ



កងទ័ពខ្មែរក្រហម


# រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា



អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងពត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពត៌មាន
លេខ ០២៩១ពម៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**វាគ្មិនលេខនេះៈ** ចាយ៉ា វ៉ាមជី, ដេវីត ឆេនដល័រ, ស៊ីវ ហេឌ័រ, ហិនរី ឃីសស៊ីងជឺរ, យិមស៊ុត វ៉ាណាជិត, យ៉ន វ៉ាន់ គ្រីនធីន, គ្រេក អេចឆេសាន់, អេលីហ្សាប៊ែត វ៉ាន់ ស្កាក់, ភីតធើ ម៉ាឃៀរ **អ្នកនិពន្ធនិងស្រាវជ្រាវៈ** សាន់ កល្យាណ, លី សុផល, ជួង សុភារិទ្ធ **ជំនួយការនិពន្ធនាយកៈ** អែម សុខឃីម **និពន្ធនាយករងទី១ៈ** ផាត កុសល **និពន្ធនាយករងទី២ៈ** សឹម សុរិយ៉ា **អ្នកបកប្រែៈ** សួ ប៊ុនស៊ូ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ, **គ្រប់គ្រងការចែកផ្សាយៈ** ទ្រី សុភក្តិ

*សំបុត្រ:*

# ម៉ុក

នៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៩៩ កងកម្លាំងប្រដាប់អាវុធរបស់រាជរដ្ឋាភិបាលកម្ពុជាបានចាប់ខ្លួន តាម៉ុក ហើយដាក់គុកមកទល់សព្វថ្ងៃនេះ ។ ឥឡូវនេះ តាម៉ុក កំពុងរង់ចាំតុលាការឯករាជ្យមួយដើម្បីធ្វើការវិនិច្ឆ័យទោស និងដាក់ទណ្ឌកម្មទៅតាមច្បាប់ជាធរមានពីបទឧក្រិដ្ឋដែលខ្លួនបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យរវាងឆ្នាំ១៩៧៥-១៩៧៩ ។

មុនពេលចាប់ខ្លួន តាម៉ុកធ្លាប់បាននិយាយថា នៅពីលើ ម៉ុក គឺមានតែមេឃដោយមិនបានគិតដល់ថាច្បាប់អាចនៅពីលើមេឃរបស់គាត់ ។ តាម៉ុក ក៏បានភ្លេចឈ្ងោកមុខចុះក្រោមហើយសញ្ជឹងគិតថា នៅក្រោមបាតជើងខ្លួនគឺមានសុទ្ធតែរណ្តៅសាកសពមនុស្សរាប់សែននាក់ដែលបានស្លាប់ក្រោមស្នាដៃនិងខួរក្បាលរបស់ខ្លួន ។ សាច់ឈាមញាតិមិត្តនៃសាកសពទាំងនោះកំពុងរស់នៅហើយរង់ចាំមើលថាតើច្បាប់នឹងដោះស្រាយអំពើរបស់ តាម៉ុក នេះ តាមរបៀបណា? យាយពូន ដែលត្រូវជាប្អូនស្រីបង្កើតរបស់ តាម៉ុក ហើយដែលបានមកសួរសុខទុក្ខ តាម៉ុក (ដោយឈរមើលពីចម្ងាយ) ជាមួយនឹងក្មួយប្រសា កាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០០ កន្លងមកនេះ ក៏កំពុងរង់ចាំមើលពីការពិតដែរ ។ យាយពូន ពុំបានជឿថា តាម៉ុក ដែលជាមនុស្សម្នាក់ធ្លាប់បួសរៀននៅវត្ត អាចលើកដៃសម្លាប់មនុស្សបានទេ ។ ប៉ុន្តែយ៉ាងហោចណាស់មានឯកសារចំនួន៣ដែលអ្នកស្រាវជ្រាវផ្នែកច្បាប់យល់ថា មានការពាក់ព័ន្ធដល់អំពើឧក្រិដ្ឋដែល តាម៉ុក បានប្រព្រឹត្ត ។ ប្រសិនបើរាប់បញ្ចូលទាំងចម្លើយសាក្សី និងវត្ថុតាងជាក់ស្តែងជាច្រើនទៀត ប្រហែលជាអាចបង្ហាញឲ្យឃើញពីការពិតដុតពីភាពមន្ទិលសង្ស័យបានថា តាម៉ុក ជាជនដែលដល់ដែលឥតប្រកែកបាន ។

ទោះបីជាយ៉ាងនេះក៏ដោយ ការដាក់គុក តាម៉ុក ដែលអូសបន្លាយពេលវេលាដ៏យូរអង្វែងបែបនេះបានធ្វើឲ្យមានការចោទជាសំណួរថាតើនរណាជាអ្នកទទួលខុសត្រូវចំពោះសុខមាលភាពនិងអាយុជីវិតរបស់តាម៉ុក?

តាម៉ុក ជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនិស្តកម្ពុជាក្នុងឆ្នាំ១៩៧១ ហើយធ្លាប់ជាលេខាភូមិភាគនិរតីនៅឆ្នាំ១៩៦៨ ។ នៅខែវិច្ឆិកា ឆ្នាំ១៩៧៨ តាម៉ុក ត្រូវបានចាត់តាំងជាអនុលេខាបក្សកុម្មុយនិស្តកម្ពុជា ។ **ឆាំង យុ**



© រូបថតឯកសារ Peter H. Maguire

# ទឹម សេន និងសកម្មភាពនៅតំបន់ ២៥

តំបន់២៥ ដែលរួមមានស្រុកលើកដែក ស្រុកស្អាង និង ស្រុកកោះធំ ខេត្តកណ្តាល ស្ថិតនៅក្នុងភូមិភាគនិរតី ហើយស្ថិត ក្រោមការទទួលខុសត្រូវរបស់តាម៉ុក ។ ខាងក្រោមនេះជា សេចក្តីសង្ខេបដកស្រង់ឯកសារលេខ ៤៤០បបគខ មានចំនួន ១២សន្លឹក ជាចម្លើយសារភាពរបស់អ្នកទោសគុកទួលស្លែងម្នាក់ ឈ្មោះ ទឹម សេន ហៅ ស៊ិត អតីតលេខាស្រុកកោះធំ តំបន់ ២៥ ភូមិភាគនិរតី ។

ទឹម សេន បានសារភាពថាខ្លួនឈ្មោះ ទឹម សេន ហៅ ស៊ិត អាយុ៤៤ឆ្នាំ(១៩៧៧) កើតនៅភូមិត្រពាំងលើ ឃុំពាមរាំង ស្រុក១៤ តំបន់២៥ ធ្លាប់បានចូលបក្សពលករវៀតណាមនៅ ឆ្នាំ១៩៦៥ ជាមួយសកម្មភាពឃោសនាប្រជាជនឲ្យឧបត្ថម្ភគាំទ្រ វៀតណាមកសាងកម្លាំងឲ្យចូលទ័ពវៀតណាម ។ ឆ្នាំ១៩៧២ ទឹម សេន បានបំផុសប្រជាជនឲ្យធ្វើបាតុកម្មប្រឆាំងអ្នកដឹកនាំ បដិវត្តន៍ ហើយចាប់បាតុករសម្លាប់ចោលអស់ជាច្រើននាក់ ។ ក្រោយរំដោះឆ្នាំ១៩៧៥ ទឹម សេន ឡើងជាលេខាស្រុក១៨ តំបន់២៥ ហើយបានបង្កភាពច្របូកច្របល់ក្នុងសហករណ៍បំផ្លាញ សម្ភារ បង្ខំមនុស្សឲ្យធ្វើការហួសកម្លាំងរហូតដល់ឈឺជាបន្តបន្ទាប់ ធ្វើសកម្មភាពប្រឆាំងនឹងផែនការបដិវត្តន៍ដែលដាក់ចុះរហូតដល់ ថ្ងៃទី១ ខែមីនា ឆ្នាំ១៩៧៧ ត្រូវអង្គការចាប់ខ្លួន ។

សកម្មភាពពិស្តាររបស់ ទឹម សេន ហៅ ស៊ិត នៅក្នុងចម្លើយ សារភាពនេះមានដូចតទៅ÷

កាលពីកុមារភាព ទឹម សេន រៀននៅសាលាពាមរាំង ស្រុកលើកដែក ខេត្តកណ្តាល ។ ឆ្នាំ១៩៥៥-៥៧ គាត់មក ធ្វើជាកម្មករលីបាវស៊ីម៉ង់ត៍នៅកំពង់ផែមុខវត្តភ្នំ (ភ្នំពេញ) ។ ឆ្នាំ១៩៥៧ ត្រឡប់ទៅធ្វើស្រែចម្ការជាមួយឪពុកម្តាយនៅឯ ស្រុកកំណើតវិញ ។

ឆ្នាំ១៩៦៨ ទឹម សេន ត្រូវបានបងថ្លៃឈ្មោះ ទូន ផន ណែនាំគាត់ឲ្យជួយឃោសនាប្រជាជន ឲ្យប្រជាជនជួយឧបត្ថម្ភ កងទ័ពវៀតណាមជាស្បៀងនិងជាសម្ភារ ដោយ ទូន ផន បង្ហាញ ឲ្យឃើញថា វៀតណាមមកជួយវាយខ្មាំងនៅកម្ពុជា ។ ទឹម សេន បានធ្វើតាមការណែនាំនេះជាបន្តបន្ទាប់ ។ ក្រោយមក ទូន ផន ក៏ បញ្ចូល ទឹម សេន ជាសមាជិកបក្សពលករវៀតណាមដោយមាន ឈ្មោះ ឈុន គ្រី ហៅ ខៀវ សំអាត គណៈស្រុក១៨ តំបន់២៥ ជាអ្នកខទ្សេនាមចូល ។ ភារកិច្ចរបស់ ទឹម សេន ក្រោយពេល



ក្លាយជាសមាជិកបក្សពលករវៀតណាមគឺ ៈ

១) ឃោសនាឲ្យប្រជាជនជឿនិងឧបត្ថម្ភវៀតណាម និង

២) កសាងកម្លាំងប្រជាជនឲ្យចូលបម្រើកងទ័ពវៀតណាម ។

នៅខែ៣ ឆ្នាំ១៩៧០ ឈ្មោះ ស៊ិន សាឌី គណៈស្រុក លើកដែក តំបន់២៥ បានចាត់តាំង ទឹម សេន ជាសមាជិក ឃុំពាមរាំង ចំណែក ទូន ផន ត្រូវបានចាត់តាំងជាលេខាឃុំ ។ ប្រហែល២ខែក្រោយ ទូន ផន ត្រូវពួកធីវគីចាប់យកទៅសម្លាប់ បាត់ទៅ ។ ពេលនោះ ទឹម សេន ក៏ត្រូវបានចាត់តាំងជាប្រធាន សន្តិសុខស្រុកលើកដែកដោយមាន វ៉ុង ភន ជាអនុប្រធាន

ជាម អេង និង អ៊ុយ គីម ជាសមាជិក ។ តាមរយៈការចាត់តាំងនេះ ស៊ិន សាឌី ណែនាំឲ្យអ្នកទាំងបួនធ្វើសកម្មភាពបំផុសឲ្យប្រជាជនលក់គោ លក់ជ្រូក ទៅស្រុកយួនឲ្យអស់ដោយយកលេសថាបើទុកខ្មាំងវាចុះមក វាចាប់ វាកៀរយកទៅអស់ហើយ ។

ចុងឆ្នាំ១៩៧០ ស៊ិន សាឌី បានហៅ ទឹម សេន ជុំ សារ៉េត និង អ៊ិក នួន មកប្រជុំប្រាប់ថា ស្រុកលើកដែក ត្រូវប្រគល់អាវុធ និងកម្លាំងយោធាទាំងអស់ឲ្យខាងតំបន់២៥ ។ ទន្ទឹមនឹងនេះដាក់ផែនការឲ្យ ជុំ សារ៉េត ត្រូវរៀបចំកងឈ្លបចាំកម្ទេចកម្មាភិបាល



តំបន់២៥ នៅពេលដែលបក្ខពួក ទឹម សេន ចូលមកទទួលអាវុធ និងកម្លាំងយោធា ប៉ុន្តែផែនការនេះមិនបានសម្រេចទេព្រោះកាលណោះកម្មាភិបាលខាងតំបន់២៥មិនបានទៅទទួលយកអាវុធ និងកម្លាំងយោធាពីខាងស្រុកលើកដែកឡើយ ។

ឆ្នាំ១៩៧១ដោយឮថាមានអង្គការខ្មែរនៅខាងស្រុក១៨ តំបន់២៥ ទឹម សេន និងបក្ខពួកមួយចំនួនទៀតមានឈ្មោះ ម៉ៅ ឌុក សមាជិកសន្តិសុខស្រុកលើកដែក ជាម អេង និង ឡាយ សារីម បាននាំគ្នាចូលទៅទាក់ទងសុំ សុខ ប៊ុតចំរើន គណៈតំបន់២៥ ដើម្បីមកធ្វើការនៅខាងតំបន់ ២៥វិញ ។ កន្លះខែក្រោយមក សុខ ប៊ុតចំរើន បានចាត់តាំង ទឹម សេន ជាប្រធានសន្តិសុខស្រុកលើកដែកដដែល និងឲ្យ ម៉ៅ ឌុក ធ្វើជាអនុប្រធាន ។ មួយរយៈខ្លីក្រោយមកទៀត សុខ ប៊ុតចំរើន បានបើកអង្គប្រជុំមួយដែលមានគ្នា៧នាក់មាន សុខ ប៊ុតចំរើន ជាប្រធានអង្គប្រជុំ សុក បញ្ជាការតំបន់២៥ ហួត សេ ប្រធានសន្តិសុខតំបន់២៥ ឡាយ សារីម គណៈឃុំកំពង់ភ្នំស្រុកលើកដែក ម៉ៅ ឌុក ជាម អេង និង ទឹម សេន ។ ខ្លឹមសារប្រជុំគឺបំផុសប្រជាជនកុំឲ្យជឿអង្គការនិងកសាងកម្លាំងបន្ថែមទៀត ។

ឆ្នាំ១៩៧២ តាជ័យ លេខាតំបន់២៥ បានចាត់តាំង ទឹម សេន មកកាន់ខាងកងទ័ព មាននាទីជាលេខាវរសេនាតូចលេខ១១២ របស់តំបន់២៥ ។ ខែ៤ ឆ្នាំ១៩៧២ តាជ័យនិង ហួត សេ បានបញ្ចូល ទឹម សេន និង លាត (អនុបញ្ជាការវរសេនាតូចលេខ១១២) ទៅក្នុងបក្សកុម្មុយនិស្តកម្ពុជា ។ ព្រមជាមួយនេះ តាជ័យ បានណែនាំអ្នកទាំងពីរឲ្យខំកសាងកម្លាំង និងបំផ្លាញបដិវត្តន៍នៅលើសមរភូមិ ។ បន្ទាប់មកមានផែនការវាយខ្មាំងនៅបារ៉ែន ទឹម សេន និងបក្ខពួកបានធ្វើការបំផ្លាញកម្លាំងបដិវត្តន៍ដោយជំរុញឲ្យយុទ្ធជនវាយខ្មាំងទាំងយប់ទាំងថ្ងៃបណ្តាលឲ្យស្លាប់ ១០នាក់ និងរបួស ២៥នាក់ ។

រយៈកាលជាបន្តបន្ទាប់ ទឹម សេន កសាងបានកម្លាំងជាច្រើននាក់ដោយវិធីបបួលទៅហូបបាយទឹក នំចំណីនិងឲ្យសម្ភារប្រើប្រាស់ជាញឹកញាប់ ។

ក្នុងឆ្នាំ១៩៧២ ដដែលនេះ សុក គណៈបញ្ជាការកងទ័ពតំបន់២៥ បានចាត់តាំង ទឹម សេន និងម្នាក់ទៀតឈ្មោះ លាត ឲ្យដើរបំផុសប្រជាជននៅឃុំត្រើយស្លា និងឃុំតាលន់ បានចំនួន ៥០នាក់ធ្វើបាតុកម្មប្រឆាំងនឹងអ្នកដឹកនាំតាមភូមិឃុំក្នុងស្រុកស្អាងតំបន់២៥ ។ ក្បួនបាតុកម្មនេះហែពីផ្សារព្រែកឃ្មោកទៅចូលមន្ទីរតំបន់២៥ នៅភូមិត្នោតញី ឃុំខ្ពប ស្រុក២០ តំបន់២៥ ដោយមានឈ្មោះ លាត ជាអ្នកដឹកនាំ ។ ចំណែក ទឹម សេន ទទួលបញ្ជាឲ្យធ្វើជាអ្នកចាំទប់ទល់ចលនាបាតុកម្មនេះ ហើយចាប់ពួកបាតុករយកទៅសម្លាប់ចោល ។ ពេលនោះកម្លាំងមូលដ្ឋានចាប់ពួកបាតុករបានទាំងអស់ ហើយយកទៅសម្លាប់ចោលអស់១០នាក់ នៅសល់៤០នាក់ទៀតដោះលែងទៅវិញ ។ ក្នុងឯកសារចម្លើយ

សារភាព ទឹម សេន បានសរសេរថា «...ខ្ញុំក៏បានធ្វើតាមផែនការនេះ កាលនោះក៏បានបញ្ជាឲ្យកងទ័ពចាប់ពួកបាតុករនោះបានទាំងអស់ (៥០នាក់) ហើយបានយកទៅសម្លាប់ចោលអស់ ១០នាក់ ។ ៤០នាក់ទៀតក៏ដោះលែងទៅវិញ» ។

ចុងឆ្នាំ១៩៧៣ តាជ័យ ចាត់តាំង ទឹម សេន ឲ្យធ្វើជាជាសមាជិកស្រុក១៨ តំបន់២៥ ហើយឲ្យទាក់ទងការងារក្បត់ជាបន្តជាមួយឈ្មោះ កាត បញ្ជាការកងឈ្លបស្រុក១៨ តំបន់២៥ ឈ្មោះ សៀង លី បញ្ជាការវរសេនាតូច២៦០ តំបន់២៥ និងឈ្មោះ វៀល លិញ គណៈទាក់ទងខ្មែរ-វៀតណាម ។

ឆ្នាំ១៩៧៤ វាយខ្មាំងនៅបន្ទាយជ្រៃធំ ជិតព្រំដែនវៀតណាមខាងត្បូង ទឹម សេន បានសារភាពថា ខ្លួនគាត់និងបក្ខពួកទាំងពីរនាក់បានធ្វើឲ្យប៉ះពាល់ដល់កម្លាំងបដិវត្តន៍ជាច្រើន ។ ពេលវាយខ្មាំងបាក់ស្មារតីហើយ ទឹម សេន ក៏បញ្ជាឲ្យទាហានឈប់បាញ់ ។ ខ្មាំងក្តាប់បានសភាពការណ៍នេះក៏បាញ់សង្កត់មកវិញយ៉ាងខ្លាំង ឃើញដូច្នេះ ទឹម សេន បញ្ជាឲ្យទាហានដកទ័ពរត់បណ្តាលឲ្យត្រូវគ្រាប់ស្លាប់ ១៥នាក់ និងរបួស ២០នាក់ ។ បន្ទាប់មកអ្នកទាំងបីបានបំផុស និងបើកផ្លូវឲ្យប្រជាជននៅឃុំសំពៅពូន និងឃុំឈើខ្មៅរត់ទៅតំបន់ខ្មាំង អស់ប្រហែល១០០គ្រួសារ ។ ក្រោយមកទៀត ដោយមិនទប់ទល់និងមិនវាយប្រយុទ្ធ បក្ខពួក ទឹម សេន បានបណ្តោយឲ្យខ្មាំងចូលមកកៀរយកប្រជាជននៅឃុំសំពៅពូនទៅអស់រាប់រយគ្រួសារទៀត ។

ខែ២ ឆ្នាំ១៩៧៥ ទឹម សេន ត្រូវបាន តាជ័យ ចាត់តាំងឲ្យធ្វើជាលេខាស្រុក១៨ តំបន់២៥ ។

ឆ្នាំ១៩៧៥ ក្រោយខ្មែរក្រហមរំដោះបានហើយអង្គការមានផែនការឲ្យរៀបចំសហករណ៍ឲ្យបានស្អាតដោយជ្រើសរើសវណ្ណភាព ។ ទឹម សេន សារភាពទៀតថា «តែផ្ទុយទៅវិញ ខ្ញុំ (ស៊ិត) បានធ្វើឲ្យច្របូកច្របល់ក្នុងសហករណ៍ ដោយចាត់តាំងសមាសភាពចម្រុះនៅក្នុងសហករណ៍ ធ្វើឲ្យមានទំនាស់គ្នាជាបន្តបន្ទាប់ពីរឿងកម្មសិទ្ធិពីរឿងធ្វើការងារពលកម្ម» ។

ប្រហែលខែ៥ ឬខែ៦ ឆ្នាំ១៩៧៦ ទឹម សេន បានមកទាក់ទង តាជ័យ នៅឃ្លាំងប្រាក់ក្រោយវត្តភ្នំដើម្បីស្នើរកសម្ភារយកទៅប្រើប្រាស់ក្នុងស្រុក ។ តាជ័យ ក៏ណែនាំឲ្យអនុវត្តតាមទិសដៅដូចតទៅ÷

១) ត្រូវរៀបចំវណ្ណភាពចម្រុះនៅក្នុងសហករណ៍ដើម្បីឲ្យមានការច្របូកច្របល់និងមានទំនាស់ស្មុគស្មាញ ។

២) បំផ្លាញសេដ្ឋកិច្ចនិងទ្រព្យសម្បត្តិរបស់សមូហភាព ។

៣) បំផ្លាញកម្លាំងបដិវត្តន៍គ្រប់ផ្នែក ។

ខែ៧ និងខែ៨ ឆ្នាំ១៩៧៦ ទឹម សេន បានចាត់តាំងកម្លាំងនៅក្នុងសហករណ៍ឲ្យទប់ព្រែកនៅឃុំព្រែកស្តី ស្រុក១៨ តំបន់២៥ ដើម្បីយកផលពោតនៅក្នុងឃុំព្រែកស្តី និងឃុំព្រែកថ្មី រួមប្រហែល ៦០ហិកតា ។ ផ្ទុយទៅវិញ ទំនប់ក៏ត្រូវធ្លាយទឹកក៏ទៅលិចពោតអស់ (ពោតទាំងនោះទើបនឹងទុំបានប្រហែល៥០%) ហើយថែមទាំងលិចស្រូវពង្រោះកន្លែងនោះអស់១០០ហិកតាទៀត ។

សកម្មភាពមួយទៀត ទឹម សេន បានអនុវត្តបំភ្លៃមាគ៌ារបស់អង្គការដោយជំរុញឲ្យយុវជន-យុវនារីធ្វើការងារខ្លាំងមិនឲ្យសម្រាករហូតដល់បាក់កម្លាំងឈឺជាបន្តបន្ទាប់ ។ មិនតែប៉ុណ្ណោះ ទឹម សេន នៅបានចាត់តាំងឈ្មោះ បេ ឲ្យធ្វើសកម្មភាពបំផុសយុវជនក្នុងកងផលិតកម្មស្រុក១៨ តំបន់២៥ ឲ្យរត់ទៅផ្ទះជាបន្តបន្ទាប់ដើម្បីធ្វើឲ្យមានបញ្ហាស្មុគស្មាញពិបាកដោះស្រាយ ។

នៅខែ៣ ឆ្នាំ១៩៧៧ ទឹម សេន ហៅ ស៊ិត ត្រូវអង្គការចាប់ខ្លួនបញ្ជូនមកគុកទួលស្លែង ។

នៅក្នុងគុកទួលស្លែងក្រោមការគ្រប់គ្រងរបស់ ឌុច, ទឹម សេន ត្រូវបានសួរចម្លើយនៅថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៧៧ ដោយអ្នកសួរឈ្មោះ ថន ។ ឯកសារចម្លើយសារភាពនេះត្រូវបានបញ្ជូនទៅ តាម៉ុក ជាលេខាភូមិភាគនិរតី ។ ចំណារជាអក្សរដៃដែលសរសេរធំៗនៅលើផ្នែកខាងមុខនៃឯកសារដាក់ថា «និរតីជូនតាម៉ុកហើយ ១២-១១-៧៧» ។

នៅផ្នែកបញ្ចប់នៃឯកសារចម្លើយឃើញមានតារាងឈ្មោះកម្លាំងក្បត់ដែលដកស្រង់ចេញពីចម្លើយសារភាពរបស់ ទឹម សេន ចំនួន២៣នាក់ក្នុងនោះ១០នាក់មានបញ្ជាក់ថា «អង្គការចាប់ហើយ» ដែលមានមនុស្សសំខាន់ៗមួយចំនួនក្នុងតំបន់២៥ដូចជា ស៊ិន សាឌី សុខ ប៊ិតចំរើន ហួត សេ ជ័យ...។ ដោយឡែក ស៊ិន សាឌី ត្រូវបានអង្គការចាប់ខ្លួនតាំងពីឆ្នាំ១៩៧៦ម្ល៉េះ ។

**សាន់ កល្យាណ**

# ទំនាស់វណ្ណៈ និងការតស៊ូវណ្ណៈ

## I. ទំនាស់វណ្ណៈ

### ១) អំពីវណ្ណៈ

នៅក្នុងសង្គមកម្ពុជា «កម្ពុជាប្រជាធិបតេយ្យ» មានវណ្ណៈ៥ គឺវណ្ណៈសក្តិភូមិ វណ្ណៈនាយទុន វណ្ណៈអនុធន វណ្ណៈកសិករ និង វណ្ណៈកម្មករ ។ ដើម្បីវិនិច្ឆ័យអំពីវណ្ណៈបានយើងត្រូវមើលអំពីមធ្យោបាយផលិតកម្ម ។ វណ្ណៈសក្តិភូមិគឺវាគ្មានពលកម្មឬគិតគូរអ្វីទាំងអស់ គឺវាចាំតែដើរទារពន្ធគ្រប់បែបយ៉ាង ។ រីឯវណ្ណៈនាយទុន វាគិតតែទិញថោកលក់ថ្លៃប៉ុណ្ណោះ ។ ផ្ទុយទៅវិញ មានតែវណ្ណៈកសិករ-កម្មករទេដែលខិតខំបំពេញការងារ ។ កម្មករចែកជា២ប្រភេទគឺ កម្មករចាស់ និងកម្មករថ្មី ។ កម្មករចាស់គឺធ្វើការឲ្យនាយទុន ចំណែកកម្មករថ្មីគឺធ្វើការឲ្យរោងចក្រដែលបក្សយើងជ្រើសយកក្រោយថ្ងៃ១៧ មេសា មកធ្វើការជូនសមូហភាព ។ កសិករមាន២ប្រភេទដែរគឺ កសិករចាស់ និងកសិករថ្មី ។ កសិករចាស់គឺកាប់គាស់ដីស្រែដោះស្រាយជីវភាពដោយខ្លួនឯង ។ កសិករថ្មីគឺពួកនាយទុននិងអនុធនដែលបក្សយើងជម្លៀសចេញពីក្រុងយកមកឲ្យធ្វើការងារពលកម្ម មានការដឹកនាំ និងធ្វើការជូនសមូហភាព ។

### ២) ទំនាស់វណ្ណៈ

ទំនាស់វណ្ណៈមានពីរគឺ ទំនាស់វណ្ណៈផ្ទៃក្នុង និងទំនាស់វណ្ណៈមកពីក្រៅ ។

#### ក) ទំនាស់វណ្ណៈផ្ទៃក្នុង

គឺជាទំនាស់រវាងកសិករ-កម្មករយើងនឹងពួកសក្តិភូមិនាយទុន ។ រាល់មធ្យោបាយផលិតកម្មទាំងអស់ដូចជារោងចក្រសុទ្ធតែធ្លាក់ក្នុងកណ្តាប់ដៃកសិករ-កម្មករយើង ដូច្នេះពួកវាមិនសប្បាយចិត្តនឹងយើងទេរហូតដល់មានទំនាស់ជាបដិបក្ខស្លាប់រស់នឹងយើង ។ ពេលយើងចាត់តាំងពួកវាឲ្យមើលគោ វាកាប់ជើងគោឬចងគោបន្ទត់ស្មៅ ប៉ុន្តែក៏មានសមាសភាពខ្លះពុំមែនទំនាស់បដិបក្ខនឹងយើងដែរព្រោះវាក៏ពេញចិត្តនឹងបដិវត្តន៍យើងដែរ ។ ពួកនេះពូកែតែខាងសរសេរកត់ត្រា តែបើខាងកាប់គាស់ពួកវាមិនប្រសប់ដូចយើងទេ ។ ពួកនាយទុនអនុធនខ្លះស្នេហាជាតិពិតប្រាកដ ជួយដោះស្រាយជីវភាពជូនប្រជាជន ប៉ុន្តែបើមិនស្នេហាជាតិពិតប្រាកដទេគឺក្បត់ជាតិពិតប្រាកដ ។

#### ខ) ទំនាស់ពីខាងក្រៅ

យើងត្រូវបែងចែកឲ្យច្បាស់រវាងមិត្តនិងសត្រូវ ។ ប្រទេសណាដែលប្រឆាំងនឹងយើងមិនអាចសម្រុះសម្រួលបាន ដូចជាប្រទេសជិតខាងយើងនោះគឺជាទំនាស់បដិបក្ខដែលយើងត្រូវវ៉ៃ គឺមិនអាចឲ្យវាយកដីយើងបានទេ ។

## II. ការតស៊ូវណ្ណៈ

ទំនាស់រវាងវណ្ណៈអធននិងវណ្ណៈសក្តិភូមិនាយទុនគឺមានលក្ខណៈស្លាប់រស់ ព្រោះវណ្ណៈអធនវិវត្តទៅរកកម្មសិទ្ធិសមូហភាព ចំណែកកម្មសិទ្ធិឯកជនគឺវិវត្តទៅរកវណ្ណៈសក្តិភូមិនាយទុន ។ វណ្ណៈអធនគិតគូរដល់ប្រយោជន៍សមូហភាព ផ្ទុយទៅវិញវណ្ណៈសក្តិភូមិគឺគិតគូរតែប្រយោជន៍ឯកជនប៉ុណ្ណោះ ។ ពួកវាគិតតែពីប្រយោជន៍បុគ្គលនិងគ្រួសារ ទាំងសម្ភារគឺចង់មានបានគ្រប់គ្រាន់តែខ្លួនឯង កេងប្រវ័ញ្ចគេឯង និងខាងជំហរសតិអារម្មណ៍ចង់បានមុខមាត់ បុណ្យសក្តិ តួនាទី មុខតំណែង ដើម្បីគ្រួសារនិងផ្ទាល់ខ្លួន ។

ដើម្បីវ៉ៃពួកវាឲ្យបរាជ័យងើបលែងរួច សហករណ៍យើងត្រូវតែប្រឹងប្រែងកុំធ្វេសប្រហែសក្នុងការតស៊ូវណ្ណៈយូរអង្វែងតឹងតែង និងស៊ិតស្វាញជានិច្ច ឧទាហរណ៍យើងឃើញខ្មាំងធ្វើសកម្មភាព ប៉ុន្តែយើងមិនថាអី ។ ដូចជាយើងឃើញខ្មាំងដឹកទឹកត្នោតហើយជុះអាចម៍ដាក់បំពង់ យើងបែរជាចាត់ទុកវាខិលខូចណាស់ដោយមិនថាវាខ្មាំង នេះគឺជាការខុសឆ្គងហើយ ។ យើងត្រូវតែវិភាគឲ្យបានគ្រប់ជ្រុងជ្រោយចំពោះសកម្មភាពដែលយើងអាចគិតគូរ កុំទុកបណ្តោយឲ្យខ្មាំងធ្វើសកម្មភាពប្រឆាំងនឹងយើងបាន ។ *(ដកស្រង់ដោយ អៀ ម៉េងទ្រី ពីសៀវភៅសិក្សានយោបាយថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៧ របស់សមមិត្តឃិន សូផន យោធាភូមិភាគបូព៌ា ២០៣)*

សូមសរសេរលិខិត
ឬអត្ថបទពិភាក្សាជុំវិញបញ្ហាខ្មែរក្រហមផ្ញើមក
**ទស្សនាវដ្តី «ស្វែងរកការពិត»**
ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ឬតាមទូរសារលេខៈ (៨៥៥) (២៣) ២១០៣៥៨
ឬ Email: dccam@bigpond.com.kh

លោកយាយ អ៊ុង ពូន បាននិយាយថា «ខ្ញុំចង់បានតែការពិតនៅក្នុងរឿងរបស់តាម៉ុក» ។ លោកយាយ ពូន សម្តែងនូវការមិនសប្បាយចិត្តនៅពេលដែលខ្ញុំសួរអំពីរឿងរបស់តាម៉ុក ។ ចំណែកប្រជាជនដទៃទៀតនៅក្នុងភូមិត្រពាំងធំចង់ដឹងចង់ឮយ៉ាងខ្លាំងនៅពេលដែលឮថា តុលាការឯករាជ្យមួយនឹងត្រូវបង្កើតនៅពេលខាងមុខនេះដើម្បីកាត់ទោសតាម៉ុកនិងមេដឹកនាំខ្មែរក្រហមដទៃទៀត ។



យាយ ពូន (ប្អូនស្រីតាម៉ុក)

# "ខ្ញុំចង់បានតែការពិត"

ខ្ញុំបានទៅដល់ភូមិត្រពាំងគល់ជាភូមិចាស់ដែលឪពុកម្តាយរបស់តាម៉ុករស់នៅ ។ ខ្ញុំបានជួបលោកយាយ ពូន ចំពេលដែលលោកយាយកំពុងតែដកសំណាបរបស់គាត់កណ្តាលថ្ងៃត្រង់ក្តៅហែង ។ លោកយាយ អ៊ុង ពូន អាយុ៦៨ឆ្នាំ ជាកូនទី៣ក្នុងគ្រួសារ និងជាប្អូនទី២ ហើយជាប្អូនស្រីតែម្នាក់គត់ដែលនៅរស់ក្នុងចំណោមប្អូនទាំង៦នាក់របស់តាម៉ុក ។ សព្វថ្ងៃលោកយាយរស់ប្រកបរបរធ្វើស្រែចម្ការតែម្នាក់ឯងដោយគ្មានកូនចៅជួយជាដៃជើងនៅភូមិត្រពាំងធំ ឃុំ ត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ ។ លោកយាយបានប្រាប់ខ្ញុំថា តាំងពីពេលដែល តាម៉ុក ត្រូវចាប់ខ្លួនមានអ្នកកាសែតជាច្រើនបានមកសួរលោកយាយពីរឿងរបស់តាម៉ុក ។ លោកយាយធ្លាប់ត្រូវបានអ្នកកាសែតបរទេសប្រាប់ថា នឹងនាំលោកយាយទៅជួបនិយាយផ្ទាល់ជាមួយតាម៉ុកនៅក្នុងគុកទៀតផង ។ អ្នកកាសែតទាំងនោះបានត្រឹមតែដឹកលោកយាយទៅដល់ភ្នំពេញប៉ុន្តែពុំបាននាំឲ្យទៅជួបនិយាយជាមួយតាម៉ុកនៅក្នុងគុកទេ ។

លោកយាយមានប្រសាសន៍ថា «ពេលដែលដឹងថា តាម៉ុក ត្រូវគេ (រដ្ឋាភិបាល) ចាប់ដាក់គុក ខ្ញុំអាណិតគាត់ណាស់ ។ ខ្ញុំចង់ជួយគាត់



តាម៉ុក

តែមិនដឹងធ្វើម៉េច ។ ខ្ញុំចង់ជួបនិយាយជាមួយគាត់» ។ លោកយាយមានប្រសាសន៍ទាំងតូចចិត្តថា «អ្នកផងនិយាយថា តាម៉ុក ជាអ្នកមានស្តុកស្តម្ភ ។ ខ្លះទៀតថា តាម៉ុក ឲ្យលុយខ្ញុំច្រើន តែតាមពិត តាម៉ុក មិនដែលឲ្យលុយខ្ញុំទេ ។ ខ្ញុំរស់នៅធ្វើស្រែចម្ការចិញ្ចឹមខ្លួនឯង» ។ លោកយាយ ពូន ធ្លាប់បានទៅជួប តាម៉ុក ម្តងនៅអន្លង់វែងកាលពីអំឡុងពេលអ៊ុនតាក់ចូលមករៀបចំការបោះឆ្នោតជាលើកទី១ នៅប្រទេសកម្ពុជា (អំឡុងឆ្នាំ ១៩៩២-៩៣) ។ លោកយាយមានប្រសាសន៍ថា «នៅអន្លង់វែង តាម៉ុក ប្រាប់ខ្ញុំថា «អញគ្មានលុយទេ ។ អញមិនមែនអ្នករកស៊ីទេ អញអ្នករត់» ។ ខ្ញុំបានហៅគាត់ត្រឡប់មកនៅភូមិកំណើតវិញ តែគាត់ថា អញមិនទៅទេ អញខ្លាចគេចាប់អញដាក់គុក» ។

តាម៉ុកត្រូវបានចាប់ខ្លួនដោយកងទ័ពរដ្ឋាភិបាលកម្ពុជា កាលពីថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៩៩ នៅតំបន់មួយលើអន្លង់វែង ជាប់ព្រំដែនកម្ពុជាថៃ ។ បច្ចុប្បន្ន តាម៉ុក កំពុងត្រូវបានឃុំខ្លួន នៅក្នុងគុករង់ចាំការវិនិច្ឆ័យទោសដោយតុលាការឯករាជ្យមួយ ដែលនឹងត្រូវបង្កើតឡើងនាពេលខាងមុខ ។

តាម៉ុកមានឈ្មោះដើមថា អ៊ុង ជឿន (ឬ ឈិត ជឿន) កើតនៅភូមិប្រគាប ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ ។ តាម៉ុកកើតឆ្នាំខាល (ឆ្នាំ១៩២៦) មកដល់បច្ចុប្បន្ននេះ តាម៉ុក មានអាយុ៧៤ឆ្នាំហើយ ។ លោកយាយ ពូន មានប្រសាសន៍ថា កាលពីក្មេង (អំឡុងទសវត្សរ៍ឆ្នាំ៣០) លោកយាយមិនសូវបានជួបមុខតាម៉ុកទេ ព្រោះ តាម៉ុក រស់នៅជាមួយយាយទួត នៅភូមិប្រគាបតាំងពីអាយុប្រហែល៨ឆ្នាំ ចំណែកខ្លួនលោកយាយរស់នៅជាមួយឪពុកម្តាយនៅភូមិត្រពាំងគល់ ។ តាម៉ុក កើតក្នុងគ្រួសារកសិករដែលស្រវាស្រទេញពីរឿងធម៌អាថ៌ ។ ឪពុករបស់តាម៉ុកឈ្មោះ អ៊ុង ព្រាក ជាចៅអធិការវត្តមហាមន្ត្រី (ភ្នំពេញ) ម្តាយឈ្មោះ ទូច សុច ។ តាម៉ុក ជាកូនច្បងក្នុងចំណោមបងប្អូន៧នាក់ (ប្រុស៣ ស្រី៤) ។ ប្អូនប្រុសបន្ទាប់ពីតាម៉ុក ឈ្មោះ ចុក (ហៅ ចុង) បន្ទាប់មកលោកយាយ ពូន ប្អូនប្រុសបន្ទាប់ឈ្មោះ ចំ ប្អូនស្រីឈ្មោះ គួប ឈ្មោះគឿន និង គេន ។ តាម៉ុកជាមនុស្សមានមាឌល្អិត រាងស្គមស្តើង និងមានសម្បុរសជ្រះ ។ កាលពីក្មេងតាម៉ុករៀននៅវត្តត្រពាំងធំ ក្បែរភូមិកំណើត ។ បន្ទាប់មកនៅពេលអាយុជាង១០ឆ្នាំ តាម៉ុកក៏បួសនៅវត្តត្រពាំងធំដដែលនេះ ។ បួសបាន១វស្សា ឪពុករបស់តាម៉ុក ក៏យកតាម៉ុកមកឲ្យរៀននៅសាលាបាលីនៅវត្តមហាមន្ត្រីជាមួយគាត់ ។ តាម៉ុកបួសរៀននៅវត្តមហាមន្ត្រីអស់រយៈពេលជាង១០ឆ្នាំ រហូតដល់ប្រឡងបានសញ្ញាប័ត្រសាលាបាលីរងទើបសឹកពីបួស ។ លោកអ៊ឹ ង៉ែត ខេង បច្ចុប្បន្នជាប្រធានភូមិត្រពាំងធំ បានបួសរៀននៅវត្តត្រពាំងធំជាមួយ តាម៉ុក តាំងពីកុមារបានឲ្យដឹងថា មូលហេតុតាម៉ុកសឹកពីបួសដោយសារប្រឡងចូលសាលាបាលីជាន់ខ្ពស់មិនជាប់ ។ លោកយាយ គល់ មី នៅភូមិត្រពាំងធំ ជាប្អូនជីដូនមួយរបស់ តាម៉ុក មានប្រសាសន៍ថា អ្នកភូមិហៅ តាម៉ុកថា «អាចារ្យជឿន» ។ កាលនៅបួស តាម៉ុកពូកែទេសនាណាស់ ។ តាម៉ុកបួសរៀនរហូតដល់ចេះចប់គម្ពីរព្រះត្រៃបិដក ។ ទាំងលោកយាយ ពូន លោកយាយ មី និង លោកអ៊ឹ ខេង សុទ្ធតែអះអាងថា តាម៉ុកពីមុនជាក្មេងស្លូតបូតសុភាពរាបសា មានសន្តានចិត្តល្អ មានមេត្តាធម៌ និងមិនចេះប្រកាន់ខ្លួន ។ លោកយាយ ពូន បញ្ជាក់ថា «សូម្បីតែត្រីឬមាន់ទាក៏តាម៉ុក មិនដែលសម្លាប់ដែរ» ។

បន្ទាប់ពីសឹកពីបួស តាម៉ុក បានមករៀបការប្រពន្ធដែលត្រូវជាបងប្អូនជីដូនមួយនៅភូមិប្រគាប ឃុំត្រពាំងធំ ។ ប្រពន្ធរបស់តាម៉ុកឈ្មោះ ខឹម ។ កូនរបស់តាម៉ុក៤នាក់សុទ្ធតែស្រីទាំងអស់ ។ កូនស្រីច្បងរបស់តាម៉ុកឈ្មោះ ខុម (?) បន្ទាប់មកឈ្មោះ ហឿ ឈ្មោះ ហេង និង ឆិច ។

គ្មាននរណានៅក្នុងភូមិកំណើតដឹងថា តាម៉ុកទាក់ទងនឹងចលនាតស៊ូតាំងពីពេលណាទេ ប៉ុន្តែលោកអ៊ឹ ង៉ែត ខេង មានប្រសាសន៍ថា តាំងពីសឹកពីបួសមក តាម៉ុក ចាប់ផ្តើមបែកឆ្វេងចូលចិត្តរឿងនយោបាយ ហើយក៏មានការទាក់ទងជាមួយចលនាតស៊ូឥស្សរៈ ។ ក្រោយពេលរៀបការហើយបាន១ឆ្នាំ (អំឡុងទសវត្សរ៍ឆ្នាំ៤០ ឬ ៥០) តាម៉ុកត្រូវគិញរដ្ឋាភិបាលតាមដាន ។ តាម៉ុក ក៏ចេញទៅរកស៊ីដឹកឈើពីព្រៃយកមកលក់ប្រហែលជាលេសដើម្បីទាក់ទងខ្សែរយៈចលនាតស៊ូនៅក្នុងព្រៃ តែដោយត្រូវគិញតាមដានស្អិតពេកតាម៉ុកក៏គេចបាត់ពីផ្ទះរហូតក្រោយពីមានកូន២នាក់ ។ តាំងពីពេលនោះមក តាម៉ុក ក៏ផ្តាច់ការទាក់ទង

ជាមួយឪពុកម្តាយបងប្អូនទាំងអស់ ។ លោកយាយ ពូន មានប្រសាសន៍ថា «តាម៉ុកមិនដែលប្រាប់អ្នកណាថាគាត់ធ្វើអីនៅឯណាទេ ។ យូរៗគាត់មកលេងផ្ទះម្តង មកអើតឪពុកម្តាយតែមួយភ្លែតក៏ទៅវិញបាត់ទៅ» ។ លោកយាយ គល់ មី បានប្រាប់ខ្ញុំថា ក្នុងអំឡុងពេលតស៊ូ តាម៉ុក បានទៅប្រទេសវៀតណាមជាញឹកញាប់ព្រោះមានមិត្តភក្តិជិតស្និទ្ធម្នាក់ ឈ្មោះ ស៊ុន ជាជនជាតិវៀតណាម ។ តាម៉ុក អាចនិយាយភាសាវៀតណាមបានយ៉ាងរអិល ។ លោកយាយមី បន្ថែមទៀតថា តាម៉ុក និយាយមិនសូវត្រូវគ្នានឹងឪពុកទេដោយហេតុថា ឪពុករបស់ តាម៉ុក ជាអ្នកប្រណិបត្តិធម៌អាថ៌ ហើយ តាម៉ុក បែរជាបែកទៅខាងនយោបាយទៅវិញ ។ ឪពុករបស់ តាម៉ុក ហៅតាម៉ុកថា អា «ពាល» ។

តាម៉ុក បានក្លាយជាគណៈស្រុកនៃក្រុមខ្មែរឥស្សរៈនៅខេត្តតាកែវនៅឆ្នាំ១៩៤៩ និងក្លាយជាសមាជិកបក្សកុម្មុយនិស្តកម្ពុជានៅឆ្នាំ១៩៦៣ ។ តាម៉ុកត្រូវបានតែងតាំងជាលេខាតំបន់និរតីនៅឆ្នាំ១៩៦៨ បន្ទាប់មកនៅខែកក្កដា ឆ្នាំ១៩៧១ តាម៉ុកក្លាយជាសមាជិកគណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនិស្តកម្ពុជាដែលបានចូលរួមដឹកនាំគោលនយោបាយសម្លាប់មនុស្សអស់រាប់លាននាក់ ក្នុងអំឡុងពេលនៃការគ្រប់គ្រងប្រទេសជិត៤ឆ្នាំរបស់ក្រុមខ្លួន ។ បងប្អូនរបស់ តាម៉ុក ក៏មានឋានៈខ្ពស់ៗជាកម្មាភិបាលខ្មែរក្រហមដែរ ។ ប្អូនប្រុសឈ្មោះ ចុក (ហៅ ចុង) ជាលេខាស្រុកព្រៃកប្បាស ។ ចំណែកឈ្មោះ ចំ ជាលេខាឃុំពកត្របែក ។ កូនស្រីម្នាក់របស់តាម៉ុកត្រូវបានតែងតាំងជាអនុលេខាតំបន់នៅឆ្នាំ១៩៧២ ។ កូនប្រសាច្បងរបស់តាម៉ុកឈ្មោះ ខែ មុត (ហៅ មាស មុត) ឆ្នាំ១៩៧៣ជាលេខាថ្មីនៃកងពលតូចលេខ៣ ប្រចាំតំបន់ ។

ទន្ទឹមនឹងតួនាទីជាលេខាតំបន់និរតី តាម៉ុក ទទួលខុសត្រូវផ្នែកយោធានៅតំបន់និរតី ។ លោកអ៊ំ ង៉ែត ខេង បានឲ្យដឹងថា កាលពីជំនាន់ប៉ុលពត លោកអ៊ំរស់នៅជិតស្និទ្ធនឹងតាម៉ុក ។ តាម៉ុកតែងតែចាត់ទុកលោកអ៊ំជាទីប្រឹក្សាផ្នែកបច្ចេកទេសសំណង់ការដ្ឋាននានាដូចជាទំនប់ ប្រឡាយ ស្ពាន ទ្វារទឹក ជាដើម ។ តាមដែលលោកអ៊ំដឹងអំពីតាម៉ុក តាម៉ុកជាមេទ័ពដ៏ក្លាហានបំផុត ។ តាម៉ុក មិនដែលរត់ចោលកូនទាហានម្តងណាឡើយ ។ ក្នុងឋានៈជាលេខាតំបន់ គ្មានថ្នាក់ក្រោមណាម្នាក់ហ៊ានតវ៉ាឬប្រឆាំងនឹងបញ្ជារបស់តាម៉ុកឡើយ សូម្បីតែវៀតណាមដែលធ្វើការជាមួយក៏ខ្លាចតាម៉ុកដែរ ។

ជំនាន់ប៉ុលពត តាម៉ុករស់នៅក្នុងផ្ទះវីឡាដ៏ធំមួយនៅទីរួមខេត្តតាកែវជាមួយនឹងប្រពន្ធកូន ។ លោកយាយ មី ប្រាប់ថា កាលជំនាន់ប៉ុលពតគេហៅ តាម៉ុក ថា «តា១៥» ពីព្រោះ តាម៉ុក មានកំណើតនៅតាកែវ លេខកូដខេត្តតាកែវគឺ «១០៥» ។ ក្រោយជ័យជម្នះទូទាំងប្រទេសរបស់ខ្មែរក្រហម តាម៉ុកបានទៅប្រជុំជាមួយថ្នាក់ដឹកនាំខ្មែរក្រហមនៅវត្តត្រពាំងធំ ឯភូមិកំណើតរបស់ តាម៉ុក ។ លោក យាយ មី មានប្រសាសន៍ថា «កាលជំនាន់ប៉ុលពត តាម៉ុកមកប្រជុំនៅវត្តត្រពាំងធំនេះជាមួយអង្គការថ្នាក់លើ និងគណៈស្រុក គណៈឃុំ តែពេលប្រជុំរួចក៏ត្រឡប់ទៅវិញវីង អត់មានងាកមើលបងប្អូនអ្នកភូមិអីបន្តិចទេ» ។

ទាក់ទងនឹងការចោទប្រកាន់ថា តាម៉ុក សម្លាប់មនុស្ស លោកអ៊ំ ង៉ែត ខេង មិនជឿទាល់តែសោះឡើយ ។ លោកអ៊ំមានប្រសាសន៍ថា «និយាយថាតាម៉ុកសម្លាប់មនុស្សយ៉ាងម៉េចបើកាលពីជំនាន់ប៉ុលពត ក្មួយរបស់ តាម៉ុក ក៏ស្លាប់ ហើយសាច់ញាតិរបស់តាម៉ុកក៏មានស្លាប់ដែរ អ៊ីចឹងចោទថាតាម៉ុកសម្លាប់មនុស្សម៉េចនឹងបាន ។ រឿងសម្លាប់មនុស្សនេះគឺថ្នាក់ក្រោមដូចជាស្រុក ឃុំ ភូមិ និងឈ្លប ទេជាអ្នកសម្លាប់ តាម៉ុកមិនបានដឹងរឿងមនុស្សស្លាប់រាប់លាននាក់នេះឡើយ» ។ ចំណែកលោកយាយ ពូន មានប្រសាសន៍ថា «រឿងដែលគេថាគាត់សម្លាប់មនុស្សនេះ បើថាជឿឬមិនជឿក៏ថាមិនបានព្រោះខ្ញុំមិនបានឃើញផ្ទាល់ភ្នែក ។ បើចង់ឲ្យជឿលុះត្រាតែយើងបានឃើញផ្ទាល់ភ្នែក» ។ ដោយឡែកលោកយាយ មី ដែលបាត់បង់បងប្រុសជាអ្នកបើកបរយន្តហោះដ៏ជាទីស្រឡាញ់របស់គាត់ក្នុងរបបខ្មែរក្រហម មានប្រសាសន៍ថា «វាជារឿងពិបាកនឹងជឿដែលថាមនុស្សម្នាក់ដែលមិនដែលបៀតបៀនសូម្បីតែជីវិតសត្វប្រែក្លាយជាឃាតករសម្លាប់មនុស្សរាប់លាននាក់ទៅវិញ ។ តែទោះជាយ៉ាងណាក៏តាម៉ុក បានធ្វើឲ្យមនុស្សស្លាប់រួចទៅហើយ» ។ លោកយាយ មី បង្ហាញនូវបំណងចង់ឲ្យ តាម៉ុក ទទួលខុសត្រូវនូវអ្វីដែលបានធ្វើក្នុងរយៈកាលកន្លងមក ។ «តាម៉ុកគឺជាខ្លាំង!» លោកយាយ មី

បន្ថែម ។ នៅពេលដែលខ្ញុំសួរថាតើចង់ឲ្យមានតុលាការកាត់ទោសតាម៉ុកឬទេ លោកយាយ មី ឆ្លើយថា «តាម៉ុក ចង់រស់សុខស្រួលយ៉ាងម៉េចបើគាត់ធ្វើឲ្យប្រជាជនស្លាប់រាប់លាននាក់ ។ អ្វីដែលតាម៉ុក ធ្វើកន្លងមកគឺខុស ។ តាម៉ុក ត្រូវតែទទួលផលកម្មដែលគាត់បានសាង ។ ព្រះពុទ្ធបានថែងថា ធ្វើល្អបានផលល្អ ធ្វើអាក្រក់បានផលអាក្រក់ ។ ដូច្នេះបើ តាម៉ុក ធ្វើល្អគាត់នឹងបានផលល្អ បើធ្វើអាក្រក់គាត់នឹងបានផលអាក្រក់ ។»

ចំពោះលោកយាយ ពូន វិញ មិនថា តាម៉ុក បានធ្វើកំហុសធំប៉ុណ្ណាចំពោះប្រជាជនកម្ពុជាទេ តាម៉ុក ជាសាច់ឈាមរបស់គាត់ដែលមិនអាចកាត់ចោលបាន ។ លោកយាយនិយាយថា «ទោះជាមនុស្សទាំងអស់ថាគាត់បានសម្លាប់មនុស្សក៏ដោយ ខ្ញុំនៅតែចាត់ទុកគាត់ជាបងប្រុសរបស់ខ្ញុំដដែល ។ ខ្ញុំចង់ឲ្យគេ (រដ្ឋាភិបាល) ដោះលែងគាត់ខ្លាំងណាស់ ។ ខ្ញុំចង់ឲ្យគាត់មករស់នៅជាមួយខ្ញុំវិញ» ។ លោកយាយ ពូន និយាយទាំងអួលដើមកថា «បើបានគាត់មកវិញមែនខ្ញុំសុខចិត្តធ្វើការលំបាកវេទនាចិញ្ចឹមគាត់ឲ្យតែបានឃើញមុខគាត់ ។ ខ្ញុំនឹកគាត់ទាល់តែវង្វេងវង្វាន់អស់ទៅហើយ ។ ខ្ញុំចង់ឃើញមុខគាត់ ខ្ញុំខ្លាចគាត់ស្លាប់ខានឃើញមុខ ព្រោះគាត់អាយុច្រើនហើយ» ។ លោកយាយ ពូន មានប្រសាសន៍ហាក់ចង់ឲ្យមនុស្សទាំងអស់លើកលែងទោសឲ្យ តាម៉ុក ថា «មនុស្សម្នាក់ៗ ពេលធ្វើខុសមិនដឹងខ្លួនទេ ។ ទាល់តែខុសហើយទើបរកត្រូវឃើញ...» ។

ឆ្លើយតបនឹងសំណួរអំពីតុលាការកាត់ទោសតាម៉ុក លោកយាយ ពូន ប្រាប់ថា «ខ្ញុំមិនដឹងទេ ព្រោះខ្ញុំមិនបានរៀនសូត្រ មិនយល់...ពីរឿងតុលាការ ។ ប៉ុន្តែខ្ញុំចង់បានតែការពិត ។ តាម៉ុក សម្លាប់មនុស្សមែនឬអត់ខ្ញុំចង់ឲ្យមានការពិត ។ បើគេឃើញថាគាត់សម្លាប់មនុស្សហើយគាត់បែរជាកែខ្លួនថាអត់សម្លាប់ទៅវិញ នោះក៏មិនយុត្តិធម៌ដែរ» ។

**សាន់ កល្យាណ**

## សេចក្តីកែតម្រូវ

នៅក្នុងអត្ថបទៈ «ការរៀបចំឯកសារទាក់ទងនឹងអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា» អាសយដ្ឋានប្រព័ន្ធអ៊ីនធ័រនែតដែលបង្ហាញអំពីទិន្នន័យនៃប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ មានដូចខាងក្រោមនេះ ÷

1. http://welcome.to/dccam
2. http://www.yale.edu/cgp
3. http://www-cgp.sistm.unsw.edu.au



យាយ ពូន (ប្អូនស្រីតាម៉ុក)

# រណ្តៅសាកសពប្រល័យពូជសាសន៍ ខេត្តបន្ទាយមានជ័យ

**(តពីលេខមុន)** ***៣) វត្តបន្ទាយនាងៈ*** ជាទីតាំងសម្រាប់និងគុក ក្នុងភូមិភ្នំ ឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ។ តាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្រ្តពិភពលោក បង្ហាញថាទីតាំងនេះស្ថិតនៅក្នុងចំណុចខ្សែស្រប ១៣° ៣០' ៤០៩៤" និងខ្សែបណ្តោយ ១៣០° ០០' ៥០៥៤" ។ ទិន្នន័យចំណុចទីតាំងភូមិសាស្រ្តនេះត្រូវបានថតទុកក្នុងឧបករណ៍អេឡិចត្រូនិកឯកសារលេខR០៤២៩០៩A ។ ទីតាំងនេះត្រូវបានចុះទៅស្រាវជ្រាវនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៩៧ វេលាម៉ោង៤ៈ៤០នាទីល្ងាច ។

លោកតាអាចារ្យ ឃុន សាយ អាយុ៥៨ឆ្នាំ ធ្លាប់ជាប់គុកជំនាន់ប៉ុលពត បច្ចុប្បន្ននៅភូមិធំ ឃុំបន្ទាយនាង ស្រុកមង្គលបូរី ។ គាត់ជាប់គុកឆ្នាំ១៩៧៦ រហូតឆ្នាំ១៩៧៧ នៅគុកចម្ការខ្នុរ (វត្តចម្ការខ្នុរ) ក្នុងស្រុកសេរីសោភ័ណ ។ សាក្សីម្នាក់ទៀតឈ្មោះ ស្រីប ថ្វាង អាយុ៦០ឆ្នាំ រស់នៅក្នុងភូមិឃុំស្រុកដូចគ្នាដែរ ។ សាក្សីទាំងពីរនាក់នោះប្រាប់ថា នៅមណ្ឌលឧក្រិដ្ឋកម្មនេះពួក ប៉ុល ពត យកព្រះវិហារ យកកុដិលោកសង្ឃនៃវត្តបន្ទាយនាងមកធ្វើជាគុក ឯកន្លែងសួរចម្លើយនិងកន្លែងសម្រាប់ស្ថិតនៅមុខវត្តបន្ទាយនាងនេះតែម្តង ។ សាក្សីបាននាំយើងទៅពិនិត្យរណ្តៅមុខវត្តនេះដែលរលុបបាត់ស្ទើរអស់ទៅហើយ ។ គាត់បានប្រាប់យើងថា រណ្តៅច្រើនណាស់ឃ្លាតពីមួយទៅមួយតែ១ម៉ែត្រទេ អាចប៉ាន់ស្មានថាពី១០០រណ្តៅ ទៅ២០០រណ្តៅ មានពេញទំហំដី១ហិកតាបួនជ្រុង និងបណ្តោយលេណដ្ឋានប្រវែងចំនួន៥០០ម៉ែត្រទៅ១០០០ម៉ែត្រសុទ្ធតែរណ្តៅដែរ ។ គាត់



វត្តបន្ទាយនាង

ប៉ាន់ស្មានពេលនោះថា ១រណ្តៅមាន២០ ទៅ២៥នាក់ អាចមាន ៣០នាក់ក៏មាន ។ នៅឆ្នាំ១៩៧៩ ពួកវៀតណាមមកជីកយកខ្មោះពីព្រះវិហារមិនដឹងយកទៅណាទេ ពេលនោះឈាមនៅប្រឡាក់ជញ្ជាំងថ្មីៗ ។ នៅមុខព្រះវិហារមានរណ្តៅដីធំមួយដែលបម្រុងយកប្រជាជននៅភូមិ-ឃុំនេះមកប្រជុំ ពួកខ្មែរក្រហមបានបោកបញ្ឆោតថា ប្រជុំរួចឲ្យហូបនំបញ្ចុក ហើយនៅតែ២ថ្ងៃទៀតដល់ថ្ងៃប្រជុំ ប៉ុន្តែមិនបានប្រជុំឡើយព្រោះប្រទេសជាតិត្រូវបានរំដោះមុននៅថ្ងៃ៧ ខែមករា ឆ្នាំ១៩៧៩ ។ ប្រភេទជនរងគ្រោះនៅវត្តបន្ទាយនាងនេះមានចម្រុះគ្នា ជាមន្ត្រីរាជការស៊ីវិល និងជាជនជាតិចិន យួន ដែលត្រូវជាប់ឃុំក្នុងវិហារនេះ ហើយត្រូវបានសម្លាប់ទាំងអស់នៅទីនោះអស់ចំនួនប្រហែលពី៣៥០០នាក់ទៅ ៥០០០នាក់ គាត់ថាអាចមានច្រើនជាងនេះទៀតផង ។

**៨) ចម្ការគាលីង៖** ជាទីតាំងសម្លាប់ស្ថិតក្នុងភូមិជួប ឃុំជួបវ៉ារី ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។ តាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រពិភពលោក (Global Positioning System) បង្ហាញថាទីតាំងនេះស្ថិតនៅក្នុងចំណុចខ្សែបណ្តោយ ១០៣° ១០' ៤៧០៧" និងខ្សែស្របច ១៣° ៣៥' ៥៦៣៧" ។ ទិន្នន័យចំណុចទីតាំងភូមិសាស្ត្រនេះត្រូវបានថតទុកក្នុងឧបករណ៍អេឡិចត្រូនិក ឯកសារលេខ R០៨៣០០២A ។ ចម្ការគាលីងមានចម្ងាយ១០០ម៉ែត្រពីវត្តព្រះនេត្រព្រះ ។ វត្តព្រះនេត្រព្រះនេះជាមន្ទីរពេទ្យកាលជំនាន់ប៉ុលពត ។ ទីតាំងនេះត្រូវបានចុះទៅស្រាវជ្រាវដល់នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៧ វេលាម៉ោង ៩:៤៥ នាទីល្ងាច ។

លោក ទុំ សឿន អាយុ៤៥ឆ្នាំ បានអះអាងថា ពេលគាត់មកជីករកមាស គាត់បានឃើញក្នុងមួយរណ្តៅមានមនុស្សស្លាប់ពី១១០នាក់ទៅ១២០នាក់ មានរណ្តៅធំៗចំនួន៦ ទំហំ៤ម៉ែត្របួនជ្រុង ជម្រៅ២ម៉ែត្រ ។ ដូច្នេះអាចមានមនុស្សស្លាប់ចំនួនពី ៦៦០នាក់ទៅ៧២០នាក់ ។ រណ្តៅទាំងនោះស្ថិតក្នុងចម្ការគាលីងខាងក្រោយគុកសន្តិសុខចម្ងាយប្រមាណ៥០ម៉ែត្រ ។ នៅទីនោះក្នុងជំនាន់ ប៉ុល ពត នៅក្នុងឃុំមានផ្ទះក្បឿងមួយខ្នងសម្រាប់ដាក់អ្នកទោស ហើយវាយសម្លាប់អស់ដាក់បន្ថែមអ្នកទោសថ្មីដែលយកមកក្រោយៗទៀត ។ អំពីប្រភេទជនរងគ្រោះស្លាប់នៅទីនេះ លោក ទុំ សឿន បន្ថែមថា ភាគច្រើនជាមនុស្សចាស់អាយុពី៤៥ចុះ តាមការឃើញឆ្អឹងលលាដ៍ក្បាលជនរងគ្រោះ ហើយជាមន្ត្រីរដ្ឋការស៊ីវិលជម្លៀសចេញពីទីក្រុងដែលមានសុទ្ធតែប្រុសៗ រីឯអដ្ឋិធាតុគ្មានសល់ទេគឺចាស់ៗឲ្យដុតចោលអស់ហើយ ។

**៩) ព្រៃតារត់៖** ជាទីតាំងសម្លាប់ស្ថិតនៅក្នុងភូមិជួប ឃុំជួបវ៉ារី ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យដែរ ។ តាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រពិភពលោកបង្ហាញថាទីតាំងនេះស្ថិតនៅក្នុងចំណុចខ្សែបណ្តោយ ១០៣° ១០' ៤៣៣៤" និងខ្សែស្របច ១៣° ៣៧' ៣៨៣៦" ។ ទិន្នន័យចំណុចទីតាំងភូមិសាស្ត្រនេះត្រូវបានថតទុកក្នុងឧបករណ៍អេឡិចត្រូនិកឯកសារលេខ R០៨៣០០៣A ។ ព្រៃតារត់ ស្ថិតនៅខាងក្រោយមន្ទីរពេទ្យស្រុកព្រះនេត្រព្រះ ចម្ងាយ១០០ម៉ែត្រ ។ ព្រៃនោះជាកន្លែងដែលពួកខ្មែរក្រហមវាយសម្លាប់មនុស្សពោលគឺជាកន្លែងសម្លាប់មិនមែនជាគុកទេ ហើយជនរងគ្រោះមានចំនួន ៣៨៩០នាក់ ។ ទីតាំងនេះត្រូវបាន


ទុំ សឿន


ថ្វាន ថុង

ចុះទៅដល់នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៧ វេលាម៉ោង ១០:២០ នាទីព្រឹក ។

លោក ថ្វាន ថុង អាយុ៤៩ឆ្នាំ បានអះអាងថាគាត់គ្រាន់តែដឹងថាជាកន្លែងសម្លាប់ ប៉ុន្តែជនរងគ្រោះយកពីណាមក គាត់មិនបានដឹងទេ ឯឆ្អឹងគាត់បានយកទៅដាក់លើសារមន្ទីរភ្នំជញ្ជាំង ប៉ុន្តែខ្វះវិធានការទប់ស្កាត់ក៏រលុបរលាយបាត់អស់ទៅ ។

**៦) ភូមិចក្រី:** ជាទីតាំងសម្លាប់ស្ថិតនៅក្នុងភូមិចក្រី ឃុំជួបវ៉ារី ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។ តាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រពិភពលោកបង្ហាញថាទីតាំងនេះស្ថិតនៅក្នុងចំណុចខ្សែបណ្តោយ ១០៣° ១០'៤៥០២" និងខ្សែស្រប ១៣° ៣៧' ២៤១១" ។ ទិន្នន័យចំណុចទីតាំងភូមិសាស្ត្រនេះត្រូវបានថតទុកក្នុងឧបករណ៍អេឡិចត្រូនិកឯកសារលេខ R០៤៣០០៣B ។ ទីតាំងនេះត្រូវបានចុះទៅដល់នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៧ វេលាម៉ោង១១:០០នាទីព្រឹក ។

អំពីពត៌មានស្តីអំពីទីតាំងសម្លាប់ទូទាំងស្រុកព្រះនេត្រព្រះក្នុងឃុំទាំង៨គឺនៅមានច្រើនកន្លែងទៀត ។ ប៉ុន្តែយើងទៅបានតែមួយចំនួនទេដោយសារតែទីតាំងសម្លាប់ខ្វះនៅឆ្ងាយសន្តិសុខមិនអាចទៅបាន ហើយផ្លូវពិបាក ។ ស្រុកព្រះនេត្រព្រះ យើងងាយស្រួលពីព្រោះយើងមានឯកសារផ្តល់មកពីការិយាល័យវប្បធម៌ស្រុកដែលបានស្រង់ចាប់ពីឆ្នាំ១៩៨៤មក ។ មានស្ថិតិជនរងគ្រោះទូទាំងឃុំនិងទីតាំងសម្លាប់តាម ភូមិ-ឃុំ ។ តាមឯកសាររបស់ការិយាល័យវប្បធម៌ស្រុកបង្ហាញថាជនរងគ្រោះទូទាំង៨ឃុំ មានចំនួន ៧៨៤៩៦នាក់ ហើយមានរហូតដល់៣៣ទីតាំង ។ ប៉ុន្តែយើងបានចុះស្រាវជ្រាវបានតែ៣កន្លែងប៉ុណ្ណោះ ។

ក្រៅពីនេះមានពត៌មានមួយបញ្ជាក់ថានៅទីតាំងភ្នំត្រយ៉ូងចំនួនជនរងគ្រោះមានរហូតទៅដល់ ៤០០០០នាក់ ទីនោះជាគុកធំនិងជាកន្លែងសម្លាប់ដ៏ខ្លាំងដែលស្ថិតនៅចម្ងាយ២០គីឡូម៉ែត្រពីទីនេះ ។

ការចុះស្រាវជ្រាវនេះយើងបានជួបសាក្សីបំភ្លឺពត៌មានពិតជាក់ស្តែង ថតចម្លងបទសម្ភាសន៍ក្នុងកាសែ្សត និងពិនិត្យថតទីតាំងសម្លាប់ ថតរណ្តៅ ថតសាក្សី ទុកជាឯកសារភស្តុតាងនិងបម្រើឲ្យប្រវត្តិសាស្ត្រសម្រាប់មនុស្សជំនាន់ក្រោយៗទៀត ។

**ឌួង សុភារិទ្ធ**

## ពាក្យស្លោកខ្មែរក្រហម

**◆ កម្មាភិបាលល្អនិងគណៈកម្មាធិការល្អ គឺស្ទុះស្ទារដោះស្រាយនិងលើកស្ទួយជីវភាពមហាជនបានល្អគ្រប់ផ្នែក និងគ្រប់ពេលវេលា ដោយគោលជំហរទទួលខុសត្រូវ និងថ្លៃប្រឌិតគំនិតផ្តើមខ្ពស់។**

(ដកស្រង់ចេញពីសៀវភៅលេខ១០៧៦ កណហ)

**◆ បដិវត្តន៍ចក្រពត្តិមិនមែនអញ្ជើញភ្ញៀវទៅពិសាបាយទេ មិនមែនសរសេរអត្ថបទទេ មិនមែនប៉ាក់ផ្កាទេ មិនមែនត្រូវអប់រំទេ ទន់ទេ មិនត្រូវព្រងើយកន្តើយ សុភាពរាបសារទេ មិនត្រូវខ្លាចខ្លាំងទេ បដិវត្តន៍គឺជាកំហឹងវណ្ណៈមួយ វាយរំលំវណ្ណៈមួយ។**

(ដកស្រង់ចេញពីសៀវភៅញុក ទំព័រ៧៨)



# អំពីលក្ខន្តិកៈបក្សកុម្មុយនិស្តកម្ពុជា

(ឯកសារទង់បដិវត្តន៍ លេខពិសេស ខែតុលា-វិច្ឆិកា ឆ្នាំ១៩៧៧)

***សំណូមពរ:***

គឺរំលឹកឲ្យកាន់តែជ្រួតជ្រាបនូវខ្លឹមសារផ្សេងៗរបស់លក្ខន្តិកៈនៃបក្សយើង ដើម្បីលើកកំពស់នូវការយល់ដឹងនិងគុណភាពរបស់កម្មាភិបាលនិងបក្សជនយើងខាងមាគ៌ាចាត់តាំងជាមូលដ្ឋានដែលចែងនៅក្នុងលក្ខន្តិកៈ ពីព្រោះលក្ខន្តិកៈវាជាច្បាប់ វាជាធម្មនុញ្ញរបស់ច្បាប់ ។ ធ្វើអ្វីៗត្រូវឈរលើច្បាប់នេះជាមូលដ្ឋាន ។ បើកាលណាយល់ជ្រួតជ្រាបហើយមានគុណភាពលើលក្ខន្តិកៈនេះកាន់តែជ្រៅជ្រះ ការអនុវត្តក៏កាន់តែល្អ ។ បើមិនសូវជ្រួតជ្រាប ដំណើរការទៅ ជួនណាមានការភ្លាត់ភ្លាំងពីច្បាប់ទម្លាប់នេះ ។ ដូចនោះហើយបានជាត្រូវរៀនហើយរៀនទៀត ។ រៀនជាបុគ្គលរៀនជាសមូហភាព ដើម្បីក្តាប់បាននូវលក្ខការណ៍ជាមូលដ្ឋានរបស់បក្សនិងលក្ខការណ៍ចាត់តាំងរបស់បក្ស ។

***អធិប្បាយសំណូមពរ***

រៀនឯកសារនេះវាងដែលទេ ។ តែក្នុងការអនុវត្តវាមិនងដែលទេ ។ ក្នុងការអនុវត្តវាមានការត្រូវតែការខុសក៏មានដែរ ។

***ឧទាហរណ៍:*** ដូចជាមានសេចក្តីរាយការណ៍លើកថា មានពួកខ្លះចូលបក្សដោយគ្មានអីជាសំអាង គ្មានដឹងថ្នាក់ណាជាអង្គការអនុម័ត ។ ថាគ្រាន់តែហូបបាយដំណើបមួយពេលក៏ថាបានចូលបក្សដែរ ។ តាមនេះពួកក្បត់វាលបលួចបញ្ចូលគ្នាវាក្នុងបក្សបាន ។

ហេតុនេះហើយបានជាយើងត្រូវក្តាប់គោលការណ៍ចាត់តាំងរបស់បក្ស ហើយត្រូវតាមដានការអនុវត្តនូវគោលការណ៍ចាត់តាំងនេះទៀតទើបខ្មាំងវាលបលួចបង្កប់ចូលក្នុងបក្សមិនបាន ។ យើងត្រូវចាប់អារម្មណ៍ពង្រឹងអំពីគោលការណ៍ចាត់តាំងរបស់បក្សនេះឲ្យជ្រួតជ្រាបថែមទៀតនៅក្នុងបក្ស ។

**ឧទាហរណ៍:** «ខ» ស្តីពីការជ្រើសរើសកម្មាភិបាលតាមលក្ខណៈសម្បត្តិ១០យ៉ាង ជួនកាលយើងមិនបានពិនិត្យទេ។ ក្នុងនេះ «ខ» ស្តីពីប្រវត្តិរូបពិតមែនតែនៅខាងចុង តែឥឡូវមានសារៈសំខាន់ជាពិសេសដែលត្រូវយកចិត្តទុកដាក់ពិនិត្យឲ្យបាន ព្រោះខ្មាំងវាបង្កប់បានដោយយើងមិនបានពិនិត្យប្រវត្តិរូបហ្មត់ចត់។ សំអាងតែលើជាប់ចលនា។ ចុងបំផុតវាជាខ្មាំង។ «ខ» ឯទៀតស្តីពីការអនុវត្តមាគ៌ានយោបាយ មាគ៌ាសតិអារម្មណ៍ និងមាគ៌ាចាត់តាំង ក៏ត្រូវយកចិត្តទុកដាក់។

**ខ្លឹមសារឯកសារ**

**១) អំពីលក្ខការណ៍និងគោលជំហរនយោបាយជាមូលដ្ឋានរបស់បក្សក្នុងរយៈកាលថ្មីនៃបដិវត្តសង្គមនិយម និងការកសាងសង្គមនិយម**

-បក្សយើងដែលកំណត់ឲ្យឈ្មោះថាបក្សកុម្មុយនិស្តកម្ពុជាដោយហេតុផលថាឲ្យវាស្អាត កុំឲ្យជំពាក់ជំពិនជាមួយបរទេស ពិសេសបរទេសដែលវាចង់សង្គ្រប់យើង។**នេះទី១**។

**ទី២** យើងឃើញថាពួកអាក្សត់ដែលយើងចាប់ក្នុងឆ្នាំ៧៦ ពិសេស៧៧នេះវាបង្កើតបក្សមួយទៀតឲ្យឈ្មោះថាបក្សពលករ ដើម្បីឲ្យទៅជាបក្សមួយដោយឡែកពីបក្សកុម្មុយនិស្តកម្ពុជាយើង។ ឯខ្លឹមសារនៃបក្សនេះជាខ្លឹមសារសេ.អ៊ី.អា ខ្លឹមសារពួកសេរី ពួកបរទេសឈ្លានពានវាគឺលេបទឹកដី។

**ទី៣** យើងចេញបក្សយើងជាចំហ។ តាមខ្លឹមសារដែលយើងចេញនេះ មិត្តភក្តិយើងលើសកលលោកគេរីករាយ។ គេថាមាគ៌ាបក្សយើងត្រឹមត្រូវ។ សូម្បីតែមិត្តមិនមែនជាកុម្មុយនិស្តនៅតតិយលោកក៏គេថាមាគ៌ាយើងត្រឹមត្រូវដែរ។ ហេតុផលរបស់យើងគេឃើញច្បាស់គេជឿ។ ឯបក្សម៉ាក្ស-ឡេនីនវិញគេរៀនសូត្រ។ នេះខាងយើង។

ឯខាងខ្មាំងវិញ ដូចជាចុកមាត់វាអស់។ ដូចនោះពេលបក្សយើងចេញចំហ ប្រតិកម្ម គ្មាននរណាមួយហ៊ានជេរយើងទេ។ ទន្ទឹមនឹងនេះពួកអាខ្មាំងខ្លះវាទឹងសម្បារ វាចុកឈាមខ្លាំងណាស់។

នេះចង់និយាយថា ការប្រយុទ្ធអំពីឈ្មោះបក្សយើង អាយុរបស់បក្សយើង ប្រវត្តិរបស់បក្សយើង ដែលយើងធ្វើឡើងដើម្បីឲ្យបក្សយើងឯករាជ្យ ដោយឈរលើប្រយោជន៍នៃប្រជាជាតិយើង ប្រជាជនយើង ប្រទេសយើង។ តែជំហរឯករាជ្យម្ចាស់ការរបស់យើង ខ្មាំងវាមិនចង់ឲ្យទេ។ វាចង់ឲ្យឈ្មោះបក្ស អាយុបក្ស ប្រវត្តិបក្ស ជាបក្សខ្ញុំគេ។

ឆ្នាំ១៩៦០ ក្នុងការប្រជុំអចិន្ត្រៃយ៍បើកទូលាយ យើងបានសម្រេចថា ត្រូវធ្វើប្រវត្តិរបស់បក្សយើងឲ្យជំនាន់យើងក៏បក្សឯករាជ្យ តពូជតពង្សទៅក៏បក្សយើងឯករាជ្យ។ ឈរលើគោលជំហរនេះ យើងសរសេរប្រវត្តិបក្សយើងនិងប្រវត្តិតស៊ូ ១៧ឆ្នាំរបស់បក្សយើង។ តាមគោលជំហរនេះហើយដែលយើងកំណត់ឈ្មោះបក្សយើង អាយុបក្សយើង និងប្រវត្តិបក្សយើង។ កូនចៅតជំនាន់ទៅទៀតរៀនសូត្រ ប្រវត្តិបក្សគឺប្រវត្តិឯករាជ្យ មិនមែនប្រវត្តិខ្ញុំគេ ខ្ញុំពួកវាតទីទេ។

ខ្លឹមសារឯករាជ្យគឺវាត្រឹមត្រូវ។ តែការពិតជាក់ស្តែងប្រជាជនយើងតស៊ូជំនាន់ណាក៏ដើម្បីឯករាជ្យ។ ពួកជិះជាន់វាធ្វើប្រវត្តិសាស្ត្រដើម្បីជិះជាន់ប្រជាជនតទៅទៀត។ ឯយើងសរសេរប្រវត្តិសាស្ត្រប្រទេសយើង ប្រវត្តិតស៊ូរបស់បក្សយើងនិងប្រជាជនយើង ក៏ដើម្បីឯករាជ្យមិនមែនដើម្បីប្រជាជនយើងខ្ញុំគេតទៅទៀតទេ។

**ឧទាហរណ៍:** សរសេរប្រវត្តិធ្វើអង្គរយើងថាប្រជាជនជាអ្នកធ្វើ។ ហើយការពិតជាក់ស្តែងគឺជាប្រជាជនជាអ្នកធ្វើ មិនមែនស្តេចជាអ្នកធ្វើទេ។

**ឧទាហរណ៍:** ការតស៊ូកន្លងមកក៏ប្រជាជនយើងជាអ្នកធ្វើ។ ប្រជាជនយើងជាអ្នកធ្វើប្រវត្តិសាស្ត្រ។ មិនមែនពួកបរទេសលេបទឹកដីណាវាមកធ្វើប្រវត្តិសាស្ត្រឲ្យប្រជាជនយើងទេ។

យើងត្រូវជ្រះស្រឡះអំពីបញ្ហានេះហើយមានមោទនភាពចំពោះឈ្មោះបក្សយើង ចំពោះអាយុបក្សយើង និងចំពោះប្រវត្តិរបស់បក្សយើង។ បញ្ហានេះនៅមានការតស៊ូតទៅទៀត។ តែបញ្ហានេះស្រេចនៅលើយើងទេ មិនមែនសម្រេចនៅលើខ្មាំងទេ។

**២)** លក្ខការណ៍និងគោលជំហរនយោបាយជាមូលដ្ឋានរបស់បក្សទាំង៩ខ វាសង្ខេបនូវខ្លឹមសារទាំងអស់របស់បក្ស។ វាចង្អុលនូវខ្លឹមសារទាំងអស់របស់បក្សយើង ទាំងនយោបាយ ទាំងសតិអារម្មណ៍ ទាំងចាត់តាំង។

ឧបមាក្នុង«ខ»ទី២ លក្ខន្តិកៈថា បក្សយើងជាបក្សរបស់

វណ្ណៈកម្មករ ។ បើថាបក្សយើងជាបក្សរបស់វណ្ណៈកម្មករហើយ នយោបាយក៏ត្រូវបម្រើវណ្ណៈកម្មករ សតិអារម្មណ៍ក៏របស់វណ្ណៈកម្មករ ចាត់តាំងក៏របស់វណ្ណៈកម្មករ ។ បក្សរបស់វណ្ណៈកម្មករតំណាងឲ្យនរណា? តំណាងឲ្យកម្មករ តែក៏តំណាងឲ្យវណ្ណៈកសិករ ឲ្យវណ្ណៈផ្សេងទៀតទាំងអស់ និងឲ្យប្រជាជាតិទាំងមូល ។

**ឧទាហរណ៍:** «ខ» និយាយថា ក្រោយសម្រេចបដិវត្តប្រជាជាតិប្រជាធិបតេយ្យ បក្សត្រូវបន្តធ្វើបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមទៀត ។

តែពួកអាក្បត់វាប្រឆាំងនឹងមាគ៌ាបន្តធ្វើបដិវត្តន៍សង្គមនិយមរបស់បក្ស ។ ទោះជាវាថាធ្វើបដិវត្តសង្គមនិយមអ៊ីក៏ដោយ តែធាតុពិតរបស់វាគឺទៅនាយទុន ទៅសេរី ទៅខ្ញុំគេ ។

សកលលោកដោយឈរលើអន្តរជាតិនិយមវណ្ណៈអធន ។ យើងធ្វើយ៉ាងនេះទើបខ្មាំងវាឯកោយើងមិនបាន ។ ប្រតិភូយើងទៅចិននិងកូរ៉េ យើងឃើញថាប្រទេសភាគច្រើនលើសកលលោកឧបត្ថម្ភយើង ។ ឯខ្មាំងជានយោបាយរកលេសអីវាយយើងមិនបានទេ ។ វាខឹងសម្បារតែវាត្រូវខ្ទប់មាត់ ។ ដូចនេះយើងត្រូវអានត្រូវរៀនសូត្រឡើងវិញដើម្បីឲ្យជ្រួតជ្រាប ។ បើនរណាប្រឆាំងនឹងលក្ខការណ៍ជាមូលដ្ឋាននេះគឺដើរទៅផ្សេង ដើរទៅនាយទុន ដើរទៅសេរី ដើរទៅប្រឆាំងបក្ស ប្រឆាំងបដិវត្តន៍ ។

យើងត្រូវអាន ត្រូវរៀនសូត្រ ព្រោះលក្ខការណ៍នយោបាយជាមូលដ្ឋាន នេះវាសង្ខេបនូវខ្លឹមសារទាំងអស់របស់បក្ស ។

**ឧទាហរណ៍:** ជំពូកទី១ ចែងថាអ្នកណាប្រឆាំងនឹងមាគ៌ារបស់បក្សដោយធ្វើឲ្យអន្តរាយដល់បក្សត្រូវទទួលវិន័យ ។ ពួកអាក្បត់វាប្រឆាំងពេញទីនឹងមាគ៌ារបស់បក្ស ។ វាធ្វើកម្មវិធីមួយទៀតដើម្បីប្រឆាំងនឹងមាគ៌ារបស់បក្ស ។

**ឧទាហរណ៍:** អំពីទស្សនៈមហាជន និងមាគ៌ាមហាជនក៏យើងត្រូវយល់ឲ្យច្បាស់ អនុវត្តឲ្យជាក់ស្តែង ហើយខំប្រមូលកម្លាំងមហាជនតទៅទៀត ។ បើមិនខំប្រមូលកម្លាំងមហាជនទេ ខ្មាំងវាវាយយើងបាន ។ ប្រមូលកម្លាំងមហាជនឥឡូវគឺត្រូវដោះស្រាយជីវភាពប្រជាជនឲ្យបាន បោសសម្អាតខ្មាំងក៏ឲ្យត្រឹមត្រូវតាមមាគ៌ារបស់បក្សកុំឲ្យប៉ះពាល់កម្លាំងប្រជាជន ។

◆គោលជំហរឯករាជ្យម្ចាស់ការក៏ចែងក្នុងនេះ ។ ដូចនេះត្រូវរៀនសូត្រវាដើម្បីអនុវត្តវាឲ្យស័ក្តិសិទ្ធិថែមទៀត ។

◆ខទី៩ និយាយថា បក្សយើងក៏សាមគ្គីនឹងបក្សម៉ាក្ស-ឡេនីនលើ


ប៉ុល ពត

# បញ្ជីឈ្មោះមន្ត្រីនិងបុគ្គលិកស្ថានទូតកម្ពុជានៅបរទេស
## ដែលជាប់ឃុំឃាំងនៅមន្ទីរ ស២១

| ល.រ | ឈ្មោះអ្នកទោស | ភេទ | មុខងារ | ប្រភពឯកសារ | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|---|
| ១ | គីម វ៉ែន | ប្រុស | លេខាទី២ទូតនៅអារ៉ាប់ | TSL | ១៥-៦-៧៧ | (ឥតមាន) |
| ២ | ង៉ូ តាំងទីកា | ប្រុស | លេខាទី២ទូតនៅរ៉ូម៉ានី | TSL | ១-៦-៧៧ | ២៧-១១-៧៧ |
| ៣ | ចាន់ ម៉ុន | ប្រុស | លេខាទី២ទូតនៅបារាំង | TSL | ១-៦-៧៧ | ៣១-៣-៧៨ |
| ៤ | ជា សាន | ប្រុស | ទូតនៅរុស្ស៊ី | TSL | ៣-៣-៧៨ | ២៧-៥-៧៨ |
| ៥ | តាន់ ឆាយហេង | ប្រុស | លេខាទូតយូហ្គោស្លាវី | TSL | ១៦-៥-៧៧ | (ឥតមាន) |
| ៦ | ថាច់ សួង | ប្រុស | លេខាធិការទី២ទូតនៅយូហ្គោស្លាវី | TSL I08436 | ១៩-១២-៧៦ | ១៨-២-៧៧ |
| ៧ | ទេព សំអាន | ប្រុស | ទូតនៅអាល់ហ្សេរីជាលេខាធិការទី៣ | T83 TSL I08504 | ២៣-១០-៧៦ | (ឥតមាន) |
| ៨ | មាឃ ទូច | ប្រុស | ទូតប្រចាំនៅប្រទេសឡាវ | TSL | ២០-១១-៧៧ | ៣១-៣-៧៨ |
| ៩ | មាស គៀន ហៅ សារេត | ប្រុស | ទូតនៅអេហ្ស៊ីប | TSL | ២៨-១០-៧៦ | ១២-៥-៧៧ |
| ១០ | យុគ ចន្ថា ហៅ ថា | ប្រុស | លេខាទី១ទូតនៅតង់ហ្សានី | Y143, TSL | ២៦-២-៧៨ | ១៨-៧-៧៨ |
| ១១ | យួស ថុល ហៅ ឌាន | ស្រី | លេខាទី២ទូតនៅឡាវ | TSL | ២០-១១-៧៧ | ៣១-៣-៧៨ |
| ១២ | លឿង ហុងសួ | ប្រុស | យាមស្ថានទូតនៅតង់ហ្សានី | TSL | ១៥-៦-៧៧ | (ឥតមាន) |
| ១៣ | ស៊ាន អាន | ប្រុស | ទូតនៅហាណូយ | S163, TSL | ១២-១២-៧៦ | ១៨-១០-៧៧ |
| ១៤ | សុក សុខុម | ប្រុស | ដាំបាយឲ្យទូតខ្មែរនៅបារាំង | TSL | ២៦-២-៧៨ | (ឥតមាន) |
| ១៥ | ហួ សុមេធ | ប្រុស | លេខាទី២ទូតនៅបារាំង | TSL | ១-៦-៧៧ | (ឥតមាន) |
| ១៦ | ហួត សម្បត្តិ | ប្រុស | ទូតប្រចាំប្រទេសយូហ្គោស្លាវី | H89, TSL | ៩-៩-៧៦ | ១៧-១១-៧៦ |
| ១៧ | ហេង សុកឃាង | ប្រុស | ធ្វើការនៅទូតប្រចាំហាណូយ | TSL | ២៥-២-៧៨ | ៣១-១២-៧៨ |
| ១៨ | ហៃ គីរីវ៉ាត់ | ស្រី | បុគ្គលិកទូតនៅគុយបា | TSL | ៨-១២-៧៦ | (ឥតមាន) |
| ១៩ | ហៃ គីមសាង | ប្រុស | លេខាធិការទូតនៅគុយបា | H156, TSL | ៨-១២-៧៦ | ១៨-៣-៧៧ |
| ២០ | ឡេង ថាច ហៅ វុន | ប្រុស | ដាំបាយឲ្យទូតអារ៉ាប់អេហ្ស៊ីប កូរ៉េ | TSL | ២៧-២-៧៨ | (ឥតមាន) |
| ២១ | អ៊ី ស៊ីបគន្ធី | ប្រុស | ទូតប្រចាំប្រទេសស៊ុយអែដ | Y149, TSL I08433 | ៩-៩-៧៦ | ៦-១២-៧៦ |
| ២២ | អ៊ី សេនារ៉ាក់ | ប្រុស | អនុពន្ធស្ថានទូតនៅរុស្ស៊ី | I1, TSL | ១៦-៥-៧៧ | ២០-៧-៧៧ |
| ២៣ | អ៊ិន សុផន | ប្រុស | លេខាទី២ទូតនៅអាល់បានី | TSL | ២៨-៥-៧៧ | ៩-១២-៧៧ |
| ២៤ | អ៊ុក ភេត | ប្រុស | លេខាទី៣ទូតនៅអេហ្ស៊ីប | TSL | ១៥-៦-៧៧ | ៩-១២-៧៧ |
| ២៥ | អ៊ុយ ឡូន ហៅ ជា | ប្រុស | បើកឡាននៅស្ថានទូតម៉ូស្គូ | TSL | ២-៤-៧៧ | ១៣-៣-៧៨ |
| ២៦ | ជីង កុកហួ | ប្រុស | ភារៈស្តីទីស្ថានទូតបារាំង | TSL | ២៣-១០-៧៦ | ២៩-១០-៧៦ |



រូបភាពឯកសារៈ
ការដ្ឋានសំណង់បូជនីយដ្ឋានជើងឯក
ក្នុងទសវត្សរ៍ឆ្នាំ៨០





រណ្តៅរាលពិឃាត
ជើងឯក

# សេចក្តីកែតម្រូវ

ទស្សនាវដ្តីស្វែងរកការពិតលេខ៧ ទំព័រទី៥៤ អត្ថបទដែលមានចំណងជើងថា «ប្រវត្តិរណ្តៅសាកសពក្រោយគុកទួលស្លែងៈ កិច្ចខំប្រឹងប្រែងរបស់គ្រួសារជនរងគ្រោះជនជាតិអាមេរិកាំង» ដែលបានសរសេរថា «បន្ទាប់មកក្រុមរបស់លោក ជ័យ សុភារ៉ា បានជីករណ្តៅមួយនៅខាងក្រោយរបងទួលស្លែង ព្រោះគាត់ត្រូវបានប្រាប់ដោយទាហានម្នាក់ដែលអះអាងថា ខ្លួនបានរួចផុតពីមន្ទីរស-២១ នៅក្រោយថ្ងៃរំដោះ ឆ្នាំ ១៩៧៩ ។» សូមកែមកជា «រណ្តៅមួយត្រូវបានជីកឡើងនៅក្រោយរបងទួលស្លែងដោយក្រុមអ្នកធាក់ស៊ីក្លូនិងកង់ឌុប តាមការចង្អុលបង្ហាញពីទាហានម្នាក់ដែលអះអាងថាខ្លួនជាជនរងគ្រោះ ហើយបានរួចផុតពីគុកស-២១នៅក្រោយថ្ងៃរំដោះឆ្នាំ១៩៧៩» និងទំព័រទី៥៥ កូឡោនទី២ ជួរទី២ ដែលបានសរសេរថា «ចាប់បានក្នុងឆ្នាំ១៩៧៦» សូមកែមកជា «ចាប់បានក្នុងឆ្នាំ១៩៧៨» វិញ ។ **ផេង ពង្សរ៉ាស៊ី**

# សមមិត្តគង់ ឬ សួង ស៊ីគៀន

## (កត់ត្រាតាមសំណៅដើមទាំងស្រុង)




**(តពីលេខមុន)** ដោយចង់ភ្ជាប់ខ្លួនទៅចលនាចំរើន ចលនាសង្គមនិយម ហើយចង់រៀនសូត្រទ្រឹស្តីម៉ាក្ស-ឡេនីន បានជានៅពាក់កណ្តាលឆ្នាំ១៩៥៦ ខ្ញុំសុំមិត្តខ្ទួល ចូលក្នុងក្រុមម៉ាក្សនិយមខ្មែរ ។ លើកទីមួយមិត្តខ្ទួលថាមិនដឹងទេ ហើយលើកទីពីរក៏គាត់ឆ្លើយដដែល ។ ប៉ុន្តែប៉ុន្មានថ្ងៃក្រោយមកបង អៀង សារី បានមកលេងនឹងខ្ញុំ សួរសុខទុក្ខ ហើយបានស្នើឲ្យខ្ញុំសរសេរអត្ថបទ «នាទីអន្តរជាតិ» សម្រាប់កាសែត «ឯកភាព» ដែលមាន ពីង សយ ជាចាងហ្វាងមួយរយៈ មក បង អៀង សារី បានប្រាប់ខ្ញុំឲ្យទៅប្រជុំនៅ ផ្ទះបង រ៉ាំ ពេលយប់ក្នុងឋានៈជា «ជនបង្គោល» ។ ពេលទៅដល់ផ្ទះបង រ៉ាំ ខ្ញុំឃើញមានឈ្មោះ នុត ប៉ាណារ៉ា តាក ហេង ហ៊ូ យន់ និង ម្ចាស់ផ្ទះ ។ ក្រុមយើងទាំង៥នាក់ក៏បានចូលរួមប្រជុំជាមួយគ្នារាល់អាទិត្យដោយមានឈ្មោះ ហ៊ូ យន់ ជាប្រធាន ហើយពេលខ្លះក៏មានបង អៀង សារី ចូលរួម ។ បន្ទាប់មកក្រុមនេះក៏បែកគ្នា ហើយខ្ញុំចូលមកប្រជុំនៅសាលាចំរើនវិជ្ជាវិញ ។ ក្រុមថ្មីរបស់ខ្ញុំមាន នុត ប៉ាណារ៉ា ស៊ាត ផៃ អា ម៉ែន សាន ដោយមានបង អៀង សារី ជាប្រធានប្រជុំ ។ ពេលនោះខ្ញុំទទួលភារកិច្ចទាក់ទងយកការណ៍ពីអាក្បត់ គាំ រេត ហើយរាយការណ៍ជូនបង អៀង សារី រាល់អាទិត្យ ។

ខ្ញុំបន្តបង្រៀននៅសាលាចំរើនវិជ្ជា និងបន្តរួមសកម្មភាពបដិវត្តន៍រហូតដល់ខ្ញុំទៅរៀននៅប្រទេសបារាំងនៅថ្ងៃ១៧ ខែតុលា ឆ្នាំ១៩៥៧ ។

ជាសរុបក្នុងរយៈកាល១៩៤៧-១៩៥២ ខ្ញុំចូលរួមសកម្មភាពក្នុងគណបក្សប្រជាធិបតេយ្យ ដោយម្យ៉ាងយល់ថាបក្សនេះជាអ្នកស្នេហាជាតិនិងអ្នកស្អាតស្អំ (ខ្ញុំគោរពស្រឡាញ់ យុត្តិវង្ស និង អ៊ីវ កើស) ម្យ៉ាងទៀតដោយយល់ថាបក្សនេះប្រឆាំងនឹងរាជាធិបតេយ្យដែលខ្ញុំស្អប់ខ្ពើម ព្រោះទទួលឥទ្ធិពលនៃការអប់រំអាណានិគមនិយមបារាំង ពីបដិវត្តន៍នាយទុនបារាំងឆ្នាំ១៧៨៩ (ខ្ញុំគោរពស្រឡាញ់ ហើយយក រ៉ូបែសពីយ៉ា ជាគំរូ) ។ មូលហេតុទាំងពីរខាងលើនេះនាំឲ្យខ្ញុំមានសមានចិត្តនិងរួមសកម្មភាពជាមួយអា សឺង ង៉ុកថាញ់ ពីឆ្នាំ១៩៥២ ដល់ឆ្នាំ១៩៥៥ ។ មូលហេតុមួយទៀតគឺខ្ញុំយល់ច្រឡំថាក្រុមនេះជាក្រុមម៉ាក្សនិយម តែជាតិនិយមចង់ឲ្យប្រទេសយើងទៅសង្គមនិយមដែរ តែឯករាជ្យពីយួន ។ តែដល់ប្រាស្រ័យទាក់ទងជាមួយពួកអានេះ ខ្ញុំឃើញវាវាយបំបែកផ្ទៃក្នុងជាតិឯង




វាយប្រហារពួកបញ្ញាជនចំរើន និងក្រុមប្រជាជន ហើយមិនវាយចក្រពត្តិអាមេរិកដោយយកលេសថា បើវាយអាមេរិកខ្លាចបែរទៅជួយសង្គមរាស្ត្រនិយមវិញ ។ ម្យ៉ាងទៀតដោយឃើញថាអ្នកដឹកនាំក្រុមនេះគ្មានសមត្ថភាព (អា ហង់ ធុនហាក់ និង អា គាំ រេត) និងពាលាអាវ៉ាសែ ។

**ឥទ្ធិពលនៃក្រុមអាក្បត់នេះមកលើខ្លួនខ្ញុំ គឺបញ្ហាបុគ្គល**

ក្នុងការអប់រំវាលើកបុគ្គលអ្នកដឹកនាំ ពិសេសអា សឹង ង៉ុកថាញ់ បន្ទាប់មកអា អ៊ា ស៊ីចូវ ដូចជាព្រះឲ្យឃើញស្នាដៃបុគ្គលពួកវាមិនដែលនិយាយពីមហាជន ពីវីរភាពរបស់មហាជនប្រជាជនឡើយវា ឃើញតែបុគ្គលឬក្រុមតូចៗដែលអាចធ្វើការមានប្រសិទ្ធភាព ។ នេះជាទស្សនៈរបៀបហ្វាស៊ីសមើលងាយមហាជន ប្រជាជន ។

**មូលហេតុដែលឲ្យខ្ញុំបែរមករកពួកចំរើនវិញៈ**

គឺឃើញថាអ្នកចំរើនមានទស្សនៈទូលាយ វិភាគសភាពការណ៍ច្បាស់លាស់មិនថាម្តងអញ្ចេះ ម្តងអញ្ចុះ ដូចអាពួក សឹង ង៉ុកថាញ់ទេ ។ ហើយចំពោះបញ្ហាសាមគ្គីភាពក្នុងប្រជាជាតិក៏រកឃើញអ្នកចំរើនមានទស្សនៈទូលាយ មិនចង្អៀតចង្អល់ មានមាគ៌ាជាយុទ្ធវិធីប្រមូលកម្លាំងឲ្យបានច្រើនជាអតិបរមា បែងចែកកម្លាំងខ្មាំង ហើយវាយខ្មាំងមិនត្រូវប៉ះតណាប៉ះតណី ទាំងក្នុងប្រទេសទាំងក្រៅប្រទេស ។ អ្នកចំរើនបានឃើញគ្រោះអាសន្ននៃចក្រពត្តិអាមេរិកដែលត្រូវតែប្រមូលប្រជាជាតិទាំងមូលដើម្បីទប់ទល់ ។ ឯពួកអាប្រជាចលនាវិញ វាមិនដែលថាសហរដ្ឋអាមេរិកជាគ្រោះថ្នាក់ដល់ប្រជាជាតិយើងទេ ។ វាយកបញ្ហារបបគ្រប់គ្រងប្រទេសរាជាណាចក្រ ឬសាធារណរដ្ឋ មកធ្វើជាកម្មវត្ថុឃោសនារបស់វា ។ មួយវិញទៀត វាប្រមាថមើលងាយប្រជាជនយើងពិសេសកសិករក្រីក្រ ថាមិនងាយភ្ញាក់រលឹកទេ ឲ្យ សីហនុ អូសទាញបាន ។ ក្រៅពីនេះពួកវាហ្វាស៊ីសណាស់ អ្នកណាមានមតិមិនដូចវា វាដាក់ផ្លាកថាជាខ្ញុំកញ្ជះយួនភ្លាម ។

**រយៈកាលស្នាក់អាស្រ័យនៅប្រទេសបារាំង**

**(ថ្ងៃ១៧ ខែ១០ ឆ្នាំ១៩៥៧-ថ្ងៃ១៥ ខែ៥ ឆ្នាំ១៩៧០)**

នៅថ្ងៃ១៧ ខែតុលា ឆ្នាំ១៩៥៧ ខ្ញុំបានទទួលអាហារូបករណ៍ទៅរៀនវិជ្ជាបច្ចេកទេសទូរគមនាគមន៍ខាងយន្តហោះនៅទីក្រុងប៉ារីស ដោយការជ្រោមជ្រែងរបស់ឪពុកមាខ្ញុំម្នាក់ឈ្មោះ អ៊ុល ចុន ដែលពេលនោះរស់នៅទីស្នាក់ការសមាគមសិស្សចាស់ជាមួយខ្ញុំ ។

គោលបំណងខ្ញុំទៅនេះគឺដើម្បីចង់រៀនសូត្រពីទ្រឹស្តីម៉ាក្ស-ឡេនីន និងស្គាល់ចលនាបដិវត្តនិងកុម្មុយនិស្តនៅអឺរ៉ុប ពិសេសនៅប្រទេសបារាំង ។ ខ្ញុំក៏ចង់ស្គាល់និងចូលរួមសកម្មភាពជាមួយនិស្សិតនិងបញ្ញាជនម៉ាក្សនិយមកម្ពុជានៅប្រទេសបារាំងដែរ ។

ឈ្មោះ អ៊ុល ចុន បានចេញមុខរកលុយកាត់ទិញខោអាវឲ្យខ្ញុំទៅប្រទេសបារាំងបាន ។ មុននឹងចេញដំណើរ បង អៀង សារី បានហៅនិស្សិតដែលត្រូវទៅរៀននៅប្រទេសបារាំងទៅលេងផ្ទះគាត់ដើម្បីគាត់ណែនាំនិងផ្តាំផ្ញើពីបញ្ហារស់នៅ បញ្ហាទិសដៅដែលយើងខ្ញុំទៅបន្តវិជ្ជានេះ ព្រមទាំងបញ្ហារួមកម្លាំងនិស្សិតស្នេហាជាតិទាំងអស់ប្រឆាំងនឹងចក្រពត្តិអាមេរិកនិងបរិវាររវា ។ បន្ទាប់មកក៏មានរៀបចំជប់លៀងស្និទ្ធស្នាលដោយមានបង សុន សេន ចូលរួមដង ។ ឈ្មោះ ហ៊ូ យន់ បានឲ្យលុយខ្ញុំ ៥០០រៀលដែរ ។

ថ្ងៃចេញទៅ បង អៀង សារី បានប្រគល់ឯកសារសម្ងាត់មួយ ហើយបានផ្តាំខ្ញុំឲ្យយកប្រគល់ផ្ទាល់ដៃដល់បង ខៀវ សំផន នៅប៉ារីស ។ សំបុត្រនេះខ្ញុំបានយកប្រគល់ទៅឲ្យបង ខៀវ សំផន ផ្ទាល់ដៃនៅមន្ទីរពេទ្យបូរីអន្តរជាតិក្រុងប៉ារីស ដែលគាត់ទៅសម្រាកមួយថ្ងៃក្រោយខ្ញុំទៅដល់ប្រទេសបារាំង ។ ពីរ-បីថ្ងៃក្រោយមកបង ខៀវ សំផន បានប្រាប់ខ្ញុំថា តាមសំណូមពររបស់ខ្ញុំ ខ្ញុំត្រូវបានទទួលជាសមាជិក «វង្សម៉ាក្ស-ឡេនីន និយម» នៅប្រទេសបារាំង ។ ពេលនោះវង្សនេះមាន «គុរ» មួយដឹកនាំ ដែលមានសមាសភាពដូចតទៅ÷

ខៀវ សំផន ជួន មុម្ម អ៊ិន សំបុក អ៊ិន សូកាន (នៅធ្វើការក្រុងឡឺហាវ) ។ ជាមួយនេះខ្ញុំក៏បានចូលជាសមាជិកសកម្មនៃសមាគម «សហភាពនិស្សិតខ្មែរ» ។ ភារកិច្ចរបស់ខ្ញុំគឺឃោសនាកៀងគរនិស្សិតនិងកម្មសិក្សាការីកម្ពុជាឲ្យឃើញគ្រោះអាសន្ននៃចក្រពត្តិអាមេរិកនិងពួកប្រតិកិរិយាក្នុងប្រទេសជាដៃជើងវាមាន អា សម សារី មៅ សាយ លន់ ណុល ញឹក ជូឡុង ព្រមជាមួយនេះធ្វើយ៉ាងណាឲ្យគេទាំងឡាយចូលរួមសកម្មភាព ឬចូលជាសមាជិក «សហភាពនិស្សិតខ្មែរ» ។

នៅឆ្នាំ១៩៥៨ ខ្ញុំបានចូលជាសមាជិក «ក្រុមភាសា» នៃបក្សកុម្មុយនិស្តបារាំង ។ ក្នុងឆ្នាំដដែលនេះ ខ្ញុំបានប្រឡងជាប់បាសូទី២ នៅប៉ារីស ។ ក្នុងឱកាសនោះវង្សម៉ាក្ស-ឡេនីនបានលើកទឹកចិត្តខ្ញុំយ៉ាងខ្លាំង ។

ចុងឆ្នាំ១៩៥៨ បង ខៀវ សំផន ក៏អញ្ជើញត្រឡប់មក

ប្រទេសវិញ ហើយ ជួន មុម្ម បានឡើងជាអ្នកទទួលខុសត្រូវទូទៅនៃ «វង្សម៉ាក្ស-ឡេនីន» នៅប្រទេសបារាំង ។

ក្នុងឆ្នាំ១៩៥៧ និង ឆ្នាំ១៩៥៨ ខ្ញុំទទួលឥទ្ធិពលពីការអប់រំរបស់បង ខៀវ សំផន ច្រើនព្រោះគាត់យកចិត្តទុកដាក់អប់រំខ្ញុំផ្ទាល់ ។ ខ្ញុំបានរៀនសូត្រពីគាត់នូវស្មារតីលះបង់ទ្រាំទ្រការលំបាកឈឺចាប់ ដើម្បីបំពេញភារកិច្ចនូវមាគ៌ាមហាជនស្រឡាញ់រាប់អាននិងដាក់ខ្លួនក្នុងមហាជន ។

◆ក្នុងរយៈពេលដដែលនេះ ខ្ញុំក៏បានរួមចំណែកសរសេរនិងបោះពុម្ពផ្សាយទស្សនាវដ្ដីសម្ងាត់ «រស្មី» ។

◆នៅឆ្នាំ១៩៥៩ ក្រោយពី អ៊ិន សូកាន ត្រឡប់មកប្រទេសវិញខ្ញុំបានត្រូវ «វង្សម៉ាក្ស-ឡេនីន ជ្រើសរើសជាសមាជិកគុរ ជាមួយ ជួន មុម្ម, ទុន ជោតិស៊ីរិន និងអា គួចខាំឌឿន ។

នៅពេលនោះឥទ្ធិពលសេរីរើបានចាប់ផ្ដើមមានមកលើ «វង្សម៉ាក្ស ឡេនីន» ដោយបក្សបារាំងបានផ្សព្វផ្សាយឯកសារស្ដីពីមហាសន្និបាតលើកទី២០នៃបក្សកុម្មុយនិស្តសូវៀត ។ វង្សទាំងមូលទទួលយល់ព្រមតាមសេចក្ដីសន្និដ្ឋាននៃមហាសន្និបាតនេះទាំងស្រុង ។ ហើយជាបណ្ដើរៗ ស្មារតីអន្តរជាតិនិយមឥតព្រំដែនដែលតម្កល់សហភាពសូវៀតជាមេដឹកនាំបដិវត្តន៍សកលលោកបានចូលជ្រាបនិងពង្រឹងក្នុងខ្លួនខ្ញុំផ្ទាល់ក៏ដូចក្នុងវង្សទាំងមូល ។ ដូចបក្សសេរីរើឯទៀត ខ្ញុំយល់តាមរូបមន្តរបស់ហ្សាក់ឌុយក្លូ ដែលថាៈ បើប្រឆាំងសូវៀតគឺប្រឆាំងកុម្មុយនិស្ត» ។

ឆ្នាំ១៩៥៩ដដែលនេះ ខ្ញុំបានទៅចូលរួម «មហាមហោស្រព សាកលរបស់យុវជននិងនិស្សិត» នៅទីក្រុងវីយែនប្រទេសអូទ្រីស ដោយមាន អ៊ិន សូកាន ជាអ្នកដឹកនាំ ។ ពេលនោះក៏មានប្រតិភូយុវជនសង្គមរាស្ត្រនិយមដឹកនាំដោយ យឹម ឌិត ទៅចូលរួមដែរ ។ ប្រតិភូ «សហភាពនិស្សិតខ្មែរ» និងប្រតិភូ«យុវជនសង្គមរាស្ត្រនិយមបានចូលគ្នាជាគណៈប្រតិភូកម្ពុជាតែមួយដឹកនាំដោយ យឹម ឌិត ដោយមាន អ៊ិន សូកាន ជាទីប្រឹក្សា ។

ក្រោយពីមហោស្រពនេះ អ៊ិន សូកាន និងខ្ញុំក៏បានទៅចូលរួមមហាសន្និបាតនៃ «សហភាពអន្តរជាតិ» នៅទីក្រុងប្រាកប្រទេសឆេកូស្លូវ៉ាគី ។ នៅឱកាសនោះទំនាស់រវាងចិននិងពួកសេរីរើចាប់ផ្ដើមខ្លះៗហើយ ។ ឧទាហរណ៍ប្រតិភូចិនប្រឆាំងមិនឲ្យប្រើពាក្យ «ផ្លូវតាមសន្តិវិធី» ជាដើមឯកសារ ។ ពេលនោះយើងខ្ញុំក៏បានជួបគណៈប្រតិភូចិនដែរ និយាយច្រើនអំពីមិត្តភាពនិងសាមគ្គីភាពរវាងប្រជាជនទាំងពីរ ។ ប្រតិភូចិនច្រើនប្រហារថ្កោលទោសចក្រពត្តិអាមេរិក និងពួកសេរីរើយូហ្គោស្លាវី ។ ប៉ុន្តែនិន្នាការសេរីរើដែលបោះទីតាំងនៅក្នុង «វង្សម៉ាក្ស-ឡេនីន» ច្បាស់លាស់គឺនៅឆ្នាំ១៩៦០ ក្រោយពីសន្និសីទសកលលោកនៃបក្សកុម្មុយនិស្តនិងបក្សពលករចំនួន៨១នៅម៉ូស្គូ ។ «វង្ស» បានបើវគ្គរៀនសូត្រឯកសារជាសេចក្ដីថ្លែងការណ៍នៃសន្និសីទនេះហើយបានឯកភាពទាំងស្រុងជាមួយខ្លឹមសារនៃសេចក្ដីថ្លែងការណ៍នេះពិសេសលើបញ្ហា «ប្រជាធិបតេយ្យជាតិ» នៅប្រទេសតតិយលោក ។

ចាប់ពីពេលនោះមក ទស្សនៈនិងគោលជំហរសេរីរើបានចូលជ្រាបហើយប្រែក្លាយទៅជាសកម្មភាពជាក់ស្ដែងរបស់ខ្ញុំក្នុងរយៈពេលនោះ ។ ទស្សនៈនិងគោលជំហរប្រឆាំងបដិវត្តន៍នេះគឺ÷

ទី១ៈ បដិវត្តន៍វណ្ណៈអធនអាចឈ្នះដោយមិនចាំបាច់ប្រើហិង្សាអាវុធ ។ ឧទាហរណ៍នៅឆេកូស្លូវ៉ាគីនាឆ្នាំ១៩៥៨ បក្សកុម្មុយនិស្តរឹបយកអំណាចតាមការបោះឆ្នោតបានដោយមានកម្លាំងសង្គមនិយមសកលលោកនានាកុំឲ្យចក្រពត្តិនិយមអន្តរជាតិធ្វើអន្តរាគមន៍ ពេលនោះកងទ័ពសូវៀតនៅបោះក្នុងប្រទេសឆេកូស្លូវ៉ាគី ។

ទី២ៈ ក្នុងរយៈកាលឆ្លងកាត់ ពិសេសនៅប្រទេសតតិយ-លោក បក្សវណ្ណៈអធនអាចទុកឲ្យនាយទុនជាតិដឹកនាំបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ឬមួយបក្សវណ្ណៈអធនអាចរំលែកការដឹកនាំជាមួយនាយទុនជាតិ ។ ហើយផ្លូវដើម្បីសម្រេចជ័យជំនះបដិវត្តន៍សង្គមនិយមអាចធ្វើទៅតាមសភាដោយសន្តិវិធី ។

ទី៣ៈ ទ្រឹស្ដីអធិបតេយ្យភាពមានកម្រិតចលនាកុម្មុយនិស្តនិយមអន្តរជាតិ ជាចលនាឯកភាពជាធ្លុងមួយដែលមានសហភាពសូវៀតជាមេដឹកនាំ ។ បដិវត្តន៍ក្នុងប្រទេសនីមួយៗត្រូវប្រព្រឹត្តឡើងឲ្យសមស្របតាមផលប្រយោជន៍ទូទៅនៃចលនាកុម្មុយនិស្តអន្តរជាតិ ។ ឧទាហរណ៍ នៅសន្និសីទហ្សឺណែវឆ្នាំ១៩៥៤ សភាពការណ៍អន្តរជាតិ និងផលប្រយោជន៍ចលនាកុម្មុយនិស្ត

អន្តរជាតិតម្រូវឲ្យឈប់ច្បាំង ។ ដូច្នោះ បក្សនៅប្រទេសនីមួយៗ ដែលដឹកនាំការតស៊ូ ត្រូវស្តាប់តាមបក្សកុម្មុយនិស្តសូវៀត ។

ជាសកម្មភាពជាក់ស្តែង ខ្ញុំបានចេញមុខឃោសនាគាំទ្រទស្សនៈនិងគោលជំហរសេរីវេនិយមសូវៀត ពិសេសការរួមរស់ដោយសន្តិភាព ការប្រកួតប្រជែងខាងសេដ្ឋកិច្ចជាមួយលោកនាយទុន សង្គ្រាមសកលលោកម្តងទៀតគឺវិនាសអន្តរាយដល់មនុស្សជាតិទាំងអស់មិនមែនអន្តរាយតែចំពោះប្រទេសនាយទុនប៉ុណ្ណោះទេ ។ ព្រមជាមួយគ្នានេះខ្ញុំក៏បានចេញមុខឃោសនាប្រឆាំងនឹងចិនក្នុងបញ្ហាជម្លោះជាមួយសេរីវេសូវៀត ។ ម្យ៉ាងទៀតក្នុងរយៈកាលដដែលនោះសង្គ្រាមនៅវៀតណាមបានចាប់ផ្តើម ហើយម៉ាស៊ីនឃោសនារបស់សម្ព័ន្ធសេរីអន្តរជាតិបានលើកការតស៊ូប្រជាជនវៀតណាមឡើងខ្ពស់ត្រដែតទុកជាគំរូសម្រាប់ប្រជាជនសកលលោក ។ «វង្សម៉ាក្ស-ឡេនីន» និងខ្លួនខ្ញុំក៏លង់ទៅតាមចរន្តឃោសនានេះ យកការតស៊ូប្រជាជនវៀតណាមជាមេរៀនសម្រាប់ខ្លួនផ្ទាល់ ។ ក្នុងទំនាស់ចិន-សូវៀត «វង្ស» និងខ្លួនខ្ញុំផ្ទាល់តែងតែថា អាកប្បកិរិយានិងគោលជំហរ «អព្យាក្រឹត» របស់បក្សវៀតណាមគឺត្រឹមត្រូវ ។

ក្រោយពី «វិបត្តិកាំជ្រួច» នៅគុយបាក្នុងឆ្នាំ១៩៦២ ទំនាស់ចិន-សូវៀត បានផ្ទុះឡើងជាសាធារណៈ ហើយពេលនោះ «វង្សម៉ាក្ស-ឡេនីន» យកអាកប្បកិរិយាកាន់ជើងសេរីវេសូវៀត ។

នៅឆ្នាំដដែល ខ្ញុំត្រូវ «ម៉ាក្ស-ឡេនីន» ប្រគល់ភារកិច្ចទទួលខុសត្រូវគណៈប្រតិភូ «សហភាពនិស្សិតខ្មែរ» ដែលបានទៅចូលរួម «មហាមហោស្រពសកលលោកនៃយុវជននិងនិស្សិត» នៅក្រុងហែលស៊ីនគី ប្រទេសហ្វាំងឡង់ ។ ក្រោយពីមហាមហោស្រពខ្ញុំបានទៅចូលរួមមហាសន្និបាតនៃ «សហព័ន្ធសកលលោកនៃយុវជនប្រជាធិបតេយ្យ» នៅក្នុងវ៉ាសូវី ប្រទេសប៉ូឡូញ ។ ក្នុងឱកាសនោះ ក្នុងសុន្ទរកថារបស់គណៈប្រតិភូនិស្សិតកម្ពុជាមានដាក់ឃ្លាមួយដែលបញ្ចាំងនូវទស្សនៈសេរីវេដែលទាក់ទិននឹងបញ្ហាកម្ពុជា «ពិសោធន៍នៅកម្ពុជាបង្ហាញថា ការរួមរស់ដោយសន្តិភាពអនុគ្រោះដល់ការតស៊ូរបស់ប្រជាជនប្រឆាំងអំពើជ្រៀតជ្រែកវិទ្ធង្សនា និងឈ្លានពានរបស់ចក្រពត្តិអាមេរិកនិងបរិវារ ដើម្បីឯករាជ្យ សន្តិភាព អព្យាក្រឹត និងដើម្បីកែប្រែជីវភាពប្រជាជន» ។

នៅឆ្នាំ១៩៦៣-១៩៦៤ និងនៅឆ្នាំបន្ទាប់ៗមក ខ្លួនខ្ញុំលង់លិចក្នុងភក់ជ្រាំសេរីវេរហូតដល់ស្នើឲ្យ «វង្សម៉ាក្ស-ឡេនីន» ផ្ញើសំបុត្រទៅបក្សកុម្មុយនិស្តសូវៀតគាំទ្រជំហរសូវៀតប្រឆាំងនឹងចិន ។ តែសេចក្តីស្នើត្រូវសមាជិក «វង្ស» ភាគច្រើនមិនយល់តាម ។ ទស្សនៈនិងគោលជំហរសេរីវេ ខ្ញុំរក្សាជាមូលដ្ឋានរហូតដល់ខែ៩ ឆ្នាំ១៩៧១ ពេលដែលខ្ញុំបានជួបបង អៀង សារី តំណាងបក្សកុម្មុយនិស្តកម្ពុជា នៅប៉េកាំង ។

នៅឆ្នាំ១៩៦៦ ដោយមានទំនាស់ជាបុគ្គលផង ជាមាគ៌ាដំណើរការក្នុង «វង្សម៉ាក្ស-ឡេនីន» ខ្ញុំបានសុំលាចេញពីសមាជិក «គុរ» ។ ដូច្នេះសមាជិកគុរមានតែ ជួន មុម្ម ទុនជោតិ ស៊ីរិន និងអា គួច ខាំខឿន ។ ទំនាស់នេះមិនមែនទំនាស់ជាទស្សនៈឬទំនាស់ជាគោលជំហរទេ ព្រោះជារួម «វង្សម៉ាក្ស-ឡេនីន» នៅប្រទេសបារាំងធ្លាក់ទៅសេរីវេមួយរយភាគរយទៅហើយ ។ ទំនាស់ខ្លាំងគឺត្រង់ខ្ញុំមិនឯកភាពលើអាកប្បកិរិយាសម្រុះសម្រួលរបស់ ជួន មុម្ម ដែលមិនមានយកវិធានការអ្វីបន្តិចបន្តួចសោះចំពោះអំពើប្រព្រឹត្តរំលោភលើលក្ខការណ៍ចាត់តាំងរបស់«វង្ស» ។ ឧទាហរណ៍ ទុនជោតិ ស៊ីរិន ដោយគ្មានបានប្រាប់ គុរ ចូលធ្វើការក្នុង «វិទ្យាស្ថានស្រាវជ្រាវ» របស់បារាំងពេលដែលខ្លួននៅសម្រាកពេទ្យនៅតំបន់ខាងត្បូងប្រទេសបារាំងនៅឆ្នាំ១៩៦៥ ។ អា គួច ខាំខឿន ដោយយកនាទីវាជាប្រធាន «សហភាពនិស្សិតខ្មែរ» បានបញ្ចូលសមាគមនេះជាសមាជិក «សហភាពអន្តរជាតិនិស្សិត» ពេលមហាសន្និបាតអគ្គការនេះនៅម៉ូស្គូក្នុងឆ្នាំ១៩៦២ ដោយគ្មានការសម្រេចជាសមូហភាព ។

ក្នុងរយៈកាលនោះ តើទស្សនៈគោលជំហរនិងអាកប្បកិរិយាខ្ញុំចំពោះការតស៊ូរបស់ប្រជាជនយើងក្រោមការដឹកនាំរបស់បក្សកុម្មុយនិស្តកម្ពុជាយ៉ាងណា?

ខ្ញុំសូមចែកជាបីរយៈកាល ពីឆ្នាំ១៩៥៨ មកដល់ឆ្នាំ១៩៧០ ។ ខ្ញុំសូមបញ្ជាក់ថាតាំងពីចូលជាសមាជិក «អង្គការបង្គោល» នៅឆ្នាំ១៩៥៦មក ខ្ញុំដាក់ខ្លួនបម្រើចលនាតស៊ូរបស់ប្រជាជនកម្ពុជាក្រោមការដឹកនាំរបស់បក្ស ពេលនោះខ្ញុំមិនទាន់ដឹងថាមានបក្សទេ ខ្ញុំគ្រាន់តែដឹងថាមានស្នូលដឹកនាំ ។

**(នៅមានត)**

# សោកនាដកម្មនៅភូមិកោះផល

(តពីលេខមុន)



**លោក សេន សុះ អាយុ៦៩ឆ្នាំ រស់នៅភូមិកោះផល**

ខ្ញុំមានដើមកំណើតនៅក្នុងភូមិកោះផល ។ ក្រោយមកខ្ញុំក៏ទៅរស់នៅជាមួយប្រពន្ធខ្ញុំនៅភូមិទ្រា ។ ប្រហែលនៅខែកក្កដា ឆ្នាំ១៩៧៥ ខ្ញុំក៏ដូចកម្មករចម្ការកៅស៊ូដទៃទៀតដែរ ត្រូវបានជម្លៀសចេញពីភូមិទ្រា ។ កាលនោះខ្ញុំបានទៅដល់ភូមិតាប៉ាវ ។ ពីរ-បីឆ្នាំក្រោយមកខ្ញុំបានព្យួសំឡេងគ្រាប់ផ្លោងពីភូមិកោះផល ។ ពេលនោះខ្ញុំត្រូវបានពួកកម្មាភិបាលខ្មែរក្រហមចាត់តាំងឲ្យទៅរកត្រីនៅបឹងមួយក្នុងភូមិតាប៉ាវ ។ ត្រីនៅក្នុងបឹងនោះចេះតែខ្សត់ទៅៗ ដូច្នេះពួកវាក៏ឲ្យខ្ញុំទៅចាប់ត្រីនៅភូមិកោះផលនាដើមឆ្នាំ ១៩៧៦ ។ ក្រុមរកត្រីរបស់ខ្ញុំមានគ្នា៦នាក់ ជនជាតិចាម៣នាក់ និងខ្មែរ៣នាក់ ។ ខ្ញុំនៅចាំតែឈ្មោះម្នាក់ប៉ុណ្ណោះដែលជាប្រធានរបស់ខ្ញុំគឺគាត់ឈ្មោះ នុត ។ ឥឡូវនេះឈ្មោះ នុត នេះរស់នៅផ្សារប៉ើស ។

ពួកទាហានខ្មែរក្រហមមួយក្រុមដែលខ្ញុំមិនចាំឈ្មោះនិងមុខមាត់ បានបញ្ជាឲ្យក្រុមរកត្រីរបស់ខ្ញុំនៅត្រឹមតែមាត់បឹងតែប៉ុណ្ណោះ បើអ្នកណាហ៊ានតែឈានតែពីរ-បីម៉ែត្រពីកោះនោះនឹងត្រូវវាបាញ់សម្លាប់ចោល ។ ពេលរកត្រីបានហើយមានក្រុមប្រមូលត្រីមកយកពីយើងទៀត ។ យើងភ្លេចឈ្មោះអ្នកទាំងនោះអស់ហើយ ។ កាលនោះយើងមានហូបគ្រប់គ្រាន់ ។ យើងមានអង្ករខ្សាយនិងអង្ករដំណើបសម្រាប់ធ្វើបង្អែម និងសាច់ ជាពិសេសយើងមានត្រីធំៗហូប ព្រោះយើងជាអ្នករកត្រីស្រាប់ ។

រៀងរាល់ពីរ-បីថ្ងៃម្តង នៅវេលាម៉ោងប្រហែល២ឬ៣ តែងតែមានកប៉ាល់ធំមួយដឹកមនុស្សពេញប្រហែលជា១០០០នាក់ទៅកាន់កោះផល ។ ខ្ញុំនៅចម្ងាយប្រហែលជា ១៥០ម៉ែត្រ ពីកប៉ាល់នោះប៉ុណ្ណោះ ។ ប្រជាជននៅលើកប៉ាល់នោះមានយកបង្វេចមកតាមខ្លួនផង រួមមានចម្រុះទាំងចាស់ក្មេងប្រុសស្រី ទាំងជនជាតិចាម ទាំងជនជាតិខ្មែរ ចិនក៏មានដែរ ។ ខ្ញុំដឹងថាមានជនជាតិចាម ពីព្រោះគាត់មានពាក់មួកកន្ទុបនិងអាវដៃវែង ។ នៅម៉ោងប្រហែលជា៨ព្រឹក ខ្ញុំឮអ្នកខ្លះយំ អ្នកខ្លះស្រែក ហើយមានសម្រែកទាំងក្មេងទាំងចាស់ ។ សម្លេងស្រែកនេះខ្ញុំឮចេញពីកន្លែងដែលមានរណ្តៅសាកសពចំនួន៤៩ ។ បានជាខ្ញុំដឹងព្រោះក្រោយឆ្នាំ១៩៧៩ ខ្ញុំបានទៅកាន់ទីនោះហើយបានមើលឃើញនឹងភ្នែកទៀតផង ។

កាលនោះខ្ញុំនៅកោះផលនោះបាន៣ខែ រួចមកគេបានបញ្ជូនមកកាន់ភូមិតាប៉ាវដែលនៅក្នុងភូមិនោះខ្ញុំធ្វើជាជាងជួសជុលកង់ ។ នៅក្នុងភូមិនោះខ្ញុំបានដឹងថា អ្នកដែលស្រែកឈឺចាប់នោះគឺច្បាស់ជាស្លាប់ហើយរួមទាំងតា ហាក់ ផង ។ គាត់ត្រូវបានគេចោទប្រកាន់ថាបានលួចពងទា ហើយវាយគោពេលណាគាត់ខឹងនឹងអង្គការ ។ តា ហាក់ ក៏ជាចាមម្នាក់ដែរដែលត្រូវបានសម្លាប់នៅក្នុងឆ្នាំ១៩៧៦ ហើយទម្លាក់ចូលទៅក្នុងអណ្តូងនៅក្នុងភូមិតាប៉ាវតែម្តង ។ បានជាខ្ញុំដឹងរឿងពីព្រោះខ្ញុំបានឃើញសារុងនិងស្បែកជើងរបស់គាត់នៅទីនោះ ។ ខ្ញុំស្គាល់សារុងនិងស្បែកជើងនោះគឺជារបស់តា ហាក់ ។

ខ្ញុំបានឃើញឃ្លាំងទុកកាំភ្លើងចំនួន៣ តែមិនទាន់បានសង់រួចស្រេចបាច់នៅឡើយទេ ។ ឃ្លាំងនីមួយៗមានទទឹងប្រហែល ១០ម៉ែត្រនិងបណ្តោយប្រមាណ២០ម៉ែត្រ ។ ខ្ញុំដឹងពីព្រោះខ្ញុំបានឃើញពួកកម្មាភិបាលខ្មែរក្រហមដឹកគ្រាប់និងកាំភ្លើងមកកាន់

កោះផលនោះ ។ នៅក្នុងឆ្នាំ១៩៧៩ ពេលដែលខ្ញុំចូលមកកាន់កោះផលខ្ញុំឃើញតែឃ្លាំងទទេប៉ុណ្ណោះ ។ ផ្នូរទាំង៤៩វាមិនទាន់កប់ឡើយ ។ ខ្ញុំឃើញឆ្អឹងលលាដ៍ក្បាលនិងឆ្អឹងដៃឆ្អឹងជើងជាច្រើន ។ ក្រោយមកផ្នូរទាំងនោះក៏រលុបជាបណ្តើរៗ ។

### លោក ហ្សីប មេឃុំ១ ភូមិកោះផល

នៅក្នុងភូមិកោះផលមានរណ្តៅសាកសពជនរងគ្រោះស្លាប់ដោយសារពួកខ្មែរក្រហមចំនួន៤៩ ។ មកដល់ឥឡូវមិនទាន់មានអ្នកណាជីករណ្តៅនោះនៅឡើយទេ ។ រណ្តៅនីមួយៗមានទទឹងប្រហែល២ម៉ែត្រនិងបណ្តោយប្រហែលជា៥ម៉ែត្រ ហើយមានជម្រៅពី២,៥ ទៅ៣ម៉ែត្រ ។

### លោក ម៉ាត់ អេល អាយុ២៦ឆ្នាំ រស់នៅភូមិកោះផល

មានប្រជាជនចាមជាច្រើនស្លាប់ដោយសារជំងឺគ្រុនចាញ់ពោលគឺមាន២២០នាក់ស្លាប់ក្នុងភូមិផ្កាដូង ៤៤នាក់ក្នុងភូមិក្របីក្រៀក ៦៦នាក់ក្នុងភូមិប្រវាក់ដែក និង៦៧នាក់ក្នុងភូមិបារាយណ៍ ។ ប្រជាជនទាំងនោះត្រូវបានចាត់ជាច្រើនពួកដែលពួកវាយល់ថាជាខ្មាំងរបស់ខ្លួន ។ ក្រុមទី១រួមមានអ្នកមានជាងគេ ហើយចេះដឹងខាងផ្នែកសាសនាច្រើន ។ ក្រុមនេះត្រូវបានបញ្ជូលទៅក្នុងភូមិផ្កាដូងដែលជាតំបន់ងាយទទួលរងនូវជំងឺគ្រុនចាញ់ ។ ក្រុមទី២បញ្ជូលក្នុងភូមិក្របីក្រៀក ក្រុមទី៣បញ្ជូលក្នុងភូមិប្រវាក់ដែក និងក្រុមទី៤បញ្ជូលក្នុងភូមិបារាយណ៍ ។ ក្រុមទី២សុទ្ធតែជាអ្នកដែលមិនសូវចេះអក្សរ ហើយក្រុមទី៣ជាអ្នកនេសាទត្រីហើយក្រីក្រ ។

ប្រជាជននៅភូមិទាំងបីនេះក្រោយមកក៏ត្រូវបញ្ជូនទៅកាន់ទីកន្លែងផ្សេងៗជាច្រើនដូចជាភូមិរំកិល ភូមិប៉ុន និងភូមិមួយទៀតដែលអ្នកភូមិហៅថា ភូមិវិហារខ្ពស់ ឬវិហារទាប ដែលស្ថិតនៅក្នុងឃុំសួង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។ ខ្ញុំបានទៅនៅឃុំសួង ។ ប្រជាជននៅក្នុងភូមិបារាយណ៍និងរំវេញគ្មានមានអ្នកណារស់ម្នាក់ទេ ។ ប្រជាជនក្នុងភូមិនេះស្លាប់ទាំងអស់ក្នុងសម័យជម្លៀស ។ នៅពេលធ្វើដំណើរត្រឡប់មកវិញយើងបានជួបប្រជាជនជាច្រើន ខ្លះមកពីភូមិនេះ ខ្លះមកពីភូមិនោះ លើកលែងតែភូមិទាំងពីរខាងលើនេះដែលមិនបានឃើញមកនឹងគេ ។ អ្នកស្រុកភូមិដែលជាជនជាតិខ្មែរបានប្រាប់យើងថា មានការរៀបចំពិធីជប់លៀងមួយយ៉ាងធំដោយមានការកាប់គោជងធ្វើឡើងសម្រាប់ជនជាតិចាម ក្រោយមកចាមទាំងនោះត្រូវបានគេប្រមូលដាក់ឡាន ហើយប្រជាជនទាំងអស់នោះបានបាត់ខ្លួនតាំងពីពេលនោះមកដល់ឥឡូវ ។

ក្នុងចំណោមអ្នកទាំងនោះខ្ញុំស្គាល់មួយចំនួនដែរ ព្រោះកាលណោះគេឲ្យខ្ញុំធ្វើការផោរជាមួយពួកខ្មែរក្រហម ហើយគេក៏ប្រាប់រឿងទាំងនេះទៅ ។ ខ្ញុំទទួលខុសត្រូវខាងចែកអង្ករ ។ នៅប្រហែលជាឆ្នាំ១៩៨០ ខ្ញុំបានដឹងថាមានរណ្តៅខ្មោចចំនួន៤៩តាមរយៈទាហានមួយក្រុម ។ មានទាហានចំនួនប្រហែល១០នាក់បានជីករណ្តៅទាំងនោះ ។ ទាហានទាំងនោះជាទាហានរបស់រដ្ឋាភិបាលមិនមែនខ្មែរក្រហមទេ ។ មុននឹងជីកទាហានទាំងនោះបានសុំការអនុញ្ញាតពីស្រុករួចហើយ ។ ពេលនោះគេឲ្យអ្នកភូមិចេញពីផ្ទះចំនួនមួយអាទិត្យ ។ ទាហានទាំងនោះមិនបានយកឆ្អឹងទៅជាមួយឡើយ ប្រហែលជាជីកដើម្បីរកមាសផងក៏មិនដឹង ។ ពេលដែលយើងចេញបានបីថ្ងៃ តា យ៉ាន ដែលជាគណៈស្រុកក្រូចឆ្មារ ក៏ឲ្យពួកយើងចូលមករស់នៅដូចដើមវិញ ។ សព្វថ្ងៃនេះ តា យ៉ាន រស់នៅភូមិចា ស្រុកដំបែ ខេត្តកំពង់ចាម ។ អភិបាលរងគឺឈ្មោះ តា សាមិន ដែលសព្វថ្ងៃនេះធ្វើជាប៉ូលិសនៅទីរួមខេត្តកំពង់ចាម ។ ក្រោយមកអាជ្ញាធរស្រុកក៏បានមកជីកយកឆ្អឹងអស់ពីររទេះគោទៅកាន់ទីស្នាក់ការស្រុកដើម្បីទុកឲ្យប្រជាជនមើល ។

### គេះ អេល អាយុ៦៦ឆ្នាំ នៅភូមិកោះផល

ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ខ្ញុំបានរស់នៅជាច្រើនកន្លែងណាស់ ។ ក្នុងចំណោមកន្លែងទាំងអស់ខ្ញុំនៅចាំថាបានរស់នៅភូមិរកាខ្នុរចំនួន៦ខែ ក្របីក្រៀក១ឆ្នាំ និងភូមិចុងអូរជាច្រើនខែ ។ ពេលនោះគឺគណៈភូមិឈ្មោះ មិល ដែលបានជម្លៀសខ្ញុំ «អ្នកទាំងអស់ចាកចេញឥឡូវនេះ» ។ ខ្ញុំមិនចង់ចាកចេញទេ ប៉ុន្តែខ្ញុំមិនហ៊ាននិយាយឡើយ ។ បើយើងហ៊ាននិយាយពួកវានឹងចាប់ចងយើងមិនខាន ។ ក្រោយពីការជម្លៀសមកគេឲ្យខ្ញុំភ្ជួរស្រែធ្វើស្រែ ដាំពោតនិងថ្នាំជក់ ។ អ្នកដែលបញ្ជាឲ្យខ្ញុំធ្វើការនេះគឺប្រធានភូមិឈ្មោះ នុត ឥឡូវនេះស្លាប់ហើយ ។ ខ្ញុំមិនដែលឃើញគេសម្លាប់មនុស្សដោយផ្ទាល់ភ្នែកឡើយ ។

### គេះ អេល អាយុ៦៧ឆ្នាំ នៅភូមិកោះផល

ខ្ញុំកើតនៅភូមិកោះផលនិងរស់នៅភូមិនេះរហូតដល់ថ្ងៃជម្លៀសឆ្នាំ១៩៧៥ ។ នៅឆ្នាំ១៩៧៩ខ្ញុំត្រឡប់មករស់នៅក្នុងភូមិនេះវិញ ។ ខ្មែរក្រហមបានកាន់កាប់កោះផលនេះនៅក្នុងឆ្នាំ១៩៧៣ ។ នៅឆ្នាំ១៩៧៥មានប្រជាជនចាមរស់នៅចំនួន ១៧០០នាក់ ។ នៅក្នុងឆ្នាំ១៩៧៩ នៅសល់តែ៣០០នាក់ ប៉ុណ្ណោះរួមទាំងក្មេងៗផង ។ នៅចុងឆ្នាំ១៩៧៥ ប្រជាជនរស់នៅភូមិកោះផលត្រូវបានជម្លៀសចេញពីព្រោះខ្លួនបានប្រឆាំងនឹងខ្មែរក្រហម ។ ប្រជាជនមួយចំនួនតូចត្រូវបានជម្លៀសទៅកាន់នៅទីនោះក៏មានប្រជាជនចាមខ្លះដែរដែលមកពីភូមិដំនីក ។ ប្រជាជននៅទីនោះទទួលរងនូវការធ្វើការហួសកម្លាំង និងកង្វះអាហារ ។ មួយរយៈក្រោយមក ប្រជាជននៅក្នុងភូមិក្របីក្រៀក និងផ្កាដូងត្រូវគេជម្លៀសទៅកាន់កន្លែងផ្សេងទៀត ហើយមានអ្នកខ្លះក៏រស់ ហើយក៏ត្រឡប់ទៅកាន់កោះផលវិញនៅឆ្នាំ ១៩៧៩ ។ ប៉ុន្តែក្នុងចំណោមភូមិទាំងបីនោះ គ្មានឃើញប្រជាជនណាម្នាក់ត្រឡប់មកវិញឡើយ ។ អ្នកស្រុកភូមិជនជាតិខ្មែរដែលមកមើលទីនេះបានប្រាប់ថា គ្មានចាមណាម្នាក់នៅរស់រានមាន


وَإِنْ عَاقَبْتُمْ فَعَاقِبُوا بِمِثْلِ مَا عُوقِبْتُم بِهِ ۖ وَلَئِن صَبَرْتُمْ لَهُوَ خَيْرٌ لِّلصَّابِرِينَ ﴿١٢٦﴾

ដកស្រង់ពីគម្ពីរគួរអាន ស៊ូរ៉ស់១៦ ចំណុច១២៦

*«ប្រសិនបើអ្នកដាក់ទណ្ឌកម្ម (សងសឹកសត្រូវរបស់អ្នក) ត្រូវដាក់ឲ្យស្មើនឹងទារុណកម្មដែលអ្នកបានទទួលរង ។ ប៉ុន្តែបើអ្នកអត់ធ្មត់នោះជាប្រការល្អប្រសើរ ។»* បកប្រែដោយៈ សឹម សុរិយ៉ា នាយករងទី២មជ្ឈមណ្ឌលឯកសារកម្ពុជា, ហាជី សុះកិរី ប្រធានគណៈដឹកនាំជាន់ខ្ពស់សាសនាអ៊ិស្លាមកម្ពុជានិងឯកឧត្តម ហ្សាក់គ្រីយ៉ា អាដាម អនុរដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា ។

**មតិបកស្រាយៈ** ដូចនេះសាសនាឥស្លាមពុំបានថែងហាមឃាត់មិនឲ្យសាសនិកធ្វើទណ្ឌកម្មឬ សងសឹកអ្នកដែលប្រព្រឹត្តបទល្មើសនោះឡើយ ។ ពាក្យថា «ស្មើគ្នានឹង» មានន័យថា ឲ្យសមស្របនឹងទង្វើដែលបានប្រព្រឹត្តនិងបានទទួលរង ។ ឧទាហរណ៍ថារងរបួសមួយកាំបិត ស្លាប់មួយនាក់ ត្រូវដាល់មួយដៃ ។ កាំបិតអាចតូច-ធំ ឬចាក់ចំកន្លែងខុសគ្នាមនុស្សត្រូវសម្លាប់សងសឹក អាចមានអាយុឬស្ថិតក្នុងប្រការសំខាន់ខុសពីមនុស្សដែលរងគ្រោះនោះ រីឯកម្លាំងដៃដាល់សងអាចធ្ងន់ ឬស្រាលជាងមុន ។ ក្នុងករណីអាចស្មើបានការសងសឹកឬការដាក់ទណ្ឌកម្មអាចធ្វើបានហើយមានយុត្តិធម៌ ។ បើមិនស្មើទេបណ្តាលឲ្យមានការសងសឹកទៅមកមិនចេះចប់ ។ ក្នុងសង្គមបច្ចុប្បន្នគឺមានតែតុលាការយុត្តិធម៌ទេទើបអាចដោះស្រាយបញ្ហានេះបាន ។ ក្នុងករណីដែលជនរងគ្រោះអត់ធ្មត់មិនតបតនោះនឹងបានទទួលកុសលផលបុណ្យមួយថ្មីយ៉ាងពេញលេញ មានន័យថា ជនរងគ្រោះនឹងត្រូវទូទាត់កុសលផលបុណ្យរបស់ខ្លួនទៅនឹងទណ្ឌកម្មដែលខ្លួនប្រព្រឹត្តតជនដៃដល់វិញ ។ ទណ្ឌកម្មនិងទារុណកម្មសុទ្ធតែជាអំពើបាបដូចគ្នា តែបើទណ្ឌកម្មសងទៅវិញ ស្មើទារុណកម្មនោះវាជាដំណោះស្រាយមួយមានតុល្យភាព មានន័យថា ជនរងគ្រោះបានសងសឹកហើយពុំបានខាតបង់ផលកុសលពីមុនមកឡើយ ។ **សឹម សុរិយ៉ា**

ខេត្តស្ទឹងត្រែង ប៉ុន្តែភាគច្រើនទៅកាន់ភូមិផ្កាដូង ក្របីក្រៀក ប្រវ៉ាក់ដែក បារាយណ៍ និងភូមិរំវេញ ។ ប្រជាជនចំនួន១០គ្រួសារ ក្រោយមកត្រូវបានជម្លៀសទៅកាន់តំបន់ក្រសាំងនិងសន្ទុក នៃខេត្តកំពង់ធំ និងទៅឃុំស្ងួន ស្រុកត្បូងឃ្មុំ ក្នុងខេត្តកំពង់ចាម ។ នៅភូមិទាំងប្រាំនេះជាតំបន់គ្រុនចាញ់មានព្រៃក្រាស់ ហើយមិនសូវមានប្រជាជនរស់នៅឡើយ ។ ប្រជាជនចាមបានសង់ខ្ទមតូចៗ ហើយរស់នៅលាយឡំជាមួយប្រជាជនខ្មែរ ។ ជីវិតឡើយពួកគេស្លាប់ទាំងអស់ ។

គេជម្លៀសខ្ញុំពីភូមិកោះផលទៅកាន់ភូមិផ្កាដូងនៅក្នុងឆ្នាំ ១៩៧៥ ។ ខ្ញុំអាចនៅចាំរឿងរ៉ាវកាលនោះ ។ យើងធ្វើដំណើរទៅកាន់ភូមិរកាខ្នុរ ។ ហើយក៏ឡើងជិះទូកកាត់តាមភូមិជំនីកមកកាន់ភូមិផ្កាដូង ។ ខ្ញុំរស់នៅក្នុងភូមិនោះដោយសង់កូនខ្ទមតូចមួយ ។ នៅភូមិផ្កាដូងមានប្រជាជនរស់នៅច្រើនជាងនៅភូមិក្របីក្រៀកនិងភូមិដទៃទៀត ។ ជនជាតិចាមមកពីភូមិទ្រាដែលគេ

ជម្លៀសមកកាន់ស្រុកដំបែ ក៏គេយកមកកាន់ភូមិផ្កាដូងនេះដែរ ក្នុងឆ្នាំ១៩៧៧ ។ ក្នុងរយៈពេលមួយឆ្នាំនោះខ្ញុំទទួលភារកិច្ចមើលគោនិងលើកទំនប់ ។ ខ្ញុំរែកដីស្ទើរតែបាក់ឆ្អឹងឆ្អែងអស់ហើយ ។ ខ្ញុំស្ទើរតែស្លាប់ទៅហើយកាលនោះ ។ អ្នកភូមិស្រុកនៅទីនោះជាច្រើនស្លាប់ដោយជំងឺគ្រុនចាញ់ ។ ប្រជាជនស្លាប់រាល់ថ្ងៃគឺប្រហែល ៣នាក់ក្នុងមួយថ្ងៃ ។ ប្រជាជនភាគតិចណាស់ដែលអាចរស់ ។

ក្រោយមកគេជម្លៀសយើងទៅកាន់ឃុំសួង ។ កាលនោះខ្ញុំក៏ចេះតែធ្វើដំណើរតាមគេឯង ប៉ុន្តែបានមកឈប់នៅត្រង់ក្បាលអូរ ពីព្រោះនៅទីនោះខ្ញុំបានជួបនឹងក្រុមគ្រួសាររបស់ខ្ញុំ ។ អ្នកផ្សេងៗទៀតចេះតែធ្វើដំណើរទៅមុខទៀតឆ្ពោះទៅកាន់ឃុំសួង ស្រុកត្បូងឃ្មុំ ។

## អែលម៉ាត់ អាយុ៤៦ឆ្នាំ រស់នៅភូមិកោះផល

ខ្ញុំត្រូវបានជម្លៀសទៅកាន់ភូមិផ្កាដូង ឃុំឈូក ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ។ នៅទីនោះខ្ញុំធ្វើស្រែនិងហូបបបរ ប៉ុន្តែគ្មានការធ្វើទារុណកម្មអ្វីទេ ។ ខ្ញុំរស់នៅភូមិផ្កាដូងអស់រយៈពេលជិត៣ខែ ។ ពេលដែលពួកនិរតីវាយពួកបូព៌ានាឆ្នាំ១៩៧៧ ខ្ញុំផ្លាស់ទីកន្លែងទៅកាន់ពោធិដើងខាល ហើយរស់នៅទីនោះអស់រយៈពេល៨ខែ ។ ពួកកម្មាភិបាលនិរតីបានសម្លាប់ប្រជាជនចាមទាំងអស់ដែលរស់នៅភូមិបារាយណ៍ និងភូមិច្រវាក់ដែក ប៉ុន្តែខ្មែរគេមិនសម្លាប់ទេ ។ ទាំងភូមិផ្កាដូង និងភូមិក្របីក្រៀកទាំងមូលគ្មានប្រជាជនរស់ម្នាក់ឡើយ ។ ខ្ញុំមិនដឹងហេតុអ្វីទេ ។ ខ្ញុំមិនដែលឃើញគេសម្លាប់មនុស្សទេ ។ មានតែពីរនាក់ប៉ុណ្ណោះគឺខ្ញុំនិងប្អូនស្រីដែលនៅរស់ ។ គ្រួសាររបស់ខ្ញុំស្លាប់អស់រួមទាំងបងៗរបស់ អែល សេន នៅភូមិផ្កាដូង អែល ទត នៅភូមិបារាយណ៍ និង អែល ទីយ៉ើ នៅភូមិបារាយណ៍ ។

ក្រោយពីខ្ញុំត្រឡប់មករស់នៅភូមិកោះផលបានពីរឆ្នាំ ខ្ញុំឮថាបងប្អូនជីដូនមួយស្រីរបស់ខ្ញុំឈ្មោះ អាមីណាស់ នៅរស់នៅឡើយ ។ ពេលនោះខ្ញុំក៏ទៅកាន់ភូមិច្រវាក់ដែករកមើលគាត់ ។ ខ្ញុំដើរចូលផ្ទះគេសុំទឹកផឹក ។ ខ្ញុំស្គាល់ផ្ទះនោះ ព្រោះខ្ញុំធ្លាប់នៅទីនោះពីមុនមក ។ ខ្ញុំក៏សួរស្ត្រីម្នាក់ថា «មានឃើញ អាមីណាស់ ដែលជាកូនរបស់អ៊ំស្រី ម៉េស ទេ» ។ ពេលនោះគាត់ក៏ស្រែកយំហ៊ូ ហើយថា «ស្លាប់អស់ហើយ ស្លាប់ទាំងអស់មួយគ្រួសារគ្មានសល់ម្នាក់ឡើយ» ។ គាត់ត្រូវគេសម្លាប់នៅម្តុំឃុំឈូក ។ ប្រជាជននៅភូមិបារាយណ៍ និងភូមិច្រវាក់ដែកត្រូវបានខ្មែរក្រហមសម្លាប់ច្រើនជាងភូមិដទៃទៀត ។

សមាជិកគ្រួសារនៅភូមិកោះផលត្រូវបានយកមកទុកនៅភូមិរកាខ្នុរអស់១០ថ្ងៃ ហើយក្រោយមកត្រូវចាត់ឲ្យទៅនៅភូមិផ្សេងៗជាច្រើនទៀត ។ ប្រជាជនទាំងនោះអាចបានមកជួបគ្នា ប៉ុន្តែមិនអាចនៅជាមួយគ្នាបានឡើយ ។ យើងអាចមកមើលសាច់ញាតិរបស់យើងដែលមានជំងឺតែរយៈពេលខ្លីប៉ុណ្ណោះ គឺមិនបាននៅមើលថែទាំឡើយ ។ ពួកវានិយាយថាមានអ្នកមើលខុសត្រូវហើយ មិនបាច់ឲ្យយើងនៅមើលទេ ។ នៅចុងឆ្នាំ១៩៧៨ នៅភូមិផ្កាដូង ពេលខ្ញុំកំពុងឃ្វាលក្របីខ្ញុំឃើញគេបោះត្រាក់ តែខ្ញុំមិនចេះអានទេ មិនដឹងជាគេដាក់ថាយ៉ាងម៉េច ។

សព្វថ្ងៃនៅភូមិកោះផលមានប្រជាជនរស់នៅចំនួន៦៣ គ្រួសារ ប្រកបមុខរបរចិញ្ចឹមជីវិតដោយធ្វើស្រែនិងនេសាទ ។

**សឹម សុរិយ៉ា**

**ចប់**


អ្នកស្រុក និង ក្មេងៗនៅភូមិចាម ខេត្តកំពង់ចាម

**(តពីលេខមុន)** ហ៊ុយ ទីពីរនៅមន្ទីរស-២១គឺ នុន ហ៊ុយ ហៅ «ហ៊ុយខ្ពស់» ឬ «ហ៊ុយស្រែ»។ ហ៊ុយ ទីពីរនេះមើលការខុសត្រូវមន្ទីរ២៤ ជាការដ្ឋានគុកនៅព្រៃសដែលជាសាខានៃមន្ទីរស-២១ ។ នៅក្នុងការដឹកនាំមន្ទីរស-២១ ហ៊ុយខ្ពស់ គឺជាមនុស្សដ៏សំខាន់ម្នាក់ ។ ជាឧទាហរណ៍ ក្នុងឆ្នាំ១៩៧៦ ហ៊ុយខ្ពស់មើលការខុសត្រូវវគ្គសិក្សាមួយចំនួនសម្រាប់សមាជិកក្រុមយុវជនកុម្មុយនិស្តកម្ពុជាធ្វើការនៅមន្ទីរ២៤នេះ ។ ប្រពន្ធរបស់ហ៊ុយខ្ពស់ ឈ្មោះ ប្រុក ខឿន ដែលជា «សមាជិកពេញសិទ្ធិ» នៃបក្សកុម្មុយនិស្តកម្ពុជា ធ្វើការពាក់កណ្តាលម៉ោងជាអ្នកសួរចម្លើយនៅគុកមន្ទីរស-២១ ។ ទាំងពីរនាក់ប្តីប្រពន្ធ នេះត្រូវបានចាប់ខ្លួននៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨ ។ ញ៉ែម អេន អះអាងថា ហ៊ុយខ្ពស់ត្រូវបានចាប់ខ្លួនពីបទល្មើសផ្លូវភេទ (ខុសសីលធម៌) ប៉ុន្តែចម្លើយសារភាពរបស់ ហ៊ុយខ្ពស់ ពុំបាននិយាយអំពីបទល្មើសនោះឡើយ ។




**សម្លេងពីមន្ទីរ ស-២១**
**វគ្គទី២: ស្ថាប័នស្វយ័ត**
**ដោយសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ**

## អ្នកសួរចម្លើយ

នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៦ ក្រុមអ្នកសួរចម្លើយមានយ៉ាងតិច ១១ក្រុមដែលមួយក្រុមៗមានសមាជិកចំនួន៦នាក់ ។ មកដល់ពាក់កណ្តាលឆ្នាំ១៩៧៧ ក្រុមសួរចម្លើយបង្រួញមកត្រឹម១០ក្រុម ដែលក្នុងមួយក្រុមមានសមាជិក៦នាក់ ។ ហើយក្រោយមកក៏បំបែកជាក្រុមតូចៗដែលមាន៣នាក់ ដែលមានអ្នកមើលខុសត្រូវតែម្នាក់ ។ ក្រុមនីមួយៗមានប្រធានម្នាក់ អនុប្រធានម្នាក់ជាអ្នកវិភាគឯកសារ និងសមាជិកម្នាក់ទៀត ហើយប្រព័ន្ធនេះត្រូវបានប្រើប្រាស់ជាទូទៅទាំងក្នុងសាខាបក្សនិងអង្គការផ្សេងៗទៀតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ មនុស្សទីបីដែលជួនកាលត្រូវបានចាត់ទុកជាឆ្នាំនោះ អាចជាមនុស្សដែលទទួលការចាត់តាំងឲ្យមកធ្វើទារុណកម្ម ។ នៅត្រឹមឆ្នាំ១៩៧៨ អ្នកសួរចម្លើយភាគច្រើនធ្វើការនៅក្នុងក្រុមក្តៅដែលចាត់តាំងដោយអ្នកសួរចម្លើយជាន់ខ្ពស់ឈ្មោះ ពូ ដែលមិនទាន់មាននរណាម្នាក់ដឹងប្រវត្តិរូបនៅឡើយ ។ នៅក្នុងឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៧ ក៏មានក្រុមសួរចម្លើយមួយក្រុមទៀតហៅថា «ក្រុមរង» (ក្រុមសួរស្លូត) ដែលសមាជិករបស់ក្រុមនេះមិនត្រូវបានអនុញ្ញាតឲ្យធ្វើទារុណកម្មអ្នកទោសឡើយ ។ ក្រុមក្តៅនៅក្នុងចម្លើយសារភាពត្រូវបានហៅថា «ក្រុមកាច» ។ ក្រុមនេះមានសិទ្ធិធ្វើទារុណកម្មអ្នកទោសបាន ។ នៅឆ្នាំ១៩៧៨ តាមចម្លើយសារភាពនានាគ្មាននិយាយពី «ក្រុមស្លូត» ឡើយ ប៉ុន្តែប្រហែលជាគេដូរមកជាក្រុម «ត្រជាក់» ក៏មិនដឹង ។ «ក្រុមអង្កៀម» ដែលមានសមាជិក៨នាក់ក្រោមការចាត់តាំងរបស់ឈ្មោះ ប្រាក់ ណន ដែលជាអ្នកសួរចម្លើយមានបទពិសោធន៍ ចាត់ការការងារណាដែលមានលក្ខណៈតឹងរ៉ឹងនិងសំខាន់ ។

នៅក្នុងឆ្នាំ១៩៧៧និងឆ្នាំ១៩៧៨ ហាក់ដូចជាមានយ៉ាងហោចណាស់អ្នកសួរចម្លើយម្នាក់ភេទស្រី ពោលគឺឈ្មោះ ប្រុក ខឿន ដែលជាប្រពន្ធរបស់ ហ៊ុយ ។ ប្រុក ខឿន មកពីក្រុម២៥ ហើយចាត់ទុកខ្លួនគាត់ថាជា «កសិករថ្នាក់កណ្តាលក្រោម» ។ ឃឿន បានសរសេរថាគាត់ចូលបដិវត្តន៍នៅឆ្នាំ១៩៧២ ដោយសារតែខ្លួនមានកំហឹងចំពោះ «ពួកវណ្ណៈកាន់អំណាចដែលជិះជាន់និងមើលងាយកសិករក្រ» ។ ក្រោយពីត្រូវបានផ្ទេរមកកាន់មន្ទីរស-២១ និងក្រោយពីរៀបការជាមួយនឹង«ហ៊ុយស្រែ» ឃឿន បានសារភាពថា ខ្លួនបានធ្វើទារុណកម្មអ្នកទោសជាច្រើននាក់ «ទាល់តែធ្វើការលែងកើត» ។ ក្រៅពីនេះក៏ប្រហែលជានៅមានអ្នកសួរចម្លើយភេទស្រីដទៃទៀតផងដែរ ។ អ៊ឹង ប៉ិច បានចាំឈ្មោះមនុស្សម្នាក់ដែលគាត់តែងតែដាក់ងារថា «អាយក្ស» ហើយឯកសារបានសរសេរថា គុន ជាប្រពន្ធរបស់កម្មាភិបាល

ជាន់ខ្ពស់ខ្មែរក្រហមនិងដែលត្រូវបានចាប់ខ្លួនដំណាលគាត់ (អ៊ឹង ប៉ុច) ត្រូវបានសួរចម្លើយដោយស្ត្រីពីរនាក់ឈ្មោះ លី និង ខុន ។ ប៉ុន្តែបើតាមកិច្ចសម្ភាសន៍ជាមួយឈ្មោះ កុក ស្រស់ បានឲ្យដឹងថា គ្មានអ្នកសួរចម្លើយភេទស្រីទេ ។

ភាគច្រើននៃអ្នកសួរចម្លើយនិងអ្នកធ្វើឯកសារ ធ្លាប់បានចូលរួមធ្វើសង្គ្រាមក្នុងអំឡុងឆ្នាំ១៩៧០-៧៥ ដោយបម្រើការជានិរសាដែលជាការងារប្រកបដោយគ្រោះថ្នាក់ និងគួរឲ្យគោរព ។ អ្នកសួរចម្លើយទាំងនេះច្រើនតែរៀននៅតាមសាលាបឋមសិក្សា ឬតាមវត្តអារាម ប្រហែលជាពីរ-បីឆ្នាំដើម្បីតែអាចចេះចងចាំ ចេះគោរព និងចេះសរសេរប៉ុណ្ណោះ ។ ទាំងនេះគឺជាលក្ខណៈចាំបាច់សម្រាប់ធ្វើការនៅមន្ទីរស-២១ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ការផ្ទេរពីការសិក្សាទៅការងារសង្គ្រាមនៅមន្ទីរស-២១ដែលជាកន្លែងឲ្យតម្លៃទៅលើគំនិតនយោបាយនោះ ពិតជាមានលក្ខណៈពិបាកណាស់សម្រាប់ក្មេងៗ ដូចដែលអតីតអ្នកសួរចម្លើយឈ្មោះ ម៉ា ម៉េងយាង បានសារភាពថា «គិតច្រើនពិបាកណាស់ ។ អ្នកឯងនឹងអស់កម្លាំងមែនទែននៅមន្ទីរស-២១ ហើយអ្នកនឹងឈឺក្បាលមិនខាន ហើយក្រៅពីនោះគឺជាការងារនយោបាយ ។ ធ្វើការនៅទីនោះមិនមែនជាការងាយស្រួលឡើយ ។ វាខុសពីការធ្វើស្រែនិងដាំដំណាំ ឬក៏ការធ្វើការនៅតាមរោងចក្រ ។ មិនដឹងជាដល់ថ្ងៃណាចប់ឡើយ ។ បើ «ត្រូវ» ក៏អ្នកឯងមិនដឹង ។ ប៉ុន្តែបើធ្វើស្រែវិញ អ្នកឯងដឹងថាមានគ្រាប់ពូជនិងមិនមាន ហើយនៅរោងចក្រអ្នកឯងដឹងថាម៉ាស៊ីនដើរឬមិនដើរ» ។

ការងារសម្រាប់អ្នកសួរចម្លើយមានរយៈពេលវែងណាស់ ហើយគួរឲ្យអស់កម្លាំងទៀតផង ។ ការសួរចម្លើយប្រព្រឹត្តទៅរហូតដល់យប់ជ្រៅ ។ អ្នកសួរចម្លើយមិនពេញចិត្តចំពោះលក្ខខណ្ឌការងារដែលស្ថិតក្នុងការបង្ខិតបង្ខំបែបនេះឡើយ ហើយនិយាយថា បើប្រៀបធៀបទៅឃើញថាខុសគ្នាច្រើនណាស់ទៅនឹងសេរីភាពដែលខ្លួនធ្លាប់ទទួលបានកាលពីសង្គ្រាមស៊ីវិល ។

## អ្នកធ្វើឯកសារ

សៀវភៅលេខទូរស័ព្ទមានឈ្មោះអ្នកធ្វើឯកសារចំនួន ១៨នាក់ ប៉ុន្តែវាមិនមានអ្វីគួរឲ្យឆ្ងល់ឡើយថានៅមានឈ្មោះច្រើនជាងនេះទៀត ហើយអ្នកដែលមានឈ្មោះនៅក្នុងតារាងនេះប្រហែលជាមើលខុសត្រូវក្រុមឯកសារដែលមានសមាជិក ៣ៗនាក់ ។ ក្រុមឯកសារនេះទទួលខុសត្រូវខាងចម្លងឯកសារចម្លើយសារភាពចេញពីខ្សែអាត់ ឯកសារអត្ថលីលេខ រៀបចម្លើយសារភាពសង្ខេប និងចងក្រងឯកសារ ។ គ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលឡើយថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយសារតែទាំងអស់គ្នាដឹងច្បាស់អំពីផលវិបាកនៃការ «បះបោរ» នោះ កំហុសខាងកត់ត្រាស្ទើរតែគ្មានកើតឡើងសោះឡើយ ។ ផលវិបាកជាក់ស្តែងនៅក្នុងឆ្នាំ១៩៧៦និង១៩៧៨ យ៉ាងហោចណាស់មានបុគ្គលិកចំនួន១០នាក់ដែលត្រូវបានចាប់ខ្លួនសួរចម្លើយ និងធ្វើទារុណកម្មទាល់តែស្លាប់ ។ អ្នកទាំង១០នាក់នោះសារភាពថាខ្លួន «ខ្ជិល» រៀបចំឯកសារ «ក្លែងបន្លំ» «ធ្វើឲ្យខូចម៉ាស៊ីន» និងវាយធ្វើបាបអ្នកទោសទាល់តែស្លាប់ពេលដែលខ្លួនជួយសួរចម្លើយ ។

ក្រុមថតរូបនៅមន្ទីរស-២១ស្ថិតនៅក្រោមការចាត់ចែងរបស់ សួស ធី ។ សមាជិកនៅក្នុងក្រុមនេះធ្វើការថតរូបអ្នកទោសពេលបញ្ជូនមកដល់ភ្លាម អ្នកទោសដែលស្លាប់ក្នុងលក្ខណៈជាឈ្លើយសឹក និងអ្នកទោសសំខាន់ៗផ្សេងៗទៀតក្រោយពីខ្លួនត្រូវបានសម្លាប់ ។ តាមប្រសាសន៍របស់លោក ញ៉ែម អេន ដែលធ្វើការនៅក្នុងក្រុមរូបថតនេះបានឲ្យដឹងថា រូបថតប្រភេទនេះ (រូបថតអ្នកទោសដែលគេអារ-ក) ថតដោយក្រុមកម្មាភិបាលដែលត្រូវបានជ្រើសជាពិសេស ហើយរូបថតមួយច្បាប់ត្រូវបញ្ជូនឲ្យ «បងថ្នាក់លើ» ។ ក្រុមថតរូបនេះក៏ផលិតរូបថតបុគ្គលិកប្រើក្នុងប័ណ្ណសម្គាល់ខ្លួនផងដែរ ។ រូបថតជាង៦០០០សន្លឹកដែលថតដោយក្រុមថតរូបនេះរក្សារូបរាងមកដល់សព្វថ្ងៃ ។ រូបថតពាក់កណ្តាលខ្លួនជាច្រើនរយសន្លឹកដែលត្រូវបានជ្រើសរើសនិងពង្រីកដោយជាងថតរូបមកពីប្រទេសអាល្លឺម៉ង់ខាងកើតក្នុងឆ្នាំ១៩៨១ ត្រូវបានបិទជាប់នឹងជញ្ជាំងសារមន្ទីរគុកទួលស្លែងតាំងពីឆ្នាំ១៩៨០មកម្ល៉េះ ។

ក្រុមថតរូបបានប្រើប្រាស់ម៉ាស៊ីនថត ហ៊្វីល ក្រដាស និងសារធាតុគីមីសម្រាប់ផ្តិត ដែលពួកខ្លួនរកឃើញតាមកន្លែង



អ្នកទោសគុកទួលស្លែង

នានានៅក្នុងទីក្រុង ។ ញ៉ែម អេន ដែលផ្តាច់ខ្លួនពីខ្មែរក្រហមនៅឆ្នាំ១៩៩៦ ត្រូវបានអ្នកកាសែតសម្ភាសជាច្រើនលើកច្រើនសា ។ អេន ជាក្មេងអ្នកស្រែចម្ការម្នាក់មកពីខេត្តកំពង់ចាម ដែលចូលធ្វើជាខ្មែរក្រហមក្នុងឆ្នាំ១៩៧០ ពេលខ្លួនមានអាយុ១០ឆ្នាំ ។ អេន ត្រូវបានជ្រើសរើសឲ្យទៅរៀនវិជ្ជាថតរូបនៅប្រទេសចិនក្នុងឆ្នាំ១៩៧៥-៧៦ ហើយក្រោយមកក៏មកធ្វើការនៅគុកស-២១ ។ មានខ្មែរចំនួន៥នាក់ធ្វើការជាមួយ អេន ហើយម្នាក់ក្នុងចំណោមអ្នកទាំងនោះត្រូវបានបោសសម្អាត ។ អេន ខ្លួនឯងផ្ទាល់ក៏ត្រូវស្ថិតក្រោមការសង្ស័យកាលពីរដូវក្តៅឆ្នាំ១៩៧៧ ដោយខ្លួនបានលេងវិទ្យុនិងថតរូបមិនបានល្អ ហើយបទល្មើសទាំងនេះគាត់ទើបរំលឹកឡើងវិញ២០ឆ្នាំក្រោយមក ។ រូបថតមួយក្នុងចំណោមរូបថតទាំងអស់ដែលគាត់បានថត និងត្រូវបានផ្តិតកាលពីគាត់ទៅទស្សនកិច្ចនៅប្រទេសចិនកាលពីខែតុលា ឆ្នាំ១៩៧៧ ជារូបរបស់ «បងធំទី១» ដែលមានស្នាមពណ៌នៅត្រង់ផ្នែកខាងលើភ្នែកម្ខាង ។ ចាន់ បានចោទ អេន ថាបានធ្វើឲ្យរូបថតនេះខូចក្នុងបំណងមើលងាយ ប៉ុល ពត ហើយពេលនោះ អេន ក៏ត្រូវបញ្ជូនទៅកាន់មន្ទីរកែប្រែដែលស្ថិតនៅព្រៃស ។ អេន និយាយថា នៅដើមឆ្នាំ១៩៧៨ គាត់ក៏ត្រូវដោះលែងមកវិញ ។ ហើយក្រោយមកទើបចាន់ ឃើញស្នាមដែបមួយកន្លែងនៅលើហ៊ឹលដើម ។

## ឆ្មាំសន្តិសុខ

ក្រុមការពារដែលមិនកត់ចូលទៅក្នុងសៀវភៅទូរស័ព្ទគឺជាក្រុមដែលធំជាងគេបង្អស់នៅគុកទួលស្លែង ។ នៅឆ្នាំ១៩៧៨ ក្រុមនេះមានសមាជិកចំនួន១៦៩នាក់ ។ ក្នុងចំណោមសមាជិកទាំងអស់មាន១២៧នាក់ត្រូវបានទុកនៅកន្លែង ហើយអ្នកសល់ពីនោះដែលនៅក្បែរគុកពិសេសត្រូវបានចាត់តាំងទៅភាគខាងត្បូងដែលជាកន្លែងកម្មាភិបាលជាន់ខ្ពស់ ។ ក្នុងឆ្នាំ១៩៧៦ និង១៩៧៧ ពួកសន្តិសុខត្រូវបានចែកចេញជាក្រុមយាម៦ក្រុម ដែលក្នុងក្រុមនីមួយៗត្រូវយាម៤ម៉ោងក្នុងមួយថ្ងៃ ។ ប៉ុន្តែមកដល់ឆ្នាំ១៩៧៨ ពួកសន្តិសុខធ្វើការក្នុងក្រុមដែលមានសមាជិក១០នាក់ត្រូវយាម៨ម៉ោង ។ កងសន្តិសុខទាំងអស់ត្រូវធ្វើតាមបទបញ្ជាទូទៅមួយដែលមាន៣០ចំណុច សរសេរឡើងដើម្បីឲ្យសន្តិសុខប្រុងប្រយ័ត្ននិងមិនឲ្យទាក់ទងជាមួយអ្នកទោស ។ បទបញ្ជាទាំងនោះបានតម្រូវឲ្យសន្តិសុខគុកមើលកុំឲ្យអ្នកទោសរត់រួច, កាន់អាវុធ, ធ្វើអត្តឃាត ឬនិយាយគ្នា ។

ឆ្មាំសន្តិសុខគេមិនអនុញ្ញាតឲ្យជជែកលេងជាមួយអ្នក

ទោស ស៊ុំស្គាល់ឈ្មោះ ឬវាយអ្នកទោសឡើយ ប៉ុន្តែបើតាមសម្តីសារភាពរបស់អតីតឆ្មាំគុកម្នាក់បានឲ្យដឹងថាៈ «បើសិនជាអ្នកឯងកំពុងយាមពេលយប់ អ្នកឯងអាចវាយអ្នកទោសបានបើគ្មានអ្នកណាឃើញ» ។ កុក ស្រស់ បាននិយាយថា ពេលឆ្មាំត្រូវគេហាមមិនឲ្យវាយអ្នកទោសនោះមានតែអ្នកដែលវាយអ្នកទោសធ្ងន់ធ្ងរប៉ុណ្ណោះត្រូវទទួលទណ្ឌកម្ម ។ លើសពីនេះទៀត «បើសិនអ្នកទោសមិនធ្វើតាមបញ្ជាយើង យើងអាចមានសិទ្ធិវាយបាន» ។ ចំពោះការជជែកគ្នាធម្មតាវិញ កុក ស្រស់ បន្តថាៈ «យើងអាចនិយាយលេងជាមួយអ្នកទោស ប៉ុន្តែមិនអាចអាណិតអ្នកទោសទេ ។ មានអ្នកខ្លះបានសុំឲ្យយើងដោះលែង ប៉ុន្តែបើយើងធ្វើដូច្នេះយើងពិតជាត្រូវចូលជំនួសអ្នកដែលយើងដោះលែងនោះមិនខាន ។ អ្នកទោសខ្លះនិយាយថា «ខ្ញុំមិនបានធ្វើអ្វីខុសទេហេតុអ្វីបានជាអង្គការនាំខ្ញុំមកដាក់នៅទីនេះទៅវិញ?» ។ ពេលនោះខ្ញុំមិនដឹងជាធ្វើយ៉ាងម៉េចទេ ។ ខ្ញុំក៏បានប្រាប់អ្នកទោសទៅវិញថា ខ្ញុំខ្លាចណាស់មិនហ៊ានជួយទេ» ។

ឆ្មាំគុកក៏ត្រូវបានហាមមិនឲ្យមើល ឬលួចមើលការសួរចម្លើយដែរ ហើយត្រូវតែចាំជានិច្ចថា «ពេលយាម ឆ្មាំទាំងអស់មិនត្រូវលួចស្តាប់ ឬអង្គុយ ឬផ្អែកនៅជញ្ជាំងទេ ។ ឆ្មាំត្រូវតែដើរមើលជុំវិញ ហើយពិនិត្យអ្វីៗគ្រប់យ៉ាងដោយប្រុងប្រយ័ត្នបំផុត» នេះជាបទបញ្ជាផ្ទៃក្នុងរបស់មន្ទីរស-២១ ។ ឆ្មាំគុកកម្រនឹងបានដេកពេញភ្នែកណាស់ ។ នៅក្នុងរបាយការណ៍ស្វ័យទិតៀន ឆ្មាំគុកភាគច្រើនបានរៀបរាប់ថា ខ្លួន «ងងុយដេកណាស់» ហើយនេះគឺជាកំហុសយ៉ាងធំប៉ះពាល់ដល់ការងាររបស់ខ្លួន ។ ការងាររាល់ថ្ងៃដែលត្រូវការយកចិត្តទុកដាក់រួមមានការដឹកជញ្ជូនអាវុធគ្រាប់រំសេវ និងដោះដូរប្រវ៉ាក់ ខ្នោះឃ្នាង និងសោរគុក ។ លើសពីនេះនៅមានការផ្ទេរអ្នកទោសពីបន្ទប់របស់ខ្លួនទៅកន្លែងសួរចម្លើយ និងទៅដើងឯកដោយរថយន្ត ដែលប្រព្រឹត្តទៅដោយមានលក្ខណៈប្រទាក់ក្រឡាសាំញ៉ាំ ។

បទបញ្ជាសម្រាប់ឆ្មាំគុកបានហាមមិនឲ្យមានអំពើមនុស្សធម៌ឡើយ ។ គោលជំហរនិងសតិអារម្មណ៍ខ្ពស់ត្រូវតែមានដាច់ខាតចំពោះអ្នកដែលទទួលខុសត្រូវនៅក្នុងក្រុម ។ ឯកសារស្វ័យទិតៀនមួយដែលរៀបចំឡើងនៅក្នុងមន្ទីរស-២១ កាលពីឆ្នាំ១៩៧៧ បានចោទប្រកាន់ឆ្មាំគុកមួយចំនួនថា «នាំគ្នាសើចនៅពេលទំនេរ» និង «ខ្វះគោលជំហរបដិវត្តន៍» ។ បទល្មើសដដែលៗនេះត្រូវបានរៀបរាប់នៅក្នុងប្រវត្តិស្វ័យទិតៀនដែលឆ្មាំគុកបានរៀបចំពីពេលមួយទៅពេលមួយ ព្រមទាំងមាននៅក្នុងចម្លើយសារភាពរបស់ឆ្មាំមួយចំនួន ។ ញ៉ែម អេន បានរំឭកអំពីការលេងសើចសប្បាយរបស់ខ្លួនជាមួយអ្នកធ្វើការជាមួយគ្នាក្នុងក្រុមថតរូប ចំណែក កុក ស្រស់ បាននិយាយអំពីចំណងមិត្តភាពដែលខ្លួនបានបង្កើតក្នុងរយៈពេល៣ឆ្នាំធ្វើការនៅក្នុងគុក ។

## ល្បាចមួយនៅមន្ទីរស-២១

កាលពីដើមឡើយបទបញ្ជាសម្រាប់ឆ្មាំនៅមន្ទីរស-២១ មានលក្ខណៈមិនសូវជាតឹងតែងទេ ។ របាយការណ៍អំពីការយាមកាមសរសេរនៅខែតុលា ឆ្នាំ១៩៧៦ ដែលមានព័ត៌មានប្រហាក់ប្រហែលនេះដែរ គឺជាឯកសារតែមួយគត់ដែលកត់ត្រានូវការសន្ទនាគ្នារវាងឆ្មាំគុកនិងអ្នកទោស ។ របាយការណ៍នេះបង្ហាញពីការទាក់ទងគ្នាធម្មតារវាងអ្នកទោសនិងឆ្មាំគុក ព្រមទាំងកត់ត្រានូវឧទាហរណ៍មួយចំនួននិយាយអំពីសេចក្តីក្លាហាននិងការប្រឆាំងមានះរបស់អ្នកទោសនៅក្នុងចម្លើយសារភាពរបស់ខ្លួនដែលធ្វើឡើងដោយមានការធ្វើទារុណកម្ម÷

*សេចក្តីសង្ខេបដែលត្រូវបញ្ជូនទៅកាន់បងទទួលខុសត្រូវខាងក្រុមឆ្មាំ*

*I. ឆ្មាំគុកផ្ទៃក្នុង*

*ក-សកម្មភាពរបស់ខ្មាំង*

*-នៅអគារ «ក» បន្ទប់លេខ៥ អ្នកទោសឈ្មោះ ពុន សុជល បានប្រាប់ឆ្មាំថាមូសខាំខ្លាំងណាស់ ។*

*-នៅបន្ទប់លេខ៨ បន្ទប់តូចលេខ៣ អ្នកទោសឈ្មោះ ងៃ យេត និយាយថាមិនបានដេកលក់ស្រួលទេក្នុងចន្លោះពេលថ្ងៃលិចដល់ម៉ោង២ព្រឹក ។*

*-នៅបន្ទប់ក្រោមជណ្តើរនៅផ្នែកខាងលិច អ្នកទោសដែលដេកមិនលក់បានលួចមើលឆ្មាំនិងខ្សែភ្លើងញឹកញាប់ណាស់ ។*

*-នៅបន្ទប់ទី៥ បន្ទប់តូចលេខ១៨ អ្នកទោសឈ្មោះ សុខ ហឿន ហៅ ហម បានរុញគុម្ពសូរគុងគ្នាំងដោយគ្មានប្រាប់ឆ្មាំឡើយ ។*

*-នៅបន្ទប់ទី៣ បន្ទប់តូចលេខ១៨ អ្នកទោសឈ្មោះ យឹម ភឿង*

និយាយរំខាននៅពេលដែលសមមិត្តយើងកំពុងចែកបបរថាខ្លួនមិនទាន់បានហូបអ្វីឡើយ ហើយទើបតែមកពីធ្វើការងារ ។ ប៉ុន្តែតាមពិតវាមិនបានធ្វើការឡើយ ព្រោះខ្នោះនៅជាប់ដៃវានៅឡើយ ។

-នៅផ្ទះបាយ បន្ទប់លេខ៦ បន្ទប់តូចលេខ៣ មានអ្នកទោសចំនួន៤នាក់ ឈ្មោះ ម៉ៅ ហុង, យូ ណន, ពុន លាង និង ឌី សុម៉ាត ព្យាយាមបំបាក់សោររត់ ។ អាម្នាក់នោះនិយាយថា«នេះមិនមែនជាកន្លែងអង្គការឡើយ នេះជាកន្លែងផ្ទាល់ខ្លួន» ។ ម៉ៅ ហុង និយាយថា «កន្លែងនេះហើយដែលអង្គការបានចាប់ខ្ញុំ ហើយជាកន្លែងដែលខ្ញុំពិតជាស្លាប់ ពីព្រោះអង្គការនេះមានសមាសភាពពួកចោរព្រៃ» ។ នេះគឺជាសម្តីរបស់ ម៉ៅ ហុង ដែលនិយាយទៅកាន់ឆ្មាំម្នាក់របស់យើង ។

-នៅអគារ«ង» បន្ទប់លេខ៥ បន្ទប់តូចលេខ១០ ពេលដែលឆ្មាំគុកបានឲ្យអ្នកទោសឈ្មោះ សំ សាវ៉ាវុធ សណ្តូកជើងអ្នកទោសនោះនិយាយថា វាមិនអាចងើបរួចទេ ប៉ុន្តែពេលដែលឆ្មាំគុកចេញបាត់វាក៏ងើបឈរឡើង ។

## កងវរតូចៗរបស់គុក

កងវរតូចៗចំនួន៣និងចម្ការដែលមានគុកនៅព្រៃសដំណើរការក្រោមការឧបត្ថម្ភគាំទ្រពីកងការពារ ។ នៅក្នុងក្រុមមួយមាន«អ្នកចាប់ចង» ចំនួន៨នាក់ ពេលខ្លះគេហៅថា «និរសា» ហើយនិងមានសមាជិក១០នាក់នៅក្រុមផ្នែកយានយន្ត ។ តាមសម្តីរបស់ ញ៉ែម អេន បានឲ្យដឹងថាអ្នកចាប់ចងបានស្តុកអ្នកទោសទៅកាន់មន្ទីរស-២១ដោយយកមកពីតាមជនបទ រួចហើយក៏សម្លាប់អ្នកទោសទាំងអស់ចោលភ្លាម រួមទាំងកម្មាភិបាលសំខាន់ៗដែលត្រូវបានគេសម្លាប់ហើយយកមកកប់ចោលនៅក្បែរគុកនោះ ។ ការចងចាំរបស់ ញ៉ែម អេន ត្រូវបានបញ្ជាក់ដោយ កុក ស្រស់ ។ នៅឆ្នាំ១៩៧៧ ឈ្មោះ ហ៊ឹម ហ៊ុយ បានធ្វើការនៅក្នុងកងនេះ ហើយទទួលបាននូវកេរ្តិ៍ឈ្មោះគួរឲ្យភ័យខ្លាចក្នុងចំណោមបុគ្គលិកដទៃទៀត ។ ក្រុមផ្នែកយានយន្តបានដឹកអ្នកទោសមួយក្រុមមកកាន់មន្ទីរស-២១ ហើយនាំយកអ្នកផ្សេងទៅសម្លាប់ចោលនៅបឹងជើងឯក ។

ក្រុមសេដ្ឋកិច្ចដែលមានសមាជិក២៦នាក់ដែលជាផ្នែកមួយនៃក្រុមការពារ បានផ្តល់ជាអាហារហូបចុកនិងសេវាផ្នែកគុកដល់ឆ្មាំគុក អ្នកសួរចម្លើយ និងអ្នកទោស ។ សមាជិកពីរនាក់ជាជាងកាត់សក់ និង៥នាក់ដទៃទៀតទទួលខុសត្រូវខាងចិញ្ចឹមមាន់ ទា ទន្សាយ ជ្រូក និងដាំបន្លែនៅក្នុងបរិវេណគុក ។ ចំពោះ «អ្នកប្រមូលលាមក» នៅក្នុងក្រុមបានជួយស្ទង់វាស់វែង និងធ្វើការផ្នែកប្រព័ន្ធលូទឹកស្អុយផ្សេងៗ ។ ឆ្មាំនឹងត្រូវទទួលភារកិច្ចខាងលើទាំងនេះបើសិនជាខ្លួនប្រព្រឹត្តបទល្មើសធម្មតាមិនធ្ងន់ធ្ងរ ។ លាមកត្រូវបានប្រមែប្រមូលដោយបង្កើយកទៅធ្វើជី ។

មានបុគ្គលិកសេដ្ឋកិច្ចចំនួន៧នាក់ជាអ្នករៀបចំនិងចែកចាយអាហារដល់មនុស្សនៅក្នុងគុកដែលមានចំនួនជាមធ្យមជាង១០០០នាក់ ប៉ុន្តែលើសពីនេះនៅចុងឆ្នាំ១៩៧៧ និងដើមឆ្នាំ១៩៧៨ ។ មានបុគ្គលិក៦នាក់ផ្សេងទៀតធ្វើការងារប្រហាក់ប្រហែលនឹងគ្នានេះដែរចំពោះអ្នកសួរចម្លើយរាប់រយនាក់ និងបុគ្គលិកឯកសារ ហើយជាង៣០នាក់ទៀតមើលខុសត្រូវឆ្មាំចំនួនប្រហែល២០០នាក់ ។ នៅក្នុងរបាយការណ៍របស់ ឌុច ទាក់ទងនឹងការងារគុកក្នុងរយៈពេល៣ខែដំបូងនៅឆ្នាំ១៩៧៧ បានសរសេរថា ខ្លួនបានចាត់តាំងឲ្យមានបណ្តាញតាមដានចំនួន៧ដើម្បីរកមើលមាន់ទាដែលរាប់នៅក្នុងបរិវេណគុក ហើយពីរបណ្តាញ


សាស ចន្ទា


ស៊ុម ជៀប


ដួ ពៅ


ញ៉ឹង


សុក ម៉ុច


ណោន ណាត


ពៅ


ង៉ូច ភាព


ភឿន ផៃ


សុត ភាន់

ទៀតធ្វើរបាយការណ៍អំពីអ្នកគុក១៨នាក់ដែលស្លាប់ដោយទារុណកម្ម ។ នៅក្នុងកន្លែងដែលព័ទ្ធដោយកញ្ចក់នៃមន្ទីរស-២១ សត្វទាត្រូវបានគេកាន់ទុកលើសពីមនុស្សស្លាប់ទៅទៀត ។

ស្រូវរបស់មន្ទីរស-២១ប្អប្រហែលជារបស់ក្រុមផ្សេងៗទៀតនៅក្នុងទីក្រុង ត្រូវបានដាំនៅព្រៃស ។ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ អ្នកដែលធ្វើខុសតិចតួចទាំងប្រុសទាំងស្រី ត្រូវបានដឹកពីអង្គភាពរោងចក្រនិងការដ្ឋានជាច្រើននៅក្នុងទីក្រុងភ្នំពេញមកដាក់គុកទួលស្លែង ។ យោងតាមឯកសាររៀបចំដោយ «ហ៊ុយស្រែ» នៅ១០ខែដំបូងនៃឆ្នាំ១៩៧៧ អ្នកទោសជាង ២០០០នាក់ ត្រូវបាននាំយកមកកាន់ព្រៃស ។ ក្នុងនោះមាន១៩២នាក់ ភាគច្រើនមានអាយុក្រោម២០ឆ្នាំ ត្រូវស្លាប់ដោយជំងឺ ហើយមាន៨០នាក់ផ្សេងទៀតបានរត់រួចពីគុក ។ ក្រោយមកក៏ត្រូវចាប់ខ្លួនបានវិញចំនួន២៧នាក់ ហើយក៏បានបញ្ជូនមកកាន់មន្ទីរស-២១ ។ អ្នកទោសដែលនៅសល់ទាំងប៉ុន្មានប្រហែលជាត្រូវបញ្ជូនមកមន្ទីរស-២១តាមក្រោយៗជាបណ្តើរៗ ដែលក្នុងនោះក៏មានឈ្មោះ ញ៉ែម អេន និង ហ៊ឹម ហ៊ុយ ផងដែរ ហើយអ្នកទាំងពីរនេះក៏ត្រឡប់មកកាន់ការងាររបស់ខ្លួនវិញ ក្រោយពីទទួលការដាក់ទោសមួយរយៈខ្លីនៅព្រៃស ។

អង្គភាពការពាររបស់ ហ៊ឹ ក៏មានភារកិច្ចមើលការខុសត្រូវការងារបុគ្គលិកពេទ្យចំនួន១៥នាក់ដែលមើលព្យាបាលអ្នកទោសមានជំងឺដោយសារការវាយសួរចម្លើយ បិទមុខរបួសឲ្យអ្នកដែលមានរបួសធ្ងន់ធ្ងរ និងធ្វើការបញ្ជាក់អំពីការស្លាប់ ។ មានពេទ្យម្នាក់ឈ្មោះ ភួង ជីវី ហៅ ភឿន បានត្អូញត្អែរនៅក្នុងចម្លើយសារភាពរបស់ខ្លួនថា នៅក្នុងមន្ទីរស-២១មានតែបុគ្គលិកពេទ្យដែលបានហ្វឹកហាត់រៀនត្រឹមត្រូវតែ៣នាក់ប៉ុណ្ណោះ សម្រាប់មើលការខុសត្រូវចំពោះអ្នកទោសរាប់ពាន់នាក់ ។ គាត់បន្តថា មិនអាចទៅរួចទេក្នុងការព្យាបាលអ្នកទោសក្នុងចំនួនច្រើនបែបនេះ ហើយមានអ្នកទោសច្រើនណាស់បានស្លាប់ ។ បុរសម្នាក់ដែលទទួលខុសត្រូវខាងផ្នែកពេទ្យនោះឈ្មោះ ផេង ទ្រី ហើយក្រោយមកខ្លួនឯងផ្ទាល់ក៏ត្រូវបានចាប់ខ្លួន បន្ទាប់មកបានធ្វើការសារភាពនូវកំហុសប្រហាក់ប្រហែលគ្នានេះដែរនៅក្នុងសម័យប្រជុំស៊ុយទិតៀននាឆ្នាំ១៩៧៧ ដែលកាលនោះ ទ្រី ត្រូវបានចោទថា«មិនជឿពេទ្យបដិវត្តន៍» ។ ឯកសារនៅគុកទួលស្លែងបានសរសេរថា អ្នកទោសមួយចំនួនបានកើតជំងឺគ្រុនចាញ់ រាគរូស ស្គមរីងរៃ និងទទួលការធ្វើទុក្ខបុកម្នេញ ។ នៅក្នុងឯកសារមួយដែលមានរាយឈ្មោះចំនួន២១នាក់ស្លាប់នៅក្នុងរយៈពេលដ៏ខ្លីនោះ បានសរសេរថា មាន៥នាក់ស្លាប់ដោយ «របួស» និងម្នាក់ទៀតស្លាប់ដោយអំពើ«ទារុណកម្ម»ដោយថប់ដង្ហើមនឹងថង់កៅស៊ូ ។ មានអ្នកទោសចំនួន៥២នាក់ត្រូវបាននិយាយថាស្លាប់ដោយ «ជំងឺ» ក្នុងរវាងខែមេសានិងខែកញ្ញា ឆ្នាំ១៩៧៦ ជាពេលដែលគុកនេះដាក់មនុស្សចំនួនជិត៣០០នាក់ក្នុងមួយលើកៗ ។ ហើយសៀវភៅរបស់កម្មាភិបាលមួយក្បាលសរសេរនៅឆ្នាំ១៩៧៧ បានសរសេរថា មានមនុស្សស្លាប់ចំនួន៣៩នាក់ នៅក្នុងខែកក្កដា ៨៨នាក់នៅខែសីហា ៤៩នាក់នៅខែតុលា និង៦៧នាក់នៅខែវិច្ឆិកា ។ ជាសរុបមានអ្នកស្លាប់ចំនួន២៣៤នាក់ ក្នុងរយៈពេលជាង៤ខែ ។ ភាគច្រើននៃអ្នកដែលបានស្លាប់ទាំងអស់ គឺទទួលរងនូវការរងរបួស ការខ្វះជីវជាតិ និងការធ្វើទារុណកម្ម ។ រូបថតសាកសពជាច្រើននៅក្នុងបណ្ណសារដ្ឋានបានបង្ហាញឲ្យឃើញថា អ្នកទាំងនោះស្លាប់ដោយកង្វះចំណីអាហារដ៏ធ្ងន់ធ្ងរបំផុត ។

**(នៅមានត)**

# គំរូមួយនៃភ័ស្តុតាងឯកសារដែលភ្ជាប់មេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនិស្តកម្ពុជា ដែលនៅរស់ ទៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ភាគ២)

**(តពីលេខ២៧)** ចម្លើយសារភាពធ្វើឡើងនៅខែកុម្ភៈ ឆ្នាំ១៩៧៨ របស់ មាឃ ទូច ហៅ កែម ដែលនៅពេលចាប់ខ្លួនជាឯកអគ្គរដ្ឋទូតប្រចាំនៅប្រទេសឡាវ បង្ហាញឲ្យឃើញពីកំហុសរបស់ អៀង សារី ដែលបានដឹងឮពីការកាប់សម្លាប់ប្រជាជននៅតាមជនបទ និងពីការចាប់ខ្លួននានា ។ ចម្លើយសារភាពនោះមានចំណារផ្សេងៗដើម្បីធ្វើទោសមមិត្ត «វ៉ាន់» ជាមួយនឹងចំណារផ្សេងមួយទៀតនៅក្នុងដៃរបស់ ឌុច ជម្រាបដល់ «បងជាទីគោរព» ថា «កែមជាប់ពាក់ព័ន្ធនឹងសកម្មភាពពីរៈ ១) ជាមួយផ្នែកចក្រពត្តិ វាទាក់ទងអង្គការ ហាស់ សេ អ៊ាវ ។ ២) ជាមួយយួនវាធ្វើការងារជាប់ជាមួយទូតយួន» ។ ឌុច បានជួយបន្ថែមថា កែម រៀបរាប់អំពើក្បត់របស់ខ្លួននៅប្រទេសឡាវ លើទំព័រទី៣៧ ។



នៅក្នុងចម្លើយសារភាពរបស់គាត់ កែម បាននិយាយថាខ្លួនបានធ្វើការឃោសនាអណិកជនខ្មែររស់នៅក្រុងវៀងច័ន្ទ ដែលជារាជធានីរបស់ប្រទេសឡាវ ដូចជាឲ្យប្រជាជន «មើលឃើញការលំបាកវេទនានិងការឈឺចាប់របស់ប្រជាជន» នៅក្នុងប្រទេសកម្ពុជាដូចជាការទទួលរងនូវ «ការកៀបសង្កត់ បំបិទសិទ្ធិសេរីភាព និងការប្រើអំណាចផ្តាច់ការរបស់របបកាន់អំណាចដែលកាប់សម្លាប់ប្រជាជន» ។

តារាងឈ្មោះចុងក្រោយរបស់ កែម ដែលដាក់ថា «ឈ្មោះមនុស្សដែលពាក់ព័ន្ធជាមួយសកម្មភាពរបស់ខ្ញុំ» រួមមានឈ្មោះមនុស្ស ១០នាក់ដែលត្រូវបានចារពីលើថា ត្រូវបាន «ចាប់ខ្លួនហើយ» និងឈ្មោះ៥០នាក់ផ្សេងទៀតដែលបានចោទថា «ក្បត់» ឬប្រព្រឹត្តអំពើឧក្រិដ្ឋកម្មផ្សេងៗទៀត ប៉ុន្តែមិនទាន់ចាប់ខ្លួននៅឡើយ ។

ច្បាប់ទីពីរនៃចម្លើយសារភាពដែលសម្គាល់អំពីការយកចិត្តទុកដាក់របស់ អៀង សារី គឺជាចម្លើយសារភាពរបស់ សាន់ ប៉ូ ជាយុទ្ធជននៅភ្នំពេញ «ផ្សាររដ្ឋ» ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការបរទេស ។ ទោះជាចម្លើយសារភាពមិនមាននិយាយអំពីការសម្លាប់មនុស្សក៏ដោយប៉ុន្តែការបញ្ជាក់ចុងក្រោយដែលសរសេរថា «នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៧៨ អង្គការបានចាប់ខ្លួនខ្ញុំ ហើយបញ្ជូនមកកាន់កន្លែងតែម្តង» ពោលគឺមន្ទីរ «ស-២១» ត្រូវបានភ្ជាប់ជាមួយបញ្ជីមួយដែលមានចំណងជើងថា «អំពីកម្លាំងក្បត់ដកស្រង់ពីប្រវត្តិសកម្មភាពក្បត់របស់ សាន់ ប៉ូ យុទ្ធជនផ្សាររដ្ឋ» ។ តារាងនេះមានឈ្មោះ៣៨នាក់ដែលត្រូវបានចារថា ត្រូវបានចាប់ខ្លួន

រួចហើយ ។

## របាយការណ៍សរសេរមកពីថ្នាក់ក្រោមនិងពីកន្លែងផ្សេងៗទៀត

ប្រភេទឯកសារផ្សេងៗទៀតនៅឯមជ្ឈមណ្ឌលឯកសារកម្ពុជាដែលពាក់ព័ន្ធនឹងមេដឹកនាំជាន់ខ្ពស់និងកម្មាភិបាលបក្សកុម្មុយនិស្តកម្ពុជាពីអំពើឧក្រិដ្ឋកម្ម មាននិយាយអំពីរបាយការណ៍សភាពការណ៍ផ្ទៃក្នុងដែលត្រូវបានចម្លងទៅឲ្យមេដឹកនាំជាន់ខ្ពស់ទាំងនោះ ។ ឯកសារពាក់ព័ន្ធទាំងអស់នេះរួមមាន ទូរលេខនិងសារទូរលេខផ្សេងៗដែលផ្ញើមកពីភូមិភាគផ្សេងៗនៃបក្សកុម្មុយនិស្តកម្ពុជាផ្នែកផ្សេងៗ និងពីថ្នាក់ក្រោមផ្សេងៗទៀត ប៉ុន្តែក៏មានរបាយការណ៍មកពីអគ្គភាពយោធាដែលធម្មតាស្ថិតនៅក្រោមគណៈកម្មាធិការមជ្ឈិមបក្ស និងមកពីឯកអគ្គរដ្ឋទូតនានាប្រចាំនៅបរទេស ។ ឯកសារដែលរៀបរាប់ខាងលើនេះបានបន្ថែមទម្ងន់ទៅលើភស្តុតាងនៃការពាក់ព័ន្ធផ្ទាល់របស់កម្មាភិបាលនៅក្រៅក្រុងភ្នំពេញពីបទល្មើសផ្សេងៗដែលអាចចូលទៅក្នុងផ្នែកខ្លះនៃបទដ្ឋានឧក្រិដ្ឋកម្មអន្តរជាតិ ហើយយ៉ាងហោចណាស់ក៏ចូលក្នុង «ទោសស្តីពីបទដឹងឮហើយមិនបានចាត់វិធានការទប់ស្កាត់» របស់មេដឹកនាំជាន់ខ្ពស់នៅក្នុងក្រុងភ្នំពេញ ។ ទាក់ទងនឹងករណីក្រោយនេះ តាមទស្សនៈរបស់លោក ទីត គេម័រ បានធ្វើការសន្និដ្ឋានថា «ឯកសារទាំងនេះអាចធ្វើជាភស្តុតាងបញ្ជាក់ពីការដឹងឮពីអំពើឃោរឃៅ ដែលជាការទទួលខុសត្រូវមួយផ្នែករបស់មន្ត្រីមួយចំនួនដូចជា នួន ជា និង អៀង សារី ។ អំពើឃោរឃៅនិយាយនៅពេលនេះគឺរួមមានការសម្លាប់ប្រជាជនកម្ពុជានិងអ្នកទោសព្រមទាំងជនជាតិវៀតណាមដោយហេតុផលនយោបាយ ហើយជម្លោះប្រដាប់អាវុធរវាងកម្ពុជាប្រជាធិបតេយ្យនិងប្រទេសវៀតណាមអាចនាំទៅដល់បទឧក្រិដ្ឋកម្មសង្គ្រាម ។ កែ ពក អាចក្លាយជាមនុស្សដែលមានការពាក់ព័ន្ធផ្ទាល់ជាងគេក្នុងករណីនេះ ។

ដូចជាចម្លើយសារភាពនិងឯកសារក្នុងរបបកម្ពុជាប្រជាធិបតេយ្យដូច្នេះដែរ ការទាក់ទងទាំងអស់នោះតែងតែមានប្រើពាក្យបញ្ចៀងផ្សេងៗដូចជា «កម្ទេច» និង «សម្អាត» ដើម្បីជំនួសពាក្យ «សម្លាប់» ។ ប៉ុន្តែមានពេលខ្លះក៏មានប្រើឃ្លាមួយដែលមានចែងក្នុងរដ្ឋធម្មនុញ្ញជំនួសវិញ«ការដាក់ទណ្ឌកម្មពីថ្នាក់លើ» ។ មានពេលខ្លះ ប៉ុល ពត ត្រូវបានប្រើ «អក្សរកាត់ឬឈ្មោះប្រែ ០០៩» ។ ប៉ុន្តែជាញឹកញាប់ គេប្រើលេខកូដសម្គាល់ ៨៧០ ឬមន្ទីរ៨៧០ ដើម្បីសម្គាល់ «បង» ឬ «អង្គការ» ឬក៏ «គណៈកម្មាធិការមជ្ឈិមបក្ស» ។ គ្រប់ករណីទាំងអស់នៅក្នុងការទាក់ទងគ្នា តែងតែមានកំណត់សម្គាល់ថាបានចម្លងជូនទៅមនុស្សមួយចំនួន ឬសមាជិកនៃគណៈកម្មការអចិន្ត្រៃយ៍ដែលរស់នៅក្នុងរដ្ឋធានីភ្នំពេញៈ ប៉ុល ពត ខ្លួនឯងផ្ទាល់ «ត្រូវបានហៅថា អ៊ឹ» នួន ជា ហៅថា «អ៊ឹ នួន» អៀង សារី ហៅថា «បងវ៉ាន់» វន វេត ហៅថា «បងវន» ហើយ សុន សេន ហៅថា «បងខៀវ» ។ នៅក្នុងការទាក់ទងទាំងនោះអ្នកទាំង៥នាក់មិនដឹងជាមួយណាមានអំណាចធ្វើការសម្រេចចិត្តទៅលើបញ្ហាផ្សេងៗ ឬសម្រេចចិត្តនៅក្នុងវេទិកាណាឡើយ ប៉ុន្តែវាហាក់ដូចជាបង្ហាញច្បាស់ថា ទាំង នួន ជា និង អៀង សារី សុទ្ធតែមានចំណែកនៅក្នុងក្រុមក្តាប់ពត៌មានដែលរួមមានទាំង ប៉ុល ពត, វន វេត និង សុន សេន ផង ។ ក្នុងករណីផ្សេងៗទៀត ឯកសារទាំងនេះមាននិយាយអំពីអំណាចបញ្ជាឲ្យមានការកាប់សម្លាប់មនុស្ស ។

ឧទាហរណ៍មុនដំបូងគេនេះគឺ ទូរលេខចុះថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៧៦ ពីកម្មាភិបាលដែលចុះហត្ថលេខាខ្លួនឯងដាក់ឈ្មោះថា ឆុន «ប្រហែលជាឈ្មោះប្រែរបស់អតីតលេខាតំបន់


ង៉ែត ពូន


ជក សំអាត


យាត សុក


ជង ចាន់


ហន ទូច

បូញ៉ា សោភីម» ជូនចំពោះ «ប៉ុល» ។ នៅក្នុងទូរលេខនោះមានចំណារមួយថា ចម្លងជូន នួន, ខៀវ និង វ៉ាន់ ហើយរាយការណ៍អំពីការចាប់ខ្លួនជនជាតិវៀតណាមនិងកម្ពុជានៅក្នុងតំបន់២៤ ដែលមានព្រំប្រទល់ជាប់នឹងប្រទេសវៀតណាម ។ ទូរលេខបានសរសេរថា នៅថ្ងៃទី១៣ ខែមីនា កងស្រុកបាន «ចាប់ខ្លួនជនជាតិវៀតណាម៥នាក់ដែលបានលាក់ខ្លួននៅក្នុងព្រៃ» ហើយក្នុងចំណោមអ្នកទាំង៥នាក់នោះមាន២នាក់ត្រូវបាន «បាញ់សម្លាប់» និង៣នាក់ទៀតត្រូវ «បានចាប់ខ្លួនទាំងរស់» ហើយឥឡូវត្រូវបាន «ឃុំឃាំងនៅឯសន្តិសុខ» ។ មានជនជាតិវៀតណាម៥នាក់ទៀតត្រូវបានចាប់ខ្លួនក្នុងរវាងថ្ងៃទី១៤ ដល់ ១៦ ខែមីនា ។ រីឯតំបន់ក៏ចាប់បានជនជាតិខ្មែរម្នាក់ដែលត្រូវបានចោទប្រកាន់ថា បានគប់គ្រាប់បែកនៅថ្ងៃទី៧ មីនា បណ្ដាលយុទ្ធជនម្នាក់ស្លាប់និងធ្វើឲ្យរបួសធ្ងន់ចំនួន៤នាក់ ។ របាយការណ៍បង្ហាញថា ឆុន «ជាភ្នាក់ងារសន្តិភាពនិយម» ហើយពន្យល់ថា «យើងវែវាពេលសួរចម្លើយអំពីខ្សែរយៈអន្តការ» ហើយតាមចម្លើយនេះបានរកឃើញ «ខ្សែរយៈចំនួនជាង២០នាក់នៅតាមមូលដ្ឋានស្រុកព្រះស្ដេច ដែលអ្នកទាំងនោះនៅមានខ្សែរយៈអន្តការច្រើនទៀតមកពីប្រទេសវៀតណាម» ។

នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៧៦ លេខារបស់តំបន់សុយ័ត ១០៣ ឈ្មោះ ប៉ូ ផាត ហៅ ហង់ ដែលក្រោយមកត្រូវបានសម្អាត បានផ្ញើទូរលេខមួយច្បាប់ទៅ «បងជាទីស្រលាញ់និងគោរព» ដែលប្រាកដជា ប៉ុល ពត ។ ទូរលេខប្រហាក់ប្រហែលគ្នានេះដែរត្រូវបានចម្លងជូន នួន ជា សុន សេន និង អៀង សារី ។ ទូរលេខនេះបានរាយការណ៍អំពីឧបទ្ទវហេតុមួយនាថ្ងៃ១២ ខែកក្កដា ពេលដែលមានបញ្ជាពីយោធាតំបន់ឲ្យបញ្ជូនយុទ្ធជន៣នាក់ឲ្យយករបាយការណ៍មួយទៅចែកចាយ ។ ពេលនោះមានយុទ្ធជនម្នាក់ក៏បកក្រោយ ហើយបាញ់តម្រង់ទៅលើយុទ្ធជនពីរនាក់ទៀត ហើយក៏រត់បាត់ទៅ ។ របាយការណ៍នោះបានសន្និដ្ឋានថា យុទ្ធជនម្នាក់នោះគឺស្ថិតនៅក្នុងក្រុមមួយមានគ្នា១១នាក់ផ្សេងទៀតដែលត្រូវបានទទួលការទាក់ទងពីក្រុម «សន្តិភាពនិយមសេ.អ៊ី.អា» ស្ថិតនៅក្នុងប្រទេសថៃ ។ ក្រុមនេះបានបំពាក់បំប៉នយុទ្ធជនទាំងនេះឲ្យ «កម្ទេចកម្មាភិបាល និងកុំឲ្យរស់នៅជាមួយពួកកុម្មុយនិស្តដោយគ្មានសេរីភាពនិងប្រាក់ខែគ្រប់គ្រាន់» ។ ភ័ស្តុតាងសម្រាប់បញ្ជាក់ក្នុងករណីនេះគឺថា ក្រុមបដិបក្ខនេះបាននិយាយថា «ទោះជាខ្លួនខំធ្វើការគ្មានឈប់យ៉ាងណាក្ដីក៏អង្គការនៅតែថាខ្លួនធ្វើខុសដដែល» ។ របាយការណ៍បានកត់សម្គាល់ថា យុទ្ធជន១០នាក់នៃក្រុមនេះត្រូវបាន «កម្ទេច» ទាំងខ្សែៗតាមការសន្និដ្ឋានដំបូងរបស់តំបន់ ប៉ុន្តែសន្យាថា នឹងមាន «ការស៊ើបអង្កេតជាលម្អិតបន្តទៀត» ។

ឯកសារផ្សេងៗទៀតមិនមានលក្ខណៈច្បាស់លាស់ដូចនេះឡើយ ប៉ុន្តែរាយការណ៍អំពីការចាប់ខ្លួននិងការធ្វើវិសុទ្ធកម្ម បង្ហាញពីការរើសអើង ជាពិសេសទៅលើសហគមន៍ជនជាតិចាម ។

នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៧៥ កម្មាភិបាលឈ្មោះ ឆុន បានផ្ញើទូរលេខមួយច្បាប់ដែលចម្លងជូន នួន ជា រួចហើយទៅឲ្យ ប៉ុល ពត រាយការណ៍អំពីការផ្ទេរប្រជាជនទៅភូមិភាគឧត្តរ ។ ទូរលេខមានរាយការណ៍អំពីបញ្ហាផ្សេងៗដែលត្រូវបានលើកឡើងទាក់ទិនទៅនឹង «បញ្ហាដកប្រជាជនពីបូព៌ាទៅឲ្យឧត្តរ» ពីព្រោះ


ការដ្ឋានលើកទំនប់ខ្មែរក្រហម

«មានបញ្ហាខ្វះមិនឯកភាពគ្នា ហើយមិនគោរពតាមមតិណែនាំរបស់អង្គការ» ។ ដោយឡែកទោះបីជា «ចំនួនទាំងអស់» នៃប្រជាជនដែលត្រូវតែផ្លាស់ប្តូរទីកន្លែងនិងដឹកជញ្ជូនមកពីភូមិភាគបូព៌ា តំបន់២១ ទៅកាន់ភូមិភាគឧត្តរ ត្រូវបានប្រគល់នៅឯចំណុចទទួលក៏ដោយ ប៉ុន្តែភូមិភាគឧត្តរបាន «បដិសេធយ៉ាងដាច់ខាត» មិនទទួលយកប្រជាជនឥស្លាមទេ យកតែខ្មែរសុទ្ធ ។ បញ្ហានេះមានការផ្ទុយស្រឡះពីគ្នាជាមួយនឹងសេចក្តីសម្រេចចិត្តធ្វើឡើងនៅក្នុងកិច្ចប្រជុំដែល «ចែងថា... ចំណែកពាយ័ព្យ និងឧត្តរត្រូវទទួលដើម្បីបំបែកប្រជាជនឥស្លាមចេញពីដងទន្លេមេគង្គ» ។ ទូរលេខផ្ញើទៅកាន់ ប៉ុល សង្កត់ធ្ងន់ថា «ដកនេះជាគោលការណ៍បំបែកដូចមតិបងបានពិភាក្សាជាមួយយើងខ្ញុំរួចស្រេចហើយ» ។ ខ្លឹមសាររបស់ទូរលេខនេះគឺការងឿងឆ្ងល់ថាតើ «បញ្ហានេះប្រហែលជាសមមិត្ត ពក មិនបានដឹងដែរទេមើលទៅ» ។ ឆុន បានពន្យល់ថា ខ្លួនបានបង្អាក់ដំណើររបស់ជនជាតិចាមដើម្បីរង់ចាំគំនិតរបស់ ប៉ុល និងគំនិតផ្សេងៗទៀតមកពីភូមិភាគឧត្តរ ហើយសុំឲ្យគាត់ «សម្រេចថាតើត្រូវដោះស្រាយរឿងនេះរបៀបណា» ។

គ្មានឯកសារណាមួយបញ្ជាក់អំពីថាតើបញ្ហានេះត្រូវបានដោះស្រាយចេញដោយរបៀបណាឡើយ ។ ប៉ុន្តែនៅថ្ងៃទី២ ខែមេសា ឆ្នាំ១៩៧៦ ពក បានផ្ញើទូរលេខមួយទៅកាន់ ប៉ុល ហើយចម្លងជូន នួន និង សុន សេន ។ ទូរលេខនេះបង្ហាញពីការព្រួយបារម្ភរបស់ខ្លួនចំពោះការពាក់ពន្ធ័ជាមួយប្រជាជនចាម អតីតទាហានសាធារណរដ្ឋ កម្មាភិបាលដែលត្រូវបានដេញចេញ និងដែលបានធ្វើសកម្មភាពប្រឆាំង ។ ទូរលេខនេះមានផលប៉ះពាល់ដល់ចំណាត់វិធានការដែល ពក កំពុងពិភាក្សាគ្នារកមធ្យោបាយដោះស្រាយ ។ ពក បានប្រកាសថា ទោះជា «សភាពការណ៍ខ្មាំងនៅភូមិភាគឧត្តរទាំងមូលជាមូលដ្ឋានខ្មាំងពុំទាន់ធ្វើសកម្មភាពអ្វីខ្លាំងក្លាដែលប៉ះពាល់ប្រជាជន ក៏ដូចជាចលនាបង្កបង្កើនផលទេ ជារួមសភាពការណ៍នឹងន តែទន្ទឹមនឹងនេះវាក៏មានធ្វើសកម្មភាពខ្លះៗដែរ ដូចជាវាឃោសនាថាបដិវត្តមានការតឹងតែង វាឃោសនាទប់ទល់សហករណ៍ ឃោសនាទប់ទល់នឹងការលើកភ្លឺស្រែថ្មី ក៏ដូចជាការឃោសនាអំពីការអត់ឃ្លាន» ប៉ុន្តែវាក៏មានបញ្ហាដែរ ។ ដូច្នេះហើយបានជាមានការអនុវត្តសកម្មភាពផ្សេងៗដូចជាការឃោសនាថា បដិវត្តន៍គឺម៉ឺងម៉ាត់ដាច់ខាតណាស់ ។ មានការឃោសនាបំផុសកុំឲ្យមានសហករណ៍ កុំឲ្យមានការលើកភ្លឺស្រែ និងការឃោសនាអំពីគ្រោះទុរ្ភិក្ស និងការអត់ឃ្លាន ។ ពក មានការព្រួយបារម្ភអំពីគំនិតនយោបាយផ្ទុយគ្នា ហើយបានសម្រេចចាត់វិធានការបង្ក្រាបរឿងនេះ ។ ពក បានពន្យល់ថា ដោយឡែកនៅស្រុកចម្ការលើតំបន់៤២ «ពួកអាខ្មាំងជាទាហានចាស់រួមផ្សំជាមួយចាមនិងពួកអតីតប្រធានក្រុមសហករណ៍បានយករូបថតអាណុល និងសេចក្តីថ្លែងការណ៍របស់អាណុល នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ [ទម្លាក់សម្តេច សីហនុ ពីតំណែង] ទៅបិទនឹងដើមឈើ» ។ ពក បានជម្រាប ប៉ុល ថា «យើងបានចាប់ពួកអាសមាសភាពជាអតីតប្រធានក្រុមសហករណ៍ចាស់» ហើយបានណែនាំឲ្យខាងតំបន់ «យកចិត្តទុកដាក់ប្រុងប្រយ័ត្នចំពោះរឿងនេះ» ។ ពក បានពន្យល់ថា ខាងភូមិភាគមានការជឿជាក់ថា «មានខ្មែរបង្កប់នៅក្នុងផ្ទៃក្នុង» ។ ពក បានសន្យាថា «យើងបានតាមដានពិនិត្យតទៅទៀត ឃើញសកម្មភាពយ៉ាងណា យើងនឹងមានវិធានការតាមការជាក់ស្តែងទៀត» ។

ករណីប្រហាក់ប្រហែលនេះដែរទាក់ទងនឹងយោធភូមិភាគ ទោះបីជាមានការបោសសម្អាតហើយបោសសម្អាតទៀត កសាងហើយកសាងទៀត និងឃោសនាហើយឃោសនាទៀត ទាំងខាងនយោបាយ សតិអារម្មណ៍ និងការចាត់តាំងយ៉ាងណាក៏ដោយ ក៏យុទ្ធជនមួយចំនួនតូចដែលជាបណ្តាញខ្មាំងបង្កប់ពីមុនមកនៅតែបង្កបញ្ហាដដែល ។ មានម្នាក់ទើបតែបានរត់ចោលជួរទៅប្រទេសថៃ ហើយក្រោយមកភូមិភាគបាន «ដកសមាសភាពមិនល្អនិងពួកសេរីពីកងទ័ព...មកឲ្យបង្កបង្កើនផលនៅសមរភូមិក្រោយវិញ» ។ លើសពីនេះទៀត «ចំពោះបញ្ហានេះ» ភូមិភាគ «បានកំពុងតែធ្វើការកសាងនិងបោសសម្អាតសមាសភាពជាបន្តបន្ទាប់» ។

**(នៅមានត) ស្ទីវ ហេឌ័រ**

## ទ្រឹស្តីខ្មែរក្រហម

◆ **ចក្រពត្តិនិយមទាខ្លាំងតែសំបកក្រៅ តែភាពខាងក្នុងខ្សោយពីព្រោះប្រជាជន មិនគាំទ្រទា។**

*(ដកស្រង់ចេញពីសៀវភៅភោញ៉ុក ទំព័រ៧៧)*

# វិធីបួនយ៉ាងក្នុងការវិនិច្ឆ័យអំពើទារុណកម្មប្រព្រឹត្តឡើង នៅក្នុងសម័យខ្មែរក្រហម

មានភ័ស្តុតាងសំខាន់ៗបង្ហាញថា អំពើទារុណកម្មត្រូវបានប្រព្រឹត្តឡើងក្នុងទ្រង់ទ្រាយធំនៅក្នុងប្រទេសកម្ពុជាក្នុងរបបខ្មែរក្រហម ។ សៀវភៅនិពន្ធដោយប្រវត្តិវិទូ ដេវីដ ឆេនដល័រ ដែលមានចំណងជើងថា «សម្លេងពីមន្ទីរស-២១» គឺជាការសិក្សាដ៏ទូលំទូលាយមួយស្តីអំពីឯកសារនៅទួលស្លែងដែលបង្ហាញថា ការធ្វើទារុណកម្មគឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពផ្សេងៗទៀតធ្វើឡើងនៅក្នុងគុកសម្ងាត់របស់ ប៉ុល ពត ។ ប្រវត្តិរបស់ វ៉ាន់ ណាត អតីតអ្នកទោសគុកទួលស្លែងដែលរួចរស់ជីវិតនិងប្រភពផ្សេងៗទៀត បានបង្ហាញប្រាប់យើងថា អ្នកទោសត្រូវបានរងអំពើទារុណកម្មនៅតាមខេត្តដែរ ។

ជាពិសេសទិន្នន័យប្រមូលដោយមជ្ឈមណ្ឌលឯកសារកម្ពុជាពេលចុះស្រាវជ្រាវនិងផែនទីរណ្តៅសាកសពប្រល័យពូជសាសន៍ទូទាំងប្រទេស បានបង្ហាញថា ប្រភេទផ្សេងៗនៃអំពើទារុណកម្មហាក់ដូចជាកើតឡើងជាទូទៅទៅហើយនៅតាមគុកភូមិភាគ តំបន់ និងស្រុកទូទាំងប្រទេសកម្ពុជា ដែលដំណើរការដោយសន្តិសុខខ្មែរក្រហម ។ របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងឆ្នាំកន្លងមកបង្ហាញថា «មានការរកឃើញដូចៗគ្នា៖ សាក្សីធ្វើជាកសិណចំពោះការធ្វើទារុណកម្ម និងឃាតកម្មដ៏ច្រើនហួសនិស្ស័យ ហើយសំណល់ភ័ស្តុតាងជារណ្តៅសាកសពរួមនិងអតីតគុកខ្មែរក្រហមផ្តល់នូវកសិណសាក្សីស្រាប់ដែលរាយប៉ាយនៅក្នុងប្រទេសកម្ពុជា គឺជាភ័ស្តុតាងជាក់ស្តែងនៃអំពើឧក្រិដ្ឋកម្ម ។ អំពើនេះកើតឡើងគ្រប់កន្លែងហើយមានលក្ខណៈដូចគ្នាយ៉ាងច្រើននៅទូទាំងប្រទេស ។ ករណីនេះបញ្ជាក់ថា អំពើគួរឲ្យភ័យរន្ធត់កើតមានច្រើន និងជាប្រព័ន្ធទៀតផង ដែលបំពេញលក្ខណៈវិនិច្ឆ័យមួយក្នុងនិយមន័យស្តីអំពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ» ។

ការវិនិច្ឆ័យទោសជនដែលទទួលខុសត្រូវចំពោះអំពើទារុណកម្មនៅក្នុងសម័យខ្មែរក្រហមមានលទ្ធភាពច្រើនដោយផ្អែកទៅលើមូលដ្ឋានជាច្រើនយ៉ាង ។ នៅក្នុងអត្ថបទនេះ ខ្ញុំនឹងរៀបរាប់ពីមូលដ្ឋានច្បាប់ទាំងនេះ ព្រមទាំងបញ្ហាចម្បងៗនៃតម្រូវការរកភ័ស្តុតាងក្នុងការវិនិច្ឆ័យក្តី ។ ការពិភាក្សាដ៏លម្អិតនូវចំណុចទាំងនេះមិនអាចធ្វើទៅបានតាមរយៈអត្ថបទខ្លីនេះទេ ។ អ្វីដែលសរសេរនៅទីនេះមិនលើសពីគ្រោងច្បាប់ធំជាគោលៗមួយដែលអាចយកមកអនុវត្តបានចំពោះសភាពការណ៍នៅប្រទេសកម្ពុជា ។ ខ្ញុំភ្ជាប់អត្ថបទនេះទៅនឹងដែនសមត្ថកិច្ចរបស់ការិយាល័យចៅក្រម







វិសាមញ្ញនៅក្នុងតុលាការ ដូចដែលបានចែងនៅក្នុងពង្រាងច្បាប់ស្តីពីការបង្កើតការិយាល័យវិសាមញ្ញនៅក្នុងតុលាការនៃប្រទេសកម្ពុជា ដើម្បីវិនិច្ឆ័យរឿងក្តីបទឧក្រិដ្ឋកម្មប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពង្រាងធ្វើនៅក្នុងខែមករា ឆ្នាំ២០០០) ។

**ចំណុចខាងក្រោមនេះគឺជាលទ្ធភាពក្នុងការវិនិច្ឆ័យក្តីអំពើ**

**ទារុណកម្ម** ៖

១) ទារុណកម្មជាធាតុផ្សំមួយនៃឧក្រិដ្ឋកម្មសង្គ្រាមក្រោមអនុសញ្ញាក្រុងហ្សឺណែវ

២) ទារុណកម្មជាធាតុផ្សំមួយនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

៣) ទារុណកម្មជាឧក្រិដ្ឋកម្មសារធាតុមួយក្រោមច្បាប់អន្តរជាតិ

៤) ទារុណកម្មជាឧក្រិដ្ឋកម្មសារធាតុមួយក្រោមពង្រាងច្បាប់ក្នុងស្រុករបស់ប្រទេសកម្ពុជា

លទ្ធភាពនីមួយៗសុទ្ធតែមានគុណសម្បត្តិ និងគុណវិបត្តិផ្សេងៗគ្នាដែលទាក់ទងជាពិសេសទៅនឹងបញ្ហាភ័ស្តុតាង ពីព្រោះវិធានច្បាប់ភ័ស្តុតាងសំខាន់មានដែនអនុវត្តច្បាស់លាស់ ឬអ្វីដែលហៅថា ខ្សែបន្ទាត់នៃទំហំដែលអាចយកច្បាប់ទាំងនេះមកអនុវត្តបាន ។

## ១) ទារុណកម្មជាធាតុផ្សំមួយនៃឧក្រិដ្ឋកម្មសង្គ្រាមក្រោមអនុសញ្ញាក្រុងហ្សឺណែវ

ប្រទេសកម្ពុជាគឺជាភាគីមួយនៅក្នុងអនុសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៤៩ ។ អនុសញ្ញាទាំងនេះអនុវត្តចំពោះ «ករណីទាំងអស់នៃសង្គ្រាមប្រកាស ឬក៏ជម្លោះប្រដាប់អាវុធដែលអាចកើតមានឡើងរវាងភាគីពីរ ឬក៏ច្រើន នៃភាគីចុះកិច្ចសន្យាក្នុងអនុសញ្ញា ទោះជាថារដ្ឋដែលមានសង្គ្រាមកើតឡើងមិនត្រូវបានទទួលស្គាល់ដោយអនុសញ្ញាណាមួយក៏ដោយ» ។ ដូច្នេះដែនសមត្ថកិច្ចនៃអនុសញ្ញាគឺកំណត់ចំពោះជម្លោះប្រដាប់អាវុធ (អន្តរជាតិ) ទោះបីជាមាត្រា៣ ទាក់ទងនឹងជម្លោះអន្តរជាតិក៏ដោយ ប៉ុន្តែគ្មានយន្តការអនុវត្តច្បាប់ចំពោះបទល្មើសនៅក្នុងករណីនេះឡើយ ។ អនុសញ្ញានេះគឺអនុវត្តកម្រិតចំពោះ «ទ្រព្យសម្បត្តិ ឬក៏បុគ្គលការពារដោយច្បាប់» ក្រោមអនុសញ្ញាផ្សេងៗគ្នាដែលរួមមានសមាជិកនៃកងកម្លាំងប្រដាប់អាវុធរបួស ឬឈឺ, ឈ្លើយសង្គ្រាម និងជនស៊ីវិលដែលធ្លាក់ទៅក្នុងដៃរបស់ភាគីបង្កជម្លោះ ឬប្រទេសដែលកាន់កាប់ដែលជនរងគ្រោះពុំមែនជាពលរដ្ឋរបស់ប្រទេសនោះ ។

«ខ» សំខាន់មួយនៃអនុសញ្ញាចែងថា ភាគីរដ្ឋមានភារកិច្ចកាត់ទោសបុគ្គលដែលសង្ស័យថាបាន«ប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ» ដែលមានចែងនៅក្នុងអនុសញ្ញាដោយមិនគិតពីសញ្ជាតិឡើយ ។ ការហាមប្រាមមួយទៀតដែលចែងនៅក្នុងអនុសញ្ញាគឺ «អំពើឃោរឃៅប៉ះពាល់ដល់ជីវិតឬបុគ្គល ជាពិសេសអំពើឃាតកម្មគ្រប់ប្រភេទ ការបំផ្លាញទ្រព្យសម្បត្តិសាធារណៈ ការធ្វើទុក្ខបុកម្នេញ និងអំពើទារុណកម្ម នៅគ្រប់ពេលវេលា និងគ្រប់ទីកន្លែងទាំងអស់» ។ ការប្រព្រឹត្តនូវអំពើណាមួយក្នុងចំណោមអំពើទាំងនេះគឺត្រូវបានចាត់ទុកថាបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ ហើយអ្នកដែលត្រូវតែទទួលខុសត្រូវចំពោះមុខច្បាប់ ។ សំណួរមួយដែលត្រូវឆ្លើយគឺថា តើ «ខ» ផ្សេងៗនៅក្នុងអនុសញ្ញាអាចអនុវត្តបានចំពោះសភាពការណ៍ជាក់ស្តែងនៅក្នុងប្រទេសកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ? តើមានអំពើទារុណកម្មត្រូវបានធ្វើឡើងនៅក្នុងជម្លោះប្រដាប់អាវុធជាមួយរដ្ឋដទៃទៀតឬទេ? របាយការណ៍របស់ក្រុមជំនាញការដែលត្រូវបានសរសេរដោយមានការអនុលោមតាមសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ៥២/១៣៥ បានឆ្លើយនឹងសំណួរនេះក្នុងលក្ខណៈវិជ្ជមានដូចតទៅនេះ ៖

«ឯកសារប្រវត្តិសាស្ត្របានបង្ហាញថា ជម្លោះប្រដាប់អាវុធរវាងប្រទេសវៀតណាមនិងប្រទេសកម្ពុជាបានចាប់ផ្តើមនៅខែកញ្ញា ឆ្នាំ១៩៧៧ និងប្រហែលជាមុននេះទៀតផង ។ ការប៉ះទង្គិចនៅតាមព្រំដែនក្នុងខែឧសភា ឆ្នាំ១៩៧៥ និងការបន្តកើតឡើងនូវឧប្បត្តិហេតុផ្សេងៗឥតឈប់ ជាហេតុផលដ៏មាំក្នុងការយកអនុវត្តអនុសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៤៩ ក្នុងទំនាក់ទំនងរវាងប្រទេសកម្ពុជានិងប្រទេសវៀតណាមក្នុងអំឡុងពេលជិតពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ ។ ជាពិសេសកងទ័ពកម្ពុជាបានប្រព្រឹត្តការកាប់សម្លាប់ ទារុណកម្ម ឬអំពើអមនុស្សធម៌ ដោយចេតនា ការបង្កការឈឺចាប់ ខ្លោចផ្សា ចាប់ដោយចេតនា ការនិរទេសឬឃុំឃាំងដោយខុសច្បាប់ និងការបំផ្លាញទ្រព្យសម្បត្តិ» ។ ជនដែលទទួលខុសត្រូវចំពោះអំពើទារុណកម្មប្រឆាំងនឹងក្រុមដែលការពារដោយច្បាប់នៅក្រោមអនុសញ្ញានៅក្នុងជម្លោះប្រដាប់អាវុធរវាងកម្ពុជាប្រជាធិបតេយ្យ និងប្រទេសវៀតណាម អាចយកមកកាត់ទោសក្នុងនាមជាជនដែលដល់ «ប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ» ។ ***(នៅមានត)*** **យ៉ន ខ៉ាន់ ត្រឹនធីន**

# រឿងក្តីរបស់អ៊ីស្រាអែល និង អេច្មក្អាន់

នៅដើមទសវត្សរ៍ឆ្នាំ៦០ ការជំនុំជម្រះក្តីដ៏ល្បីល្បាញលើពិភពលោកមួយបន្ទាប់ពីការកាត់ទោសពួកហ្វាស៊ីសណាហ្ស៊ីនៅទីក្រុងនូរិមប៊ឺក គឺជាការកាត់ក្តីលើរូបលោក អាឌុល អេច្មក្អាន់ ក្នុងប្រទេសអ៊ីស្រាអែល ក្នុងរវាងឆ្នាំ១៩៦១ដល់១៩៦២ ។ លោក អេច្មក្អាន់ ដែលជាអតីតប្រធានអង្គភាពប៉ូលិសសម្ងាត់ក្នុងទីក្រុងប៊ែរឡាំង ដែលទទួលខុសត្រូវចំពោះផែនការ «ដំណោះស្រាយចុងក្រោយ» «ការសម្លាប់រង្គាលនូវប្រជាជនជ្វីហ្វក្នុងប្រទេសអាល្លឺម៉ង់ និងទឹកដីក្រោមការកាន់កាប់ដោយអាល្លឺម៉ង់ទាំងឡាយ» បានរត់គេចពីការចាប់ខ្លួននៅពេលចប់សង្គ្រាម ហើយបានលាក់បំពួនរស់នៅក្នុងប្រទេសអាហ្សង់ទីន ចាប់តាំងពីឆ្នាំ១៩៥០ ដោយដូរឈ្មោះថ្មី ។ នៅខែឧសភា ឆ្នាំ១៩៦០ អេច្មក្អាន់ ត្រូវបានចាប់ពង្រត់ដោយភ្នាក់ងារសន្តិសុខប្រទេសអ៊ីស្រាអែល ហើយត្រូវបាននាំមកប្រទេសអ៊ីស្រាអែល ។ ប្រទេសអ៊ីស្រាអែលបានប្រកាសប្រាប់ពិភពលោកថាខ្លួននឹងយក អេច្មក្អាន់ ទៅជំនុំជម្រះក្តីចំពោះតួនាទីរបស់គាត់ក្នុងការអនុវត្តផែនការ «ដំណោះស្រាយចុងក្រោយ» ។ អេច្មក្អាន់ ត្រូវបានកាត់ក្តីក្រោមច្បាប់ដាក់ទណ្ឌកម្មលើពួកណាហ្ស៊ីនិងបក្សពួកណាហ្ស៊ីរបស់ប្រទេសអ៊ីស្រាអែល ។ ច្បាប់នេះកំណត់ការដាក់ទណ្ឌកម្មចំពោះបទឧក្រិដ្ឋប្រឆាំងនឹងប្រជាជនជ្វីហ្វ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនិងឧក្រិដ្ឋកម្មសង្គ្រាម ។ ផ្នែក 1(ខ) នៃច្បាប់នេះបានកំណត់និយមន័យបទល្មើសទាំងឡាយដូចតទៅនេះ÷

«ឧក្រិដ្ឋកម្មប្រឆាំងជនជាតិជ្វីហ្វ» មានន័យថា រាល់អំពើឧក្រិដ្ឋណាមួយដែលត្រូវបានប្រព្រឹត្តដោយមានចេតនាបំផ្លិចបំផ្លាញជនជាតិជ្វីហ្វទាំងស្រុង ឬដោយផ្នែកៈ ១) ការសម្លាប់រង្គាលនូវជនជាតិជ្វីហ្វ, ២) បង្កការឈឺចាប់ និងការខូចខាតជាដំណាំផ្នែករាងកាយនិងសតិបញ្ញាចំពោះជនជាតិជ្វីហ្វ, ៣) ដាក់ឲ្យរស់នៅក្នុងស្ថានភាពរស់នៅមិនសមស្របសំដៅបង្កភាពមហន្តរាយដល់សង្គមរស់នៅរបស់ជនជាតិជ្វីហ្វ, ៤) ដាក់បង្ខំនូវវិធានការនានាដែលបង្ការមិនឲ្យជនជាតិជ្វីហ្វផ្តល់កំណើតទារកក្នុងសង្គម ។

«ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ» មានន័យថាជាអំពើណាមួយក្នុងចំណោមអំពើដូចតទៅនេះ÷ អំពើមនុស្សឃាត ការសម្លាប់បំផុតពូជ អំពើទាសភាព ការបង្អត់អាហារ ឬការនិរទេស និងការប្រព្រឹត្តអមនុស្សធម៌ដទៃទៀតដែលត្រូវបានប្រព្រឹត្តមកលើប្រជាជនស៊ីវិល និងការធ្វើទុក្ខបុកម្នេញនានាដោយសារមូលហេតុនយោបាយ សញ្ជាតិ ពូជសាសន៍ ឬសាសនា ។

ច្បាប់នេះបានផ្សារភ្ជាប់ជាសំខាន់នូវបទល្មើសនៃឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅតុលាការនូរិមប៊ឺកជាមួយនឹងបទឧក្រិដ្ឋច្បាស់លាស់ជាងនេះគឺឧក្រិដ្ឋកម្មប្រឆាំងនឹងប្រជាជនជ្វីហ្វ ។ ឧក្រិដ្ឋកម្មប្រឆាំងនឹងប្រជាជនជ្វីហ្វ បានខ្ចីចំណុចខ្លះនៃនិយមន័យអំពើប្រល័យពូជសាសន៍ពីអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ។ ហេតុដូច្នេះហើយច្បាប់នេះអនុញ្ញាតឲ្យប្រទេសអ៊ីស្រាអែលយកបុគ្គលដែលបានប្រព្រឹត្តបទល្មើសនៃអំពើប្រល័យពូជសាសន៍ទាំងឡាយមកលើប្រជាជនជ្វីហ្វ មកធ្វើការកាត់ទោសដោយតុលាការក្នុងស្រុករបស់ខ្លួន ។

មិនតែប៉ុណ្ណោះ ច្បាប់ដាក់ទណ្ឌកម្មបានចែងអំពីការដាក់ទណ្ឌកម្មចំពោះអ្នកទាំងឡាយដែលបានផ្តល់សេវាកម្មក្នុង «អង្គការរបស់សត្រូវ» ដូចដែលបានប្រកាសដោយតុលាការយោធាអន្តរជាតិនៅនូរិមប៊ឺក (ផ្នែក៣ «ក» និង «ខ») ហើយបានបដិសេធយ៉ាងច្បាស់លាស់នូវការយក «បញ្ជាថ្នាក់លើ» មកធ្វើជារបាំងការពារកំហុសដែលបានប្រព្រឹត្ត (ផ្នែកទី១៩) ។ អេច្មក្អាន់ ត្រូវបានតុលាការអ៊ីស្រាអែលចេញដីកាចោទប្រកាន់លើ៤ករណីនៃឧក្រិដ្ឋកម្មប្រឆាំងប្រជាជនជ្វីហ្វ ពីបទមានមុខនាទីក្នុងកិច្ចការគ្រប់គ្រងលើផែនការ «ដំណោះស្រាយចុងក្រោយ» ដាក់ឲ្យប្រជាជនជ្វីហ្វរស់នៅក្នុងសភាពដែលអាចបង្កឲ្យមានមហន្តរាយដល់សង្គមជីវភាពរស់នៅ បង្កគ្រោះថ្នាក់ធ្ងន់ធ្ងរចំពោះប្រជាជនជ្វីហ្វដោយការបង្ខំឲ្យធ្វើទាសករ ការបង្អត់អាហារ ការធ្វើទុក្ខបុកម្នេញ ការនិរទេសខ្លួន និងការចាប់ឃុំឃាំង និងពីបទចាត់វិធានការនានាបង្ខំមិនឲ្យប្រជាជនជ្វីហ្វផ្តល់កំណើតទារកក្នុង

សង្គម ។ ករណីបទឧក្រិដ្ឋ៣ ដែលតុលាការនោះបានចោទប្រកាន់មកលើ អេច្ចម៉ាន់ ថាបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំង មនុស្សជាតិគឺអំពើមនុស្សឃាត ការសម្លាប់បំផុតពូជ និងការបង្ខំឲ្យធ្វើទាសករ ការនិរទេសប្រជាជនជ្វីហ្វ ការធ្វើទុក្ខបុកម្នេញ ប្រជាជនជ្វីហ្វ និងការប្លន់ទ្រព្យសម្បត្តិរបស់ប្រជាជនជ្វីហ្វ ។ ការចោទប្រកាន់មួយទៀតគឺឧក្រិដ្ឋកម្មសង្គ្រាម ។ អេច្ចម៉ាន់ ត្រូវបានចោទប្រកាន់ដោយគ្មានភស្តុតាងថា លោកបានប្រព្រឹត្តអំពើសាហាវឃោរឃៅ និរទេស និងការសម្លាប់ប្រជាជនជ្វីហ្វ ដែលជាម្ចាស់ទឹកដីនៃរដ្ឋដែលអាល្លឺម៉ង់កាន់កាប់ ហើយថាអំពើទាំងនេះជាឧក្រិដ្ឋកម្មសង្គ្រាម ។ ករណីបទល្មើស៤ទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានផ្តោតទៅលើការគ្រប់គ្រងរបស់ អេច្ចម៉ាន់ ដែលគាត់បញ្ជាឲ្យ «ជម្លៀស» និងសម្លាប់រង្គាលក្រុមជនស៊ីវិលប្រភេទដទៃទៀតរួមមានៈ ប៉ូឡូញ ស្លូវ៉ាក អេហ្ស៊ីប និងកូនចៅរបស់ប្រជាជនឆេកូស្លូវ៉ាគី នៅក្នុងភូមិលីឌីក ។ ករណីបទឧក្រិដ្ឋ៣ចុងក្រោយចោទមកលើ អេច្ចម៉ាន់ ថាជាសមាជិកក្នុងអង្គភាពប៉ូលិសសម្ងាត់របស់របបណាហ្ស៊ីអាល្លឺម៉ង់និងហ្គេស្តាប៉ូ ដែលជាអង្គភាពព្រហ្មទណ្ឌទាំងអស់ដែលត្រូវបានប្រកាសដោយធម្មនុញ្ញនៃតុលាការយោធាអន្តរជាតិ ។

ការចោទប្រកាន់ទាំងនេះ ត្រូវបានកត់ត្រាទុកជាឯកសារទាំងស្រុង ។ នៅក្នុងការការពារខ្លួន អេច្ចម៉ាន់ បានលើកឡើងនូវការជំទាស់ជាច្រើនចំពោះ÷

១) ដែនសមត្ថកិច្ចរបស់តុលាការអ៊ីស្រាអែលដោយផ្អែកលើគោលការណ៍ទាំងឡាយនៃច្បាប់អន្តរជាតិ រួមមានការហាមឃាត់ស្តីអំពីការធ្វើច្បាប់ជំនុំជម្រះក្រោយអង្គហេតុ (ex post facto) អធិបតេយ្យភាពដែនដី និងសកម្មភាពរបស់រដ្ឋ ។

២) ការចាប់ពង្រត់រូបគាត់ពីប្រទេសអាហ្សង់ទីនដោយគាត់ពុំមានការស្ម័គ្រចិត្ត ។

៣) ការពិតថារយៈពេលនៃដែនអជ្ញាយុកាលនៃប្រទេសអាហ្សង់ទីនបានផុតកំណត់ចំពោះអំពើដែលគាត់បានប្រព្រឹត្ត ។

គាត់បានធ្វើការអះអាងការពារខ្លួនបន្ថែមដូចតទៅនេះ÷

១) គាត់គ្រាន់តែអនុវត្តតាមបញ្ជាថ្នាក់លើ

២) ក្រុមប្រឹក្សាចៅក្រមដូចជាប្រជាជនជ្វីហ្វនេះ បើតាមចិត្តសាស្ត្រមិនអាចធ្វើការជំនុំជម្រះក្តីមកលើរូបគាត់ដោយយុត្តិធម៌បានទេ ។

ការជំទាស់នឹងការអះអាងការពារខ្លួនទាំងឡាយរបស់ អេច្ចម៉ាន់ ត្រូវបានច្រានចោលដោយតុលាការស្រុកនៃទីក្រុងយេរូសាឡឹម នៃប្រទេសអ៊ីស្រាអែល ក្នុងការចេញសាលក្រមរបស់ខ្លួនដែលរកឃើញថាជនចុងចោទមានកំហុសលើ១៥ករណីនៃបទល្មើស ហើយ អេច្ចម៉ាន់ ត្រូវបានកាត់ទោសប្រហារជីវិត ។

អេច្ចម៉ាន់ បានប្តឹងឧទ្ធរណ៍ទៅតុលាការកំពូលរបស់ប្រទេសអ៊ីស្រាអែល ដោយចោទប្រកាន់ពីភាពខ្វះដែនសមត្ថកិច្ច កង្វះសមត្ថភាពផ្នែកចិត្តសាស្ត្ររបស់តុលាការក្នុងការផ្តល់ឲ្យគាត់នូវការជំនុំជម្រះក្តីមួយយុត្តិធម៌ត្រឹមត្រូវ និងកំហុសរបស់តុលាការថ្នាក់ក្រោមក្នុងការដែលរកឃើញថា គាត់មានតួនាទីធំក្នុងបទឧក្រិដ្ឋដែលបានចោទប្រកាន់មកលើរូបគាត់ ។ តុលាការកំពូលបន្តទាត់ចោលរាល់ការអះអាងទាំងនេះ ។ តុលាការកំពូលចាប់ផ្តើមដោយបដិសេធការអះអាងទូលំទូលាយរបស់ជនចុងចោទដែលថា នៅពេលដែលច្បាប់អន្តរជាតិនិងច្បាប់ក្នុងស្រុកប៉ះទង្គិចគ្នា ច្បាប់អន្តរជាតិត្រូវតែឈ្នះ ។ តុលាការបានអះអាងថា ច្បាប់ទាំងឡាយត្រូវបានដោះស្រាយបំភ្លឺដើម្បីឆ្លើយតបទៅនឹងច្បាប់អន្តរជាតិ ប៉ុន្តែនៅក្នុងព្រឹត្តិការណ៍នៃជម្លោះដែលមិនអាចចៀសផុតលក្ខន្តិកៈនៃតុលាការក្នុងស្រុកឈ្នះ ។

បន្ទាប់មកតុលាការកំពូលក៏បានឆ្លើយយ៉ាងច្បាស់ចំពោះការអះអាងប្រឆាំងចំពោះបញ្ហាដែនសមត្ថកិច្ច ។ ក្នុងការឆ្លើយតបចំពោះទឡ្ហីករណ៍របស់ជនចុងចោទដែលថាច្បាប់ដាក់ទណ្ឌកម្មពួកណាហ្ស៊ី និងបក្សពួកណាហ្ស៊ី វាយរំលោភទៅលើគោលការណ៍ច្បាប់ដែលហាមឃាត់មិនឲ្យបង្កើតច្បាប់និតិប្រតិកម្ម (ច្បាប់ក្រោយអង្គហេតុ ex post facto) តុលាការអះអាងថា ទោះបីជាគោលការណ៍នេះនៅមានសុពលភាពជាគោលការណ៍ច្បាប់ទូទៅក៏ដោយ ក៏វាពុំចងកាតព្វកិច្ចច្បាប់តុលាការអន្តរជាតិកើតដោយទំនៀមទម្លាប់ ហើយក៏ជាតម្រូវការរបស់រដ្ឋធម្មនុញ្ញដែរ ។ ជាងនេះទៅទៀតចំពោះបញ្ហាចរិយាធម៌វិញ ច្បាប់នេះមិនដាក់ទណ្ឌកម្មលើបទល្មើសទាំងឡាយដែលបានទទួលស្គាល់ពីមុននោះទេ ។ ប៉ុន្តែផ្ទុយទៅវិញច្បាប់នេះអនុវត្តតែជាមួយ «ឧក្រិដ្ឋកម្មសាហាវ

ឃោរឃៅគួរឲ្យស្អប់ខ្ពើម» ដែលជនចុងចោទត្រូវតែបានដឹងរួចជាស្រេចហើយថាវាជាអំពើរំលោភលើតម្លៃសីលធម៌ជាសកលដែលបានចាក់ឫសគល់ជ្រៅក្នុងស្រទាប់មនុស្សលោក ។ មិនតែប៉ុណ្ណោះតុលាការបានអះអាងថា ពុំមានច្បាប់អន្តរជាតិកើតដោយទម្លាប់ហាមឃាត់ការតាក់តែងបង្កើតច្បាប់ព្រហ្មទណ្ឌដែលអាចអនុវត្តបានចំពោះបទល្មើសមួយ ដែលប្រព្រឹត្តដោយជនបរទេសម្នាក់នៅក្នុងប្រទេសមួយទៀតដែលមិនមែនជាប្រទេសរបស់ខ្លួន ដោយឈរលើមូលដ្ឋានអធិបតេយ្យដែនដីនោះទេ ។

ក្នុងការពិភាក្សាដ៏ទូលំទូលាយអំពីភាពស្របគ្នានៃច្បាប់ដាក់ទណ្ឌកម្មទៅនឹងគោលការណ៍ច្បាប់អន្តរជាតិ តុលាការកំពូលរបស់ប្រទេសអ៊ីស្រាអែលបានសង្កត់បញ្ជាក់ថា បទឧក្រិដ្ឋដែល អេចម៉ាន់ បានប្រព្រឹត្ត «ត្រូវចាត់ទុកថា....មានសណ្ឋានជាឧក្រិដ្ឋកម្មអន្តរជាតិដែលត្រូវបានហាមឃាត់ដោយច្បាប់ជាតិទាំងឡាយ ហើយដែលនាំឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល» ហើយបានបញ្ជាក់ទៀតថា «បើពិនិត្យលើលក្ខណៈសភាពទូទៅជាពិសេសនៃបទឧក្រិដ្ឋទាំងនេះ រដ្ឋនីមួយៗអាចមានសមត្ថកិច្ចធ្វើការជំនុំជម្រះក្តីនិងដាក់ទណ្ឌកម្មលើជនណាដែលចូលរួមក្នុងការប្រព្រឹត្តទាំងនេះ» ។

ចំពោះការចាប់ពង្រត់ អេចម៉ាន់ ពីប្រទេសអាហ្សង់ទីន តុលាការកំពូលបានគាំទ្រចំពោះសេចក្តីសម្រេចរបស់តុលាការស្រុកដែលថា ដោយសារការចាប់ពង្រត់នេះគ្រាន់តែរំលោភបំពានទៅលើសិទ្ធិរបស់ប្រទេសអាហ្សង់ទីន ក្នុងនាមជារដ្ឋមានអធិបតេយ្យភាពប៉ុណ្ណោះ ការដោះស្រាយរវាងប្រទេសអាហ្សង់ទីននិងអ៊ីស្រាអែលបានបញ្ចប់នូវវិវាទនេះ ហើយពុំមានមូលហេតុដែលត្រូវជំទាស់ដែនសមត្ថកិច្ចរបស់អ៊ីស្រាអែលឡើយ ។ តុលាការកំពូលក៏បានបដិសេធនូវទង្វើការពារដោយឈរលើមូលដ្ឋាន «ទង្វើរបស់រដ្ឋ» របស់ខ្លួន «មានន័យថា សកម្មភាពរបស់ អេចម៉ាន់ គឺជាសកម្មភាពជាផ្លូវការរបស់រដ្ឋ ហើយហេតុដូចនេះអំពើទាំងឡាយដែល អេចម៉ាន់ បានប្រព្រឹត្តមិនអាចយកមកដោះស្រាយតាមច្បាប់អន្តរជាតិបានឡើយ» ។ ជាទំនៀមទម្លាប់ច្បាប់អន្តរជាតិអនុវត្តតែចំពោះទំនាក់ទំនងនានារវាងរដ្ឋនិងរដ្ឋ ហើយមិនមែនអនុវត្តចំពោះអំពើរបស់បុគ្គលនោះឡើយ ហើយហេតុដូច្នេះហើយបុគ្គលទាំងឡាយពុំត្រូវបានដាក់ឲ្យទទួលខុសត្រូវក្រោមច្បាប់អន្តរជាតិដែលថាគោលការណ៍ច្បាប់មួយដែលមិនទទួលស្គាល់នៅក្រោមធម្មនុញ្ញនូរិមបឺក ។

ក្នុងពេលជំនុំជម្រះក្តី អេចម៉ាន់ បានប៉ុនប៉ងដោះសារយករួចខ្លួនដោយអះអាងថា គាត់បានប្រព្រឹត្តតែតាមបទបញ្ជារបស់ថ្នាក់លើប៉ុណ្ណោះ ប៉ុន្តែតុលាការក៏បានទាត់ចោលការអះអាងការពារនេះដែរ ដោយទាញហេតុផលថា អេចម៉ាន់ បានប្រព្រឹត្តដោយឯករាជ្យពុំមានអ្នកណាបញ្ជាឡើយក្នុងការអនុវត្តផែនការ «ដំណោះស្រាយចុងក្រោយ» ហើយថាច្បាប់អន្តរជាតិបានអនុញ្ញាតឲ្យដកចេញនូវការអះអាងការពារនៃបទបញ្ជាថ្នាក់លើ ។ ជាទីបញ្ចប់ តុលាការកំពូលបានបញ្ជាក់យ៉ាងខ្លីពីការគាំទ្ររបស់ខ្លួនចំពោះការបដិសេធរបស់តុលាការដំបូងរបស់អ៊ីស្រាអែល ចំពោះការអះអាងដោះសាររបស់លោក អេចម៉ាន់ ដែលថាចៅក្រមជនជាតិជ្វីហ្វពុំមានសមត្ថភាពខាងចិត្តសាស្ត្រដើម្បីធ្វើការជំនុំជម្រះក្តីដោយយុត្តិធម៌ត្រឹមត្រូវមកលើរូបគាត់ ។

នៅពេលនោះ តុលាការកំពូលបានបញ្ជាក់ជាថ្មីលើអង្គហេតុទាំងឡាយដោយគូសបញ្ជាក់ពីតួនាទីរបស់លោក អេចម៉ាន់ ក្នុងឋានានុក្រមនៃថ្នាក់ដឹកនាំរបស់របបណាហ្ស៊ី ការអនុវត្តដោយឯករាជ្យនូវនយោបាយប្រល័យពូជសាសន៍របស់គាត់ តួនាទីដ៏សកម្ម និងតួនាទីដែលគាត់ផ្ទាល់បានដឹងក្នុងការនិរទេសប្រជាជនជ្វីហ្វទៅជំរំប្រហារជីវិត ។ តុលាការកំពូលបានចេញសាលក្រមបញ្ជាក់ជាថ្មីពីការកាត់ទោសប្រហារជីវិត អេចម៉ាន់ ហើយគាត់ត្រូវបានប្រហារជីវិតនៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ១៩៦២ ។

**អេលីហ្សា ប៉ែត ខាន់ ស្អាក់**

## ពាក្យស្លោកខ្មែរក្រហម

◆ **កិច្ចការអ្វីដែលសត្រូវប្រឆាំងយើងត្រូវតែគាំទ្រ បើសត្រូវគាំទ្រយើងត្រូវតែប្រឆាំង។**

*(ដកស្រង់ចេញពីសៀវភៅ ញូក ទំព័រទី៧៨)*

◆ **សម្រុបនិងអោនលំទោន រៀនសូត្រពីមហាជន ផ្សារភ្ជាប់នឹងចំហរមហាជន ឋិតស្ថិតមហាជន។**

*((ដកស្រង់ចេញពីសៀវភៅ អ៊ីវ ទំព័រទី៧៤)*



# ការជំនុំជម្រះក្តីខ្មែរក្រហម

**កាសែតបាងកកប៉ុស្តិ៍ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០០**

បានរាយការណ៍ថា ឯកឧត្តមរដ្ឋមន្ត្រីការបរទេសនៃព្រះរាជាណាចក្រកម្ពុជា ហោ ណាំហុង បានមានប្រសាសន៍នាថ្ងៃពុធ ទី២៦ ខែកក្កដា ថាអង្គនីតិបញ្ញត្តិរបស់កម្ពុជានឹងលើកមកពិភាក្សាដេញដោលនាពេលឆាប់ៗ នេះនូវច្បាប់អនុញ្ញាតឲ្យមានការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិ ។ មានប្រសាសន៍ទៅកាន់អ្នកយកពត៌មានរ៉យទ័រ ឯកឧត្តម ហោ ណាំហុង ថ្លែងថា «ខ្ញុំគិតថាវានឹងមិនយូរពេកទេ យើងនឹងឃើញដំណើរការជំនុំជម្រះក្តីវិវត្តទៅមុខ» ។ តាមការប៉ាន់ស្មានមានចំនួនមនុស្សប្រមាណ១លាន៧សែននាក់ ត្រូវបានកាប់សម្លាប់ក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ ក្រោមរបបកុម្មុយនិស្តខ្មែរក្រហម ។ មកដល់ឥឡូវនេះពុំទាន់មានមេដឹកនាំខ្មែរក្រហមណាម្នាក់ហ៊ានចេញមុខក្នុងតុលាការឆ្លើយបំភ្លឺអំពើសម្លាប់រង្គាលដែលបង្កឲ្យមានវាលពិឃាតនៅកម្ពុជាឡើយ ។ ឯកឧត្តម ហោ ណាំហុង បន្តថា ជាបឋមច្បាប់ត្រូវតែបានអនុម័តដោយរដ្ឋសភានិងព្រឹទ្ធសភាសិន ។ «ក្រោយពីសភាផ្តល់សច្ចានុមតិហើយ យើងអាចចុះហត្ថលេខាលើអនុស្សារណៈនៃការយល់ព្រមជាមួយអង្គការសហប្រជាជាតិ រួចហើយយើងអាចបន្តដំណើរការទៅមុខទៀតបាន» ។ មានប្រសាសន៍នៅក្រៅវេទិកាស្តីអំពីសន្តិសុខតំបន់ ឯកឧត្តម ហោ ណាំហុង មិនបានបញ្ជាក់ពីពេលវេលាច្បាស់លាស់នៃការចាប់ផ្តើមការជំនុំជម្រះក្តីឡើយ ។

លោក ហេន កូរែល ប្រធានក្រុមប្រឹក្សាច្បាប់របស់អង្គការសហប្រជាជាតិ បាននិយាយកាលពីដើមខែកក្កដានេះថា អង្គការសហប្រជាជាតិនិងប្រទេសកម្ពុជាបានដោះស្រាយរួចហើយនូវបញ្ហាបច្ចេកទេសចំពោះការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមជាលក្ខណៈអន្តរជាតិពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ប៉ុន្តែលោកព្រមានថា អង្គការពិភពលោកនឹងដកខ្លួនចេញពីដំណើរការនេះប្រសិនបើកម្ពុជាមិនអនុម័តច្បាប់សំខាន់ពុំចាំបាច់ឲ្យបានឆាប់ៗទេនោះ ។

ប៉ុល ពត មេដឹកនាំខ្មែរក្រហម ស្លាប់នៅឆ្នាំ១៩៩៨ ប៉ុន្តែភាគច្រើននៃសមមិត្តរបស់ខ្លួនកំពុងតែរស់នៅដោយសេរីភាពក្រោយពីចុះចូលជាមួយនឹងរដ្ឋាភិបាល ។ ឆ្នាំមុនរដ្ឋាភិបាលកម្ពុជាបានច្រានចោលនូវសំណើរបស់អង្គការសហប្រជាជាតិចង់បង្កើតតុលាការអន្តរជាតិសម្រាប់ជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមដែលមានវ័យចំណាស់ៗដោយនិយាយថា ទង្វើបែបនេះនឹងប៉ះពាល់ដល់អធិបតេយ្យភាពរបស់ជាតិនិងគ្រោះថ្នាក់ដល់សន្តិភាពដែលទើបតែបានបង្កើតថ្មីៗ ។

**កាសែត ឃែមបូឌា ដេលី ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០០០**

បានសរសេរថា សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានជម្រាបដល់ថ្នាក់ដឹកនាំនៅសភាជាតិថា ការងាររបស់រដ្ឋាភិបាលស្តីអំពីការបង្កើតអង្គជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមបានធ្វើរួចរាល់ហើយ ហើយការទទួលខុសត្រូវចំពោះការវិវត្តទៅមុខទៀត គឺអាស្រ័យទៅលើគណៈកម្មការនីតិកម្ម ។

នៅក្នុងសំបុត្រផ្ញើនៅថ្ងៃចន្ទ ហើយដែលសារពត៌មានក្យូដូរបស់ជប៉ុន ទទួលបាន សម្តេចនាយករដ្ឋមន្ត្រីបានមានប្រសាសន៍យោងទៅដល់ប្រធានសភាជាតិ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ថា បាល់កំពុងស្ថិតក្នុងដៃរបស់ទ្រង់ ។ សំបុត្រនោះសរសេរថា «ជាទូទៅរដ្ឋាភិបាលបានសម្រេចកិច្ចការធំៗរួចជាស្រេច ហើយអ្វីដែលនៅសល់គឺមានតែបញ្ហាផ្នែកបច្ចេកទេសតែប៉ុណ្ណោះដែលមិនទាន់បានដោះស្រាយមួយរយភាគរយ ។ អំណះអំណាងនេះផ្ទុយគ្នាដាច់ស្រឡះទៅនឹងព្រះរាជបន្ទូលរបស់ទ្រង់ រណឫទ្ធិ កាលពីសប្តាហ៍មុនដែលថាគណៈកម្មការនីតិកម្មនៅតែមាន«បញ្ហាខ្វះៗ» ដែលត្រូវដោះស្រាយនៅឡើយ ។ អង្គការសហប្រជាជាតិនិងរដ្ឋាភិបាលបានជជែកយ៉ាងល្អិតល្អន់ជាមួយគ្នាអស់រយៈពេលជាងមួយឆ្នាំស្តីអំពីបញ្ហាថាតើត្រូវបង្កើតតុលាការតាមរបៀបណា ។ អ្នកចរចារបស់អង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជា កាលពីខែកន្លងទៅថ្មីៗនេះបានដោះស្រាយបញ្ហាមួយចំនួនដែលធ្វើឲ្យក្រុមចរចាទាំងពីរបែកដាច់ពីគ្នា ជាពិសេសបញ្ហាដែលថាតើអ្នកណានឹងធ្វើជាព្រះរាជអាជ្ញា ។ ប៉ុន្តែទ្រង់ រណឫទ្ធិ នៅបានបង្ហើបព្រះបន្ទូលពីភាពខុសគ្នាច្រើនជាងនេះទៅទៀត ។ **សួ ប៊ុនស៊ុ**



បំពង់នេះជាបំណែកសល់ពីការបាញ់ភ្លើងសញ្ញាមុនពេលចុះប្រតិបត្តិការ ការទម្លាក់គ្រាប់ បេ-៥២ របស់អាមេរិកមកលើពួកវៀតកុងដែលជ្រកកោននៅភូមិចន្ទ្រាកាលពីសង្រ្គាមវៀតណាម-អាមេរិកក្នុងឆ្នាំ១៩៦៤-១៩៧៥ ។

# កេរដំណែល

ដោយៈ ហិនរី ឃីសស៊ីងជ័រ

***ហេតុផលរបស់លោក ហិនរី ឃីសស៊ីងជឺរ «ការទម្លាក់គ្រាប់បែកបេ-៥២ មកលើប្រទេសកម្ពុជា»***

*«អតីតរដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិកអត្ថាធិប្បាយអំពីការបញ្ចប់សង្រ្គាមដែលជាយុទ្ធសាស្រ្តដ៏ចម្រូងចម្រាស ដែលគាត់បានជួយរៀបចំបង្កើត និងរបៀបដែលជម្លោះបានបង្កើតរូបរាងនៃការគិតគូរអំពីគោលនយោបាយការបរទេសសម្រាប់ជនជាតិអាមេរិកអស់រយៈពេលបីជំនាន់មនុស្សកន្លងមក ។»*

មិនយូរប៉ុន្មានមុននេះ អតីតប្រធានាធិបតី ជីរល ហ្វដ និងខ្ញុំបានរំឭកឡើងវិញអំពីអាណត្តិប្រធានាធិបតី និងបទពិសោធន៍របស់យើងនៅក្នុងសេវាកម្មរដ្ឋាភិបាល ។ ក៏ប៉ុន្តែយើងបានរួមចំណែកនូវបទពិសោធន៍មួយដែលនឹងមិនចេះបាត់បង់នូវភាពដែលធ្វើឲ្យយើងគិតថាទើបតែកើតឡើងហាក់ដូចជាក្នុងពេលថ្មីៗនេះ នោះគឺការឈឺចាប់និងទុក្ខវេទនានៅថ្ងៃដែលជនជាតិអាមេរិកាំង និងជនភៀសខ្លួនវៀតណាមខាងត្បូងមួយក្រុមតូចគួរឲ្យអាណិតអាសូរដែលត្រូវបានជម្លៀសខ្លួនចេញពីលើដំបូលស្ថានទូតសហរដ្ឋអាមេរិកនៅទីក្រុងព្រៃនគរ (ឬទីក្រុងហូជីមិញ) ។ នាពេលនោះខ្សែភាពយន្តនិងទូរទស្សន៍បានបញ្ចាំងនូវវិបត្តិធំៗនៅក្នុងពេលដែលមានសកម្មភាពកលយុគដោយមន្ត្រីជំនួយការតាមការិយាល័យបានកាត់ផ្តាច់ទូរស័ព្ទ មកមមាញឹកនឹងការស្រែកប្រាប់សេចក្តីណែនាំទៅឲ្យមន្ត្រីក្រោមបញ្ជាដែលកំពុងប្រញាប់ប្រញាល់រកប្រករត់ភៀសខ្លួន ។ តាមពិតវិបត្តិទាំងនេះបានផុសជ្រលោយយ៉ាងច្បាស់ថាវានឹងកើតឡើងដោយសារភាពងាប់ស្តូកដែលយើងមិនអាចចាត់វិធានការអ្វីទាំងអស់ដោយដឹងថាជម្រើសនានាមានកាន់តែតិចទៅៗ ។ ចំនួនមន្ត្រីមានសិទ្ធិធ្វើសេចក្តីសម្រេច បានរួញមកនូវត្រឹមតែមន្ត្រីមួយចំនួនតូចក្នុងតួនាទីមួយសម្រេចលើដោគវាសនានៃព្រឹត្តិការណ៍នោះ ហើយភាពឯកោកាន់តែរីកធំឡើងពីព្រោះកាលណាវិបត្តិកាន់តែធ្ងន់ឡើងៗអ្នកស្ម័គ្រចិត្តដែលមានសុច្ឆន្ទៈទទួលភារកិច្ចកាន់តែតិចទៅៗ ។

នៅថ្ងៃចុងក្រោយក្នុងខែមេសា ឆ្នាំ១៩៧៥ លោកប្រធានាធិបតី ហ្វដ និងខ្ញុំស្ទើរតែនៅម្នាក់ឯងៈ លោកប្រធានាធិបតី ហ្វដ នៅក្នុងការិយាល័យប្រធានាធិបតីរបស់គាត់ជាភាសាអង់គ្លេសនោះហៅថា Oval Office នៃសេតវិមាន ហើយខ្ញុំនៅក្នុងការិយាល័យទីប្រឹក្សាសន្តិសុខខាងក្រោមសាលខាងមុខការិយាល័យ ។ សភាពស្ងប់ស្ងាត់កាត់ផ្តាច់ដោយសម្លេងទូរស័ព្ទរោទ៍ម្តងម្កាលប៉ុណ្ណោះ គឺនៅពេលដែលមន្ទីរបញ្ជាការនៃក្រសួងការពារប្រទេសរាយការណ៍ពីការចាកចេញរបស់ឧទ្ធម្ភាគចក្រនីមួយៗ (ពីក្រុងព្រៃនគរ) ។ អស់រយៈពេលមួយខែ យើងទាំងពីរនាក់បានធ្វើជាអាជ្ញាកណ្តាលរវាងការពិភាក្សាអន្តរក្រសួងដែលជាសញ្ញានៃទីបញ្ចប់នៃភាពរុំរ៉ៃ ថាតើត្រូវជំរុញការដកជនជាតិអាមេរិកាំងមួយចំនួនតូចចុងក្រោយដើម្បីបញ្ចៀសពួកគេឲ្យចាកផុតពីគ្រោះថ្នាក់ដែលមិនចាំបាច់ ឬត្រូវពង្រីកទំហំនៃការដកថយនេះឲ្យកាន់តែទូលាយដើម្បីអនុញ្ញាតឲ្យជនជាតិវៀតណាមខាងត្បូងក្នុងចំនួនអតិបរមាគេចខ្លួន ហើយជម្រើសមួយទៀតគឺថាតើត្រូវបោះបង់ចោលសំណើទៅកាន់សភាដើម្បីសុំជំនួយ

ដែលនឹងមិនអាចមកដល់វៀតណាម ឬរក្សាសំណើនេះដើម្បីកុំឲ្យអាមេរិកទទួលបរាជ័យដោយចាក់សម្ព័ន្ធមិត្តរបស់ខ្លួនចំកណ្ដាលខ្នងមួយការបិតនៅក្នុងស្ថានភាពដ៏ស្រួចស្រាល់ និងគ្រោះថ្នាក់ជាទីបំផុតបែបនេះ ។ លោកប្រធានាធិបតី ហ្វដ ហើយនិងខ្ញុំ បានប្រយុទ្ធដើម្បីឲ្យមានដំណើរដកថយបន្តិចម្ដងៗ ហើយរក្សាសំណើសុំជំនួយទៅសភាឲ្យនៅដដែល ។ ដោយពេលនោះការពិភាក្សារបស់យើងត្រូវបានគ្របដណ្ដប់ទៅដោយព្រឹត្តិការណ៍ធំៗជាច្រើន ។ លោកប្រធានាធិបតី ហ្វដ ហើយនិងខ្ញុំ បានក្លាយទៅជាអ្នកឈរមើលឆាកមួយដែលយើងទាំងពីរនាក់ពុំអាចមានលទ្ធភាពប្រើឥទ្ធិពលជាអ្នករៀបចំបាន ។ យើងទាំងពីរឈរទ្រឹងនៅចន្លោះភាពឈឺចាប់មួយដែលយើងមិនអាចបញ្ឈប់បាននិងអនាគតមួយដែលយើងទាំងពីរនាក់មិនទាន់ស្ថិតនៅក្នុងតួនាទីមួយដែលនឹងត្រូវគាក់តែងឡើង ។

ចំពោះអ្នកដែលបានរស់នៅឆ្លងកាត់ថ្ងៃចុងក្រោយ រាល់រឿងរ៉ាវណាមួយក៏ដោយ ក៏ត្រូវពុះជ្រៀកជាចម្រៀកតូចៗដែលគ្របដណ្ដប់លើសលប់ទៅដោយទស្សនៈវិស័យចេញពីចំណុចមានសក្ដានុពលនៃ «ភាពជាអ្នកត្រួតត្រានិយម» ដោយសារភាពវឹកវរបានទាមទារឲ្យមានការលះបង់អស់រយៈពេលពីរទសវត្សរ៍រួចមកហើយ ។ ចំពោះអ្នកដែលរួចផុតពីទុក្ខវេទនានេះ អារម្មណ៍បែបនេះហាក់ដូចជាពិបាកយល់បានណាស់ ។ ហើយប្រវត្តិវិទូក៏ពុំអាចជាជំនួយក្នុងបញ្ហានេះដែរ ពីព្រោះថារឿងរ៉ាវដែលប្រវត្តិវិទូសរសេរ ជាទូទៅបង្ហាញតែពីភាពជំទាស់ដ៏ស្រួចស្រាល់និងជូរចត់ទៅនឹងរយៈកាលនោះ ។ ការរិះគន់បែបឆ្វេងនិយមបានជំរុញឲ្យមេដឹកនាំអាមេរិកដ៏ស្រេកឃ្លានដែលកំពុងធ្វើសង្គ្រាមមួយ ឲ្យកាន់តែចង់យកឈ្នះបំពេញតាមចិត្តសាស្ត្ររបស់ខ្លួនដែលត្រូវបានពួកប្រឆាំងមូលបន្ទាច់ ។ ពួកខាងស្ដាំនិយមធ្វើកធ្វើថ្លង់ចំពោះសង្គ្រាមថាជាការដើរខុសតាមបែបសេរីមួយ ឬទម្លាក់កំហុសលើការចាញ់សង្គ្រាមដោយខ្វះថាមភាពមនោគមន៍វិជ្ជា ។ ដោយមានការអល់អែកក្នុងការចាប់យកបទពិសោធន៍ដ៏សែនវេទនាក្នុងពាក់កណ្ដាលសតវត្សរ៍នាអតីតកាល ជនជាតិអាមេរិកនឹងជួបប្រទះនូវការលំបាកច្រើនក្នុងការទាញយកមេរៀននានាពីអ្វីដែលត្រូវបានធ្វើចំពោះប្រទេសអាមេរិក និងអ្វីដែលយើងបានធ្វើមកលើខ្លួនយើងនៅក្នុងអំឡុងពេលដ៏សោកសៅ ។

នោះគឺជាប្រធានបទដែលខ្ញុំលើកយកមកនិយាយនៅក្នុងអត្ថបទនេះ ។ ប្រពៃណី «ជាអ្នកឆ្នើមលើសគេ» របស់ជនជាតិអាមេរិក គឺជាគ្រោះថ្នាក់មួយក្នុងចំណោមគ្រោះថ្នាក់ដល់ការបាត់បង់ជីវិតនៅក្នុងសោកនាដកម្មនៅវៀតណាម ។ ជំនឿស្ទើរតែជាសកលក្នុងគ្រាមួយនោះដែលជាតម្លៃរបស់យើងជាជនជាតិអាមេរិកហើយដែលតម្លៃទាំងនេះមានការពាក់ព័ន្ធជុំវិញពិភពលោកបានបើកផ្លូវឲ្យមានការបែកបាក់កាន់តែខ្លាំងឡើងអំពីសុពលភាពនៃតម្លៃរបស់អាមេរិកនិងថាតើយើងអាចឈានទៅដល់ប្រវែងណាដើម្បីលើកតម្កើងនិងការពារតម្លៃទាំងនេះ ។ ការមិនចុះសម្រុងគ្នាដ៏ខ្លាំងក្លាទាំងនេះជះឥទ្ធិពលដ៏ជ្រាលជ្រៅមកលើទង្វើគោលនយោបាយរបស់សហរដ្ឋអាមេរិកចាប់តាំងពីពេលនោះមក ។

## ចូលឥណ្ឌូចិន និងចាកចេញពីឥណ្ឌូចិន

វាគឺជាជំនាន់ដ៏អស្ចារ្យស្អីគេនោះហើយដែលអាមេរិកបានចូលក្នុងឥណ្ឌូចិននៅក្នុងពេលមហាជោគជ័យរបស់ភាពឆ្នើមនិយមរបស់អាមេរិក ។ អាមេរិកធ្វើដូច្នោះដើម្បីស្វែងរកយុទ្ធសាស្ត្រមួយដែលធ្លាប់បានធ្វើឲ្យពិភពលោកក្រោយសង្គ្រាមលោកលើកទី២មានស្ថិរភាពរួចមកហើយ គឺអាមេរិកបានកសាងអឺរ៉ុបឡើងវិញ និងស្ដារនិងស្ដាបនាប្រទេសអាល្លឺម៉ង់និងជប៉ុនឲ្យចូលមកក្នុងសហគមន៍ជាតិឡើងវិញ ហើយបានស្ទាក់ជាប់នូវការបោះពួយរបស់សូវៀតឆ្ពោះទៅត្រួតការអឺរ៉ុបនិងឧបទ្វីបកូរ៉េ ។ ការបូកបញ្ចូលគ្នានូវបទពិសោធន៍ទាំងឡាយបានមកពីសង្គ្រាមលោកលើកទីពីរនិងទស្សនៈដែលទាញចេញមកពីនយោបាយសេដ្ឋកិច្ចមួយហៅថា «ដំណោះស្រាយថ្មី ដែលជាការស្រូបយកកម្លាំងពលកម្មទៅក្នុងកិច្ចការរដ្ឋាភិបាលដោយប្រើប្រាស់ថវិការដ្ឋាភិបាលដើម្បីកាត់បន្ថយអត្រាអត់ការងារធ្វើនៅអាមេរិកក្នុងឆ្នាំ១៩៣៣» ។ យុទ្ធសាស្ត្រនេះផ្ដោតទៅលើការបញ្ឈប់ការឈ្លានពានរបស់សូវៀតនិងបំបាត់ឱកាសរបស់ពួកកុម្មុយនិស្តកុំឲ្យបង្កភាពវឹកវរដោយលើកកម្ពស់ការរីកចម្រើនផ្នែកសេដ្ឋកិច្ចនិងសង្គមនៅក្នុងតំបន់នានាក្រោមការគាំពាររបស់សហរដ្ឋអាមេរិក ។

ទោះបីជាទង្វើរបស់អាមេរិកក្នុងសង្គ្រាមត្រជាក់គឺជារឿយៗត្រូវបានបង្ហាញថាស្ទើរតែជាការមូលមតិជាឯកច្ឆ័នមួយ

ក៏ដោយ ក៏ជានិច្ចកាលមានការជំទាស់មួយដ៏សំខាន់នៅក្នុងរយៈកាលនោះ ជាពិសេសនៅក្នុងសហគមន៍បញ្ញវន្តនិងបណ្ឌិតសភាជាន់ខ្ពស់ ។ អ្នកទាំងនេះទាញហេតុផលថា ការគាំរាមកំហែងរបស់ពួកកុម្មុយនិស្តត្រូវបានបំផ្លើសហួសហេតុ ឬក៏ថាសហរដ្ឋអាមេរិកដោយគ្រាន់តែចង់រក្សាការអះអាងរបស់ខ្លួនថាជាអ្នកការពារសិទ្ធិសេរីភាព កំពុងចងសម្ព័ន្ធភាពជាមួយរបបដែលស្ថិតក្រោមការសង្ស័យច្រើនពេក ។ ក៏ប៉ុន្តែការរិះគន់នេះគឺកម្រិតត្រឹមតែលើភាពឈ្លាសវៃរបស់គោលនយោបាយជាក់លាក់ទាំងនេះមិនមែនលើសុពលភាពនៃតម្លៃនានាដែលរដ្ឋាភិបាលសហរដ្ឋអាមេរិកបានផ្អែកទង្វើរបស់ខ្លួនជាមូលដ្ឋាន ។

ដោយរដ្ឋបាល កេណ្ណឌី ចូលមកដល់ គោលនយោបាយនេះត្រូវបានផ្តល់នូវរូបរាងយ៉ាងជាក់ច្បាស់បំផុតនៅក្នុងសេចក្តីថ្លែងសុន្ទរកថាឡើងកាន់តំណែងប្រធានាធិបតីថ្មី ជាការសន្យាមួយថាសហរដ្ឋអាមេរិកនឹង «សុខចិត្តលះបង់គ្រប់បែបយ៉ាង សុខចិត្តទទួលនូវបន្ទុកអ្វីទាំងអស់ ទទួលការលំបាកអ្វីៗទាំងអស់ គាំទ្រគ្រប់មិត្ត ប្រឆាំងគ្រប់សត្រូវ ដើម្បីធានាជីវិតនិងជោគជ័យនៃសេរីភាព» ។ នៅក្នុងពេលនោះស្ទើរតែពុំមានការប្រឆាំងណាមួយទៅនឹងសេចក្តីអត្ថាធិប្បាយដ៏ចំហនេះ ឬជំទាស់ទៅនឹងការគិតជាទូទៅថា ឥណ្ឌូចិនគឺជាចំណុចក្តៅដ៏សំខាន់មួយក្នុងការការពារសិទ្ធិសេរីភាព ។

នៅពេលដែល កេណ្ណឌី កំពុងត្រៀមខ្លួនឡើងកាន់តំណែងប្រធានាធិបតី ប្រធានាធិបតីត្រៀមខ្លួនចុះពីតំណែង អេសិន ហូវ័របានផ្តល់អនុសាសន៍ឲ្យរដ្ឋាភិបាលសហរដ្ឋអាមេរិកផ្តល់ការគាំទ្រយោធាដល់ប្រទេសឡាវ ប្រសិនបើការធ្វើអន្តរាគមន៍របស់វៀតណាមខាងជើងនៅតែបន្តនៅក្នុងប្រទេសឡាវ ។ នៅក្នុងរយៈពេល២ខែក្រោយពេល កេណ្ណឌី ឡើងកាន់អំណាច លោកប្រធានាធិបតីបានបញ្ជូនទ័ពម៉ារីនទៅកាន់ប្រទេសថៃឡង់ដ៍ដែលនៅជាប់ជាមួយប្រទេសឡាវ ។ ប្រធានាធិបតី កេណ្ណឌី បានពន្យារពីការធ្វើអន្តរាគមន៍ដោយផ្ទាល់ «ទោះបី សេ អ៊ី អា បានប្រើវិធានការសម្ងាត់របស់ខ្លួនដោយឡែកក៏ដោយ» ។ ក៏ប៉ុន្តែនៅឆ្នាំ១៩៦១ នៅពេលដែលហាណូយបានបើកខ្សែផ្គត់ផ្គង់សម្ភារទៅឲ្យចលនាកុម្មុយនិស្តវៀតណាមខាងត្បូងតាមរយៈទឹកដីឡាវ ហើយពង្រីកសង្គ្រាមឈ្លបប្រឆាំងវៀតណាមខាងត្បូង កេណ្ណឌី បានបញ្ជូនទីប្រឹក្សាយោធារបស់អាមេរិកទៅកាន់វៀតណាមខាងត្បូងដែលចំនួនទីប្រឹក្សានេះកើនឡើងដល់ចំនួន១៦០០០នាក់ នៅត្រឹមដើមឆ្នាំ១៩៦៣ ។ ប្រធានាធិបតីបន្ទាប់ លីនដុន ចនសុន បានបង្កើនការប្តេជ្ញាចិត្តនេះរហូតដល់ចំនួននេះកើនឡើងដល់ជាង៥០០០០០នាក់ ទ័ពប្រយុទ្ធនៅពេលដែល ចនសុន ចេញពីតំណែង ។ ជាថ្មីម្តងទៀត ពុំមានការជំទាស់ធំដុំឡើយទាំងនៅក្នុងនិងនៅក្រៅរដ្ឋាភិបាលរបស់លោកប្រធានាធិបតីចំពោះការដាក់ពង្រាយទ័ពដ៏ច្រើនសន្ធឹកសន្ធាប់នៃរបបនោះ ។ ទោះបីជាសេចក្តីសម្រេចចិត្តនេះក្រោយមកត្រូវបានបន្ទោសលើលោកប្រធានាធិបតី ចនសុន ក៏ដោយ ក៏ប៉ុន្តែតាមពិតគឺទីប្រឹក្សាដ៏ជិតដិតបំផុតរបស់លោកប្រធានាធិបតី កេណ្ណឌី ឈ្មោះ ចច ប៊ុនឌី រូបឺត ម៉ាក់ណាម៉ារា និង ឌីនរ៉ាស់ ដែលបានទទូចឲ្យមានការពង្រីកការដាក់ពង្រាយនេះ ។

នៅចុងបញ្ចប់នៃរដ្ឋាភិបាលរបស់លោកប្រធានាធិបតិ លីនដុន ចនសុន ភាពតានតឹងបានកើតឡើង ។ យុទ្ធសាស្ត្រដែលធ្លាប់ទទួលបានជោគជ័យនៅក្នុងសង្គ្រាមរបស់អាមេរិកមុនតាមរយៈការវាយបំបាក់សត្រូវដោយធ្វើឲ្យខ្សោះកម្លាំងបន្តិចម្តងៗ ពុំអាចទទួលបានជោគជ័យក្នុងការប្រឆាំងនឹងពួកខ្មាំងដែលពុំមានទឹកដីត្រូវការពារប្រាកដណាមួយ ហើយដែលស្ថិតនៅក្នុងគោលជំហរមួយអាចជ្រើសរើសពេលវេលានិងទីកន្លែងដើម្បីវាយប្រហារតាមអំពើចិត្ត ។ ម្យ៉ាងទៀតសោត ប្រទេសដែលមិនកុម្មុយនិស្តនៅឥណ្ឌូចិនពុំគោរពតាមបទដ្ឋានលទ្ធិប្រជាធិបតេយ្យជូនសម្ព័ន្ធមិត្តអឺរ៉ុបរបស់សហរដ្ឋអាមេរិកទេ ដែលជាហេតុធ្វើឲ្យមានចំណោទសួរថាតើអ្វីទៅជាគោលបំណងត្រឹមត្រូវនៃសង្គ្រាមនេះ ។ ចំពោះអ្នកទាំងឡាយណាដែលបានធ្វើការសម្រេចចិត្តបញ្ជូនទ័ពអាមេរិកភាពមន្ទិលសង្ស័យក្នុងខ្លួនដែលចេះតែរីកធំឡើងឡោមព័ទ្ធភាពអស់សង្ឃឹមដោយការលួចធ្វើឃាតលោកប្រធានាធិបតី កេណ្ណឌី ។

នៅក្នុងខណៈដែលមេដឹកនាំអាមេរិកត្រូវបានគ្របដណ្តប់ដោយភាពច្របូកច្របល់ក្នុងអារម្មណ៍ ពួកអ្នករិះគន់បានធ្វើការវាយប្រហារមកលើខ្លឹមសារនៃការពាក់ព័ន្ធរបស់អាមេរិកនៅឯបរទេស ។ ការទាញហេតុផលថាសង្គ្រាមពុំអាចទទួលជ័យជម្នះបាន

ហើយថាការចំណាយទៅប្រតិបត្តិការនៅក្រៅប្រទេសមានភាព លើសលប់ជាងផលចំណេញដែលបានមកពីការពង្រីកការដាក់ពង្រាយក្នុងល្បឿនយ៉ាងលឿនបែបនេះ ។ ដំបូងអ្នកដែលមានការមន្ទិលសង្ស័យថយចំនួនកាន់តែតិចទៅៗ អំពីថាតើធ្វើយ៉ាងដូចម្ដេចទើបអាចរកច្រកចេញមួយដ៏មានកិត្តិយសចេញពីវិបត្តិនេះ ក៏ប៉ុន្តែនៅក្នុងប៉ុន្មានខែក្រោយមក ភាពឆ្មើមនិយមរបស់អាមេរិកនេះតែម្ដងត្រូវបានចោទសួរ ។ ក្រុមប្រឆាំងកាន់តែទាញហេតុផលយ៉ាងទទូចថា មូលហេតុចុងក្រោយនៃវិបត្តិគឺមិនមែនជាកំហុសអចេតនានៅក្នុងការវិនិច្ឆ័យទេ ប៉ុន្តែជាភាពពុករលួយដល់ឆ្អឹងខាងផ្នែកសីលធម៌នៅក្នុងជីវភាពរបស់ជនជាតិអាមេរិក ។ ជ័យជម្នះរបស់ពួកកុម្មុយនិស្តនៅឥណ្ឌូចិនដែលរដ្ឋាភិបាលរបស់លោកប្រធានាធិបតីទាំងបួនបានព្យាយាមរាំងខ្ទប់អស់រយៈពេលជិត២ទសវត្សរ៍មកនោះ បានក្លាយទៅជាភាពធូរស្រាលក្នុងចិត្តសម្រាប់ក្រុមអ្នកជំទាស់ជ្រុលនិយមទៅវិញ ។ ក្រុមអ្នករិះគន់បានផ្លាស់ពីការចោទសួរពីភាពស័ក្ដិសមជាសម្ព័ន្ធមិត្តរបស់អាមេរិកសម្រាប់ប្រទេសមួយចំនួន មកវាយប្រហាររិះគន់អាមេរិកខ្លួនឯងនិងអំពីទង្វើរបស់អាមេរិក មិនមែនត្រឹមតែនៅក្នុងប្រទេសវៀតណាមប៉ុណ្ណោះទេ ប៉ុន្តែនៅទូទាំងពិភពលោកទាំងមូលទៀតផង ។ វៀតណាមបានក្លាយទៅជាសមរភូមិនៃសង្គ្រាមលើកដំបូងដែលជនជាតិអាមេរិកដ៏ឆ្មើមជាច្រើនចេញមុខជាសាធារណៈធ្វើដំណើរទស្សនកិច្ច ដែលត្រូវបានផ្សព្វផ្សាយព្រោងព្រាតទៅកាន់រដ្ឋធានីនៃប្រទេសរបស់សត្រូវដើម្បីប្រឆាំងនឹងប្រទេសខ្លួនឯង ។

នៅពេលដែល រីដឆាត និចសុន បានក្លាយជាប្រធានាធិបតីសហរដ្ឋអាមេរិក ខ្សែបន្ទាត់សមរភូមិប្រយុទ្ធត្រូវបានគូសកំណត់ជាព្រំដែន ការស្ដាបនាពីមុនដែលបានរុញច្រានយើងឲ្យជាប់ផុង ត្រូវបានវាយបំបាក់ស្មារតីដោយការដាក់កម្រិតនេះ ហើយរដ្ឋាភិបាល និចសុន បានបោះបង់ចោលភារកិច្ចពង្រីកការដាក់ពង្រាយទ័ពអាមេរិក ។ រដ្ឋាភិបាលនេះបានបើកឱកាសឲ្យក្រុមប្រឆាំងថែមទាំងមានមន្ត្រីនៃរដ្ឋាភិបាលនេះចូលរួមផង វាយប្រហាររិះគន់មកលើកង្វះចក្ខុវិស័យវែងឆ្ងាយនិងរបៀបគិតគូរពុំត្រឹមត្រូវរបស់រដ្ឋាភិបាលលោកប្រធានាធិបតីនិចសុន ។ ក្រុមអ្នកតវ៉ាជ្រុលនិយមដោយមានភាពប្រាកដចំពោះភាពឈ្នះផ្នែកសីលធម៌របស់ខ្លួន ពុំចាំបាច់ប្រើការគាបសង្កត់ទៅលើមធ្យោបាយនានាដែលពួកគេបានប្រើដើម្បីសម្រេចគោលដៅចុងក្រោយរបស់ពួកគេ ។ តាមរយៈបាតុកម្មជាច្រើននៅតាមដងផ្លូវនិងការធ្វើវិទ្ធង្សនាដោយចេតនាប្រឆាំងនឹងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ចាប់តាំងពីសកលវិទ្យាល័យរហូតដល់រដ្ឋាភិបាលអាមេរិក ពួកប្រឆាំងបានរិះរកមធ្យោបាយបំផ្លិចបំផ្លាញរាល់គោលនយោបាយណាមួយដែលបង្កើតឡើងដើម្បីអូសទាញពលរដ្ឋអាមេរិកឲ្យមានជំនឿចំពោះតម្លៃនានាដែលអាមេរិកទទួលបានដែលរាល់គោលនយោបាយរបស់អាមេរិកក្រោយសង្គ្រាមលោកលើកទី២ពឹងផ្អែកជាមូលដ្ឋាន ។ ***(នៅមានត)*** **ប្រែសម្រួលដោយ ផាត កុសល**



**រូបអំបែងនេះសល់ពីការទម្លាក់គ្រាប់បែកជំនាន់សង្គ្រាមអាមេរិកនិងវៀតណាមឆ្នាំ១៩៦៤-១៩៧៥**

# តើការលើកលែងទោស គឺជាតម្លៃនៃសន្តិភាពនៅកម្ពុជាឬយ៉ាងណា?



មានភស្តុតាងដ៏ច្រើនសន្ធឹកសន្ធាប់បង្ហាញថា របបខ្មែរក្រហមបានរំលោភបំពានទៅលើគោលការណ៍ច្បាប់ដូចដែលមានចែងនៅក្នុងការកាត់ទោសនៅតុលាការនូរិមប៊ឺក ច្បាប់សង្គ្រាម ហើយថែមទាំងអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍របស់អង្គការសហប្រជាជាតិនៅក្នុងរបបជិត៤ឆ្នាំ ដែលបានធ្វើឲ្យមនុស្សជាង១លាននាក់ស្លាប់បាត់បង់ជីវិត ។ ក្នុងខណៈដែលការបោះឆ្នោតជាប្រវត្តិសាស្ត្រនៅរដ្ឋសភាជាតិកម្ពុជាហៀបនឹងកើតឡើងដើម្បីអនុម័តការបង្កើតអង្គជំនុំជម្រះខក្រិដ្ឋកម្មសង្គ្រាមខ្មែរក្រហមចម្រុះរបស់អង្គការសហប្រជាជាតិ ប្រជាជនកម្ពុជាត្រូវសួរខ្លួនឯងនូវសំណួរដ៏សាមញ្ញមួយថា តើស្ថាបនិកនៃការដកពិសោធន៍ផ្នែកនយោបាយ និងសង្គមដែលមានលក្ខណៈបំផ្លិចបំផ្លាញ ជាទីបំផុតមួយនៅក្នុងប្រវត្តិសាស្ត្រមនុស្សលោកស័ក្តិសមនឹងទទួលការលើកលែងទោសឲ្យរួចពីការជំនុំជម្រះក្តីខក្រិដ្ឋកម្មសង្គ្រាមដែរឬទេ ។ សំណុំរឿងក្តីអតីតមេដឹកនាំខ្មែរក្រហម អៀង សារី លើកឡើងនូវបញ្ហាចម្រូងចម្រាសជាងគេបំផុតមួយ ។ បញ្ហានោះស្ថិតនៅត្រង់ថាតើការលើកលែងទោសបានក្លាយទៅជាតម្លៃនៃសន្តិភាពនៅក្នុងសតវត្សរ៍ទី២១យើងនេះឬយ៉ាងណា?

អៀង សារី បានជួបនឹង ប៉ុល ពត នៅទីក្រុងប៉ារីសជាលើកដំបូងនៅក្នុងឆ្នាំ១៩៤៩ ។ បុរសទាំងពីរនេះបានសិក្សាជាមួយគ្នា ហើយក៏រៀបការជាមួយបងប្អូន ខៀវ ប៉ុណ្ណារី ទាំងពីរ ។ អំពើឃោរឃៅព្រៃផ្សៃក្រោមស្នាដៃរបស់ អៀង សារី បានចាប់ផ្តើមក្លាយទៅជាខ្សែភាពយន្តឯកសារមួយដែលផលិតឡើងដោយមានការជួយជ្រោមជ្រែងពីទីប្រឹក្សាចិន ។ ខ្សែភាពយន្តដែលថតយកទិដ្ឋភាពទីជនបទនិងបឹងទន្លេសាបនៃប្រទេសកម្ពុជា ឧទាហរណ៍ដូចជា «មាតុភូមិជាទីស្នេហានៃយើងដែលបានរំដោះហើយ ទីណាៗក៏មានទស្សនីយ៍ភាពល្អឆើតឆាយគួរឲ្យអ្នកដងទាំងឡាយចាប់ចិត្តស្រឡាញ់ ។ បឹងទន្លេសាបជាសំបុកត្រីទឹកសាបយ៉ាងធំរបស់ប្រទេសយើង ។» នៅក្នុងខែសីហា ឆ្នាំ១៩៧៥ អៀង សារី បានធ្វើដំណើរទៅកាន់ក្រុងប៉ារីស ។ នៅទីនោះ អៀង សារី បានខទ្មេសនាមជូនបញ្ញវន្តកម្ពុជាមួយក្រុម ហើយជំរុញឲ្យបញ្ញវន្តទាំងនោះត្រឡប់មកជួយបដិវត្តន៍

នៅកម្ពុជាវិញ ។

បញ្ញវន្តកម្ពុជាមួយពាន់នាក់ដែលរស់នៅប្រទេសបារាំង អ៊ឺរ៉ុបខាងកើត និងសហរដ្ឋអាមេរិក បានវិលត្រឡប់មកកម្ពុជា ហើយនៅពេលដែលបញ្ញវន្តកម្ពុជាទាំងនោះបានមកដល់ក្រុងភ្នំពេញ អ្នកទាំងនោះត្រូវបានបញ្ជូនទៅសាលាបច្ចេកទេសមិត្តភាពខ្មែរ-សូវៀតចាស់ ។ បញ្ញវន្តទាំងឡាយណាដែលចម្លើយសារភាពរបស់ខ្លួនត្រូវបានអង្គការសង្ស័យ ត្រូវបញ្ជូនមកកាន់មន្ទីរស-២១ ហើយត្រូវបានសម្លាប់ចោល ។ អ្នកសួរចម្លើយនៅមន្ទីរស-២១ម្នាក់ បានកត់ត្រានូវសាច់រឿងអំពីការដែលគាត់«សួរ» បញ្ញវន្តដែលបានធ្វើមាតុភូមិនិវត្តន៍ម្នាក់ថា «ខ្ញុំបានសួរមីនេះដែលបានត្រឡប់មកពីបារាំង សកម្មភាពរបស់ខ្ញុំគឺថា ខ្ញុំដុតគូទរបស់វារហូតដល់គូទវាឆេះរោលរាល ហើយបន្ទាប់មកវ៉ៃរហូតទៅដល់មីនោះឡេឡឺៗ ។ ឡេឡឺហើយនៅតែខ្ញុំមិនអាចយកចម្លើយពីវាបានទៀត ខ្ទាំងពេលនោះក៏ឈប់ ចប់ចម្លើយទាំងអស់» ។ ក្នុងចំណោមបញ្ញវន្តមួយពាន់នាក់ដែលត្រឡប់មករបបកម្ពុជាប្រជាធិបតេយ្យមានតែ ១៥០នាក់ប៉ុណ្ណោះដែលនៅរស់រានមានជីវិតមកដល់ឆ្នាំ១៩៧៩ ។ បន្ទាប់ពីវៀតណាមចូលក្រុងភ្នំពេញឆ្នាំ១៩៧៩ ពួកវៀតណាមបានរកឃើញចម្លើយសារភាពមួយចំនួនរបស់បញ្ញវន្តទាំងនោះពីសំណុំឯកសារក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ ។ ដោយយោងទៅតាមប្រវត្តិវិទូ ម៉ារី ម៉ាទីនៈ «អៀង សារី បានសរសេរចំណារលើចម្លើយសារភាពទាំងនោះសង្កត់បញ្ជាក់អំពីចំណុចដែលអ្នកសារភាពពុំទាន់បានឆ្លើយ និងលទ្ធភាពនៃគ្រោះថ្នាក់ដែលអ្នកផ្តល់ចម្លើយសារភាពទាំងនេះបង្កើតឡើងចំពោះរបបនេះ...អ្នកសរសេរប្រវត្តិរូបផ្ទាល់ខ្លួនដែលត្រូវបានចាត់ទុកថាត្រូវបានមានការសង្ស័យ ឃើញមាននៅក្នុងបញ្ជីឈ្មោះនៃជនរងគ្រោះនៃមណ្ឌលប្រហារជីវិតទួលស្លែង» ។

អៀង សារី ត្រូវបានកាត់ទោសប្រហារជីវិតកំបាំងមុខដោយតុលាការមួយបង្កើតឡើងដោយវៀតណាមក្នុងឆ្នាំ១៩៧៩ ។ នៅពេលដែលសួរទាក់ទងនឹងការកាត់ទោសនៅពេលនោះ អៀង សារី សើចៈ «ខ្ញុំបានអានសាលក្រមនេះនៅឯអង្គការសហប្រជាជាតិដូចជាអ្នកការទូតជាច្រើនដទៃទៀតដែរ ។ អ្នកការទូតទាំងនោះនិយាយថា នេះជារឿងកុកកំប្លែងមួយមិនស័ក្តិសមឲ្យយើងតាមដានទាល់តែសោះ» ។ អៀង សារី បានចន្លុលបង្ហាញអំពីភាពប៉ិនប្រសប់ផ្នែកនយោបាយរបស់ខ្លួននៅពេលដែលត្រូវបានសួរអំពីសេចក្តីសង្ឃឹមនាពេលអនាគតរបស់ចលនាខ្មែរក្រហមនៅក្នុងឆ្នាំចាប់តាំងពីរបបខ្មែរក្រហមបានដួលរលំ ។ អៀង សារី បានផ្លាស់ប្តូរការប្តេជ្ញាចិត្តរយៈពេល៣០ឆ្នាំរបស់ខ្លួនចំពោះលទ្ធិម៉ាក្សនិយម និងម៉ៅនិយមឆ្ពោះទៅរកមនោគមន៍វិជ្ជារីហ្គេនៈ «ការដែលយើងខ្ញុំសង្ឃឹមលើរដ្ឋាភិបាល រីហ្គេននេះ គឺតាមប្រកាសឃើញថាមានជំហរប្រឆាំងមិន...គឺវាមានជំហរដូចថាវាដាច់ខាតជាមួយសូវៀតដែរ គឺចរចាក្នុងកម្លាំង ។ អានេះក៏ជា...តាមយើងខ្ញុំ...បើថាធ្វើអំពើយ៉ាងដូច្នេះ គឺវាជាជំនួយមួយដល់យើងខ្ញុំដែរ ដូចដែលខ្ញុំជម្រាបអម្បាញ់មិញអ៊ីចឹងថា លោកចែកជាពីរអ៊ីចឹង» ។ អៀង សារី បានធ្វើនយោបាយសង្គ្រាមត្រជាក់និងមនោគមន៍វិជ្ជារីហ្គេន ។ ដើម្បីបម្រើផលប្រយោជន៍ដល់ខ្មែរក្រហម អៀង សារី និយាយក្នុងបទសម្ភាសន៍ក្នុងខ្សែភាពយន្តនោះថាៈ «គឺមួយផ្នែក ពួកឈ្លានពានវាតទីហ្នឹងតែម្តងដែលមានសូវៀតជាមេ ហើយមួយផ្នែកទៀតជាការ...ចលនាតស៊ូដើម្បីសេរីភាពដើម្បីឯករាជ្យទាំងអស់ហ្នឹង ។ ដូច្នេះគឺចិន ហី អាមេរិកគេត្រូវហ្នឹង យើងខ្ញុំនៅក្នុងហ្នឹងដែរ» ។ នៅពេលដែលអ្នកផលិតខ្សែភាពយន្តជាជនជាតិអាល្លឺម៉ង់ខាងកើតបានសួរគាត់នៅក្នុងឆ្នាំ១៩៨០ថា តើគាត់មានអារម្មណ៍ទទួលខុសត្រូវចំពោះការសម្លាប់មនុស្សទាំងហ្វូងៗយ៉ាងច្រើនសន្ធឹកសន្ធាប់នៅក្រោមរបបខ្មែរក្រហមឬទេ អៀង សារី ឆ្លើយយ៉ាងព្រងើយថា «អាចថាយើងខ្ញុំល មេដឹកនាំមានការទទួលខុសត្រូវ ។ ប៉ុន្តែពួកឃាតករគឺភ្នាក់ងារវៀតណាម អាហ្នឹងគឺច្បាស់ដូចជាថ្ងៃអ៊ីចឹង» ។ ប្រពន្ធរបស់អៀង សារី (ប្អូនថ្លៃស្រីរបស់ ប៉ុល ពត ឈ្មោះ អៀង ធីរិទ្ធ) ពុំសូវមានល្បិចច្រើនដូចប្តីរបស់ខ្លួនទេ ។ អៀង ធីរិទ្ធ និយាយក្នុងបទសម្ភាសន៍នាដើមទសវត្សរ៍ឆ្នាំ៨០ថា «ពួកឈ្លានពានវៀតណាមមកទល់ពេលនេះ បានសម្លាប់ប្រជាជនរបស់យើងជាងកន្លះលាន ភាគច្រើនជាស្ត្រី កុមារ មនុស្សចាស់ជរា ដែលមានភាពទន់ខ្សោយក្នុងការគេចវេសពីការសម្លាប់រង្គាលដ៏សាហាវព្រៃផ្សៃរបស់ពួកគេ» ។ **(នៅមានត)**

**ភីតធ័រ ម៉ាហ្គៀរ**



# ស្មាដែគាប៉ុក

## វាលពិឃាតជនរន្ធបាធីៈ គុកសង់

ខ្ញុមបុស្សីប្រក់ស្បូវជាច្រើនតម្រៀបខ្លួននៅលើទឹកតាមបណ្តោយឆ្នេរដ៏ស្ងប់ស្ងាត់ ។ ក្មេងៗរត់លេងប្រដេញគ្នាស្រែកខ្ញៀវខ្ញារយ៉ាងសប្បាយរីករាយ ។ ឪពុកម្តាយរបស់ក្មេងៗទាំងនោះសម្រាកកាយនៅលើទ្រៃគ្រឹកក្រោយពីបានដើរមើលកំសាន្តលម្ហែកាយនៅតាមប្រាសាទបាក់បែក កសាងឡើងតាំងពីសម័យអង្គរដែលស្ថិតនៅក្បែរនោះរួចមក ។ អ្នកលក់ដូរនាំយកត្រីដុតឆ្ងាញ់ៗ ព្រមទាំងភេសជ្ជៈផ្សេងៗមកលក់ ។ អ្នកលក់ដទៃទៀតបណ្តែតខ្លួនតាមទូក លក់ខ្យង លៀស គ្រំ និងបង្អែមផ្សេងៗ ។ អ្នកស៊ីជីកដែលមកពីភ្នំពេញដែលនឹងវិលត្រឡប់ទៅលំនៅដ្ឋានរបស់ខ្លួនវិញនៅថ្ងៃរសៀលជ្រេបន្តិច កំពុងតែដដែកលេងសើចយ៉ាងសប្បាយក្អាកក្អាយជាមួយមិត្តភក្តិនិងគ្រួសាររបស់ខ្លួន ។ នេះជាថ្ងៃថ្មីមួយទៀតនៅរមណីយដ្ឋានទន្លេបាទី ក្នុងខេត្តតាកែវ ដែលមនុស្សម្នាចូលចិត្តមកលម្ហែកាយ ។ ជារៀយៗភ្នែករបស់អ្នកលម្ហែកាយទាំងនោះបោលទៅរកឆ្នេរទន្លេឆ្ងាយដាច់សង្វែង ដែលចាំងពន្លឺព្រឹមៗពីចម្ងាយជិតមួយគីឡូម៉ែត្រនោឯត្រើយម្ខាង ។ ប៉ុន្តែមានមនុស្សមួយចំនួនតូចតែប៉ុណ្ណោះដែលបានដឹងពីទុក្ខភ័យដែលកើតឡើងនៅទន្លេបាទីក្នុងជំនាន់ប៉ុលពត ។

សំរិទ្ធិ ភុំ បានដឹងអ្វីដែលកើតឡើងនៅគុកសង់ ភូមិ



ត្រពាំងស្វា ឃុំទ្រា ស្រុកបាទី ខេត្តតាកែវ ។ រឿងរ៉ាវនេះវាបានកើតឡើងចំពោះគាត់ ហើយឆាបយកជីវិតប្តីរបស់គាត់ទៀតផង ។ មិនតែប៉ុណ្ណោះរឿងរ៉ាវនេះបានកើតឡើងចំពោះប្រជាជនរាប់សែននាក់ទៀត ។ នៅទីតាំងនេះដែលស្ថិតនៅតាមបណ្តោយព្រំប្រទល់ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល និងស្រុកបាទី ខេត្តតាកែវ និងជាទីតាំងសន្តិសុខរបស់អង្គការសន្តិបាលខ្មែរក្រហម បានផ្តាច់ជីវិតប្រជាជនស្លូតត្រង់ខ្មែររាប់ពាន់នាក់ ។ សព្វថ្ងៃនេះទីតាំងនេះជាទីតាំងសំណង់បាក់បែកដូចជាសំណង់នាសម័យអង្គរនៅឯរមណីយដ្ឋានដែលនៅត្រើយម្ខាងបឹង ។

នៅឆ្នាំ១៩៦៣ នៅក្នុងសម័យសង្គមរាស្ត្រនិយមរបស់សម្តេច សីហនុ «ទីភ្នាក់ងាររបស់រដ្ឋាភិបាលសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍» បានសង់នូវសាលាបណ្តុះបណ្តាលគ្រូបង្រៀនមួយខ្នងនៅជិតភូមិត្រពាំងស្វា ឃុំទ្រា នៅតាមជាយទន្លេបាទី ។ សាលានោះគឺជាគ្រឹះស្ថានសមរម្យនិងមានប្រសិទ្ធភាពមួយ ធ្វើឡើងដើម្បីហ្វឹកហាត់ជនជាតិកម្ពុជាឲ្យបង្ហាត់បង្រៀនមេដឹកនាំជំនាន់ក្រោយ នៅថ្ងៃអនាគត ។ នៅឆ្នាំ១៩៧៧ ក្រោមការចាត់តាំងរបស់លេខានិរតីខ្មែរក្រហមឈ្មោះ ឈិត ជឿន ត្រូវបានពិភពលោកស្គាល់ថា តាម៉ុក ខ្មែរក្រហមបានប្រែក្លាយមូលដ្ឋានសិក្សានេះទៅជាកន្លែងកាប់សម្លាប់ដ៏ធំ ។ សាលារៀននេះដែលត្រូវបានកសាងឡើងក្នុងគោលបំណងជួយមនុស្សជំនាន់ក្រោយឲ្យក្លាយជាមេដឹកនាំកម្ពុជាថ្មី ត្រូវបានខ្មែរក្រហមប្រើជំនួសមកជាកន្លែងលុបបំបាត់មនុស្សជំនាន់ក្រោយ ដែលនឹងក្លាយជាមេដឹកនាំទៅវិញ ។ អ្នកស្រុកអ្នកភូមិហៅកន្លែងនេះថា គុកសង់ ។

សារិទ្ធិ កុំ និងកូនរបស់គាត់ត្រូវបានចាប់ដាក់គុកសង់អស់រយៈពេល៦ខែ ប៉ុន្តែបានរស់រានមានជីវិតនៅពេលដែលកងទ័ពវៀតណាមមកដល់ក្នុងខែមករា ឆ្នាំ១៩៧៩ ។ «កំហុស» របស់គាត់គឺគ្មានអ្វីធំដុំទេគឺគាត់គ្រាន់តែបានរៀបការជាមួយនឹងបុរសម្នាក់ដែលត្រូវបានពួកខ្មែរក្រហមចោទថាជា «ខ្មាំង» បដិវត្តន៍ ។ ចំណែកឯកំហុសរបស់ប្តីរបស់ សារិទ្ធិ កុំ ក៏មិនបានប្រព្រឹត្តអ្វីខុសឆ្គងជាធំដុំអ្វីដែរគឺគាត់គ្រាន់តែចែកអុសគ្នាដុតជាមួយអ្នកជិតខាងដែលខ្វះប្រេងចំអិនអង្ករបបបន្តិចបន្តួចប៉ុណ្ណោះ ។ ចំពោះកំហុសនេះប្រធានភូមិឈ្មោះ ពេជ្រ ឆុច បានផ្តន្ទាទោសដោយធ្វើទារុណកម្ម និងឲ្យជាប់ទោសអស់មួយជីវិតនៅឯគុកសង់ ។ វាគឺជាដំណើររឿងពិសេសមួយរបស់របបខ្មែរក្រហមដែលកាលនោះភាពមិនទៀតទាត់នៃជីវិតនិងសេចក្តីស្លាប់បានអន្ទោលតាមប្រាណរបស់ បុរស ស្ត្រី និងកុមារគ្រប់ៗរូប ។ សព្វថ្ងៃនេះមេភូមិ ឆុច នៅរស់នៅឡើយ ហើយមានផ្ទះនៅជិតភូមិបឹងខ្យាង ។ ពេលដែល កុំ ឃើញមេភូមិឈ្មោះ ឆុច និងអតីតភូឈ្លួយជិះទោចក្រយានយន្តកាត់ផ្ទះគាត់ កុំ និយាយថាៈ «វាធ្វើឲ្យខ្ញុំនឹកឃើញដល់រឿងរ៉ាវចាស់កន្លងផុតទៅ» ។

រឿងរ៉ាវគុកសង់របស់ តាម៉ុក គ្រប់គ្រាន់ក្នុងការធ្វើឲ្យ

ម្នាក់ៗមានការផ្អែតចិត្ត ។ អ្វីដែលធ្វើឲ្យកាន់ឈឺចាប់ជាងនេះទៀតនោះគឺការដែលថាគុកនេះជាប្រព័ន្ធពិសេសមួយក្នុងចំណោមកន្លែងសម្លាប់មនុស្ស២៥ ទៀតដំណើរការដោយខ្មែរក្រហមទូទាំងប្រទេស ។ ដោយក្តាប់ច្បាស់នូវអ្វីដែលបានកើតឡើងនៅក្នុងគុកសង់ យើងអាចយល់បាននូវឧក្រិដ្ឋកម្មខ្មែរក្រហម និងមូលហេតុដែលប្រជាជនចង់នាំមេដឹកនាំដូចជា តាម៉ុក នេះទៅកាន់តុលាការដើម្បីវិនិច្ឆ័យទោស ។ រឿងរ៉ាវគុកសង់នេះគឺជាទុក្ខភ័យមួយផ្នែកដែលរបបខ្មែរក្រហមធ្វើចំពោះប្រជាជនកម្ពុជា ។

តាមរយៈអ្នកស្រុកអ្នកភូមិនៅទីនោះបានឲ្យដឹងថាខ្មែរក្រហមចាប់ផ្តើមសម្លាប់មនុស្សនៅក្នុងឃុំទ្រានៅចុងឆ្នាំ១៩៧៥ ។ ជនរងគ្រោះភាគច្រើនសុទ្ធតែជាប្រជាជនថ្មីដូចជាអតីតយុទ្ធជន រដ្ឋការ និងគ្រូបង្រៀន ។ ជនរងគ្រោះត្រូវនាំមកកាន់កន្លែងសន្តិសុខដែលស្ថិតនៅជុំវិញតំបន់ ហើយក៏បាត់រហូតទៅ ។ នៅដើមឆ្នាំ១៩៧៧ ខ្មែរក្រហមចាប់ផ្តើមបញ្ជូនមនុស្សកាន់តែច្រើនឡើងៗទៅកាន់កន្លែងមួយហៅថា សាលាដំណាក់ដែលក្រោយមកមិនយូរប៉ុន្មានត្រូវបានគេដូរឈ្មោះថាគុកសង់ ។

នៅខែមីនា ឆ្នាំ១៩៧៧ លេខាតំបន់២៥ របស់ខ្មែរក្រហមឈ្មោះ ស៊ុំ ជា ត្រូវបានចាប់ខ្លួន ហើយលេខាភូមិភាគនិរតីឈ្មោះ ម៉ុក ក៏ជំនួសមុខតំណែងនេះទៅឲ្យឈ្មោះ ប្រាក់ ដែលជាសមាជិកគណៈកម្មាធិការតំបន់កាន់កាប់វិញ ។ ប្រហែលជានៅពេលដដែលនេះដែរ គណៈសន្តិសុខនៅតំបន់នេះឈ្មោះ កាសេស បានដឹងថាខ្លួននឹងពិតជាត្រូវពួកខ្មែរក្រហមធ្វើការបោសសម្អាតមិនខាន ដូច្នេះគាត់និងប្រពន្ធក៏សម្រេចចិត្តធ្វើអត្តឃាតទៅ ។ ម៉ុក បានជំនួសតំណែង កាសេស ដោយមនុស្សម្នាក់ទៀតឈ្មោះ ម៉ុង ដែលពេលនោះបានបង្កើតមូលដ្ឋានរបស់ខ្លួននៅគុកសង់ ។

ប្រជាជនមូលដ្ឋានម្នាក់ដែលកាលនោះរស់នៅក្នុងឃុំទ្រា បានឲ្យដឹងថា ខ្មែរក្រហមបានជួសជុលនិងពង្រីកគុកសង់នេះ ។ តាំងពីពេលនោះមកការសម្លាប់នៅក្នុងតំបន់ចេះតែកើនឡើងជាលំដាប់ហើយប្រជាជនមូលដ្ឋាន និងប្រជាជនថ្មីក៏ចាប់ផ្តើមបញ្ចូលទៅក្នុងបញ្ជីជនរងគ្រោះបណ្តើរៗ ។ ឥឡូវនេះគុកសង់ចាប់ផ្តើមដំណើរការពេញទំហឹងហើយ ។ អ្វីដែលធ្លាប់តែជាមជ្ឈមណ្ឌលសម្រាប់សិក្សាបានក្លាយជាមណ្ឌលពិឃាតដ៏ពេញទំហឹងមួយ ។

ជនរងគ្រោះម្នាក់ដែលត្រូវបានចាប់ដាក់គុកនៅទីនោះបានប៉ាន់ស្មានថា មានបុគ្គលិកចំនួន២២នាក់ត្រួតពិនិត្យការស្លាប់រស់នៅក្នុងគុកសង់ ។ យើងជឿជាក់ថាយើងស្គាល់មនុស្សមួយចំនួនធំដែលជាអតីតបុគ្គលិក និងប្រធានៗដែលធ្វើការនៅក្នុងគុកសង់ ហើយសព្វថ្ងៃនេះរស់នៅម្តុំភូមិត្រពាំងស្វា ។

ជនដៃដល់មួយចំនួនក្នុងចំណោមអ្នកទាំងអស់នេះត្រូវបានរកឃើញហើយសម្ភាសដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ មានម្នាក់ឈ្មោះ សាក់ តាំ ។ សាក់ តាំ ប្រកែកថាខ្លួនមិនបានសម្លាប់អ្នកណាម្នាក់ទេនៅក្នុងគុកសង់នេះ ទោះបីជាមានអ្នកស្រុកអ្នកភូមិនិយាយថា គាត់ជាឆ្មាំសន្តិសុខកាចសាហាវក៏ដោយ ។ តាំ តូញត្អូរថាការចោទប្រកាន់ទាំងនេះមិនត្រឹមត្រូវទេ ហើយថាគាត់គឺជាអ្នកដាំស្លនៅគុកសង់តែប៉ុណ្ណោះ ។ តាំ ថាគាត់បានរៀបចំបាយទឹកសម្រាប់មនុស្សនៅក្នុងគុកដែលមានចំនួនទៅដល់៥០០នាក់ ។ ធ្វើបាយទឹកគឺគាត់គ្រាន់តែដាក់អង្ករមួយក្តាប់ចូលទៅក្នុងឆ្នាំងដាំធ្វើជាបបររាវ ។ មួយវែកៗមានសុទ្ធតែជាទឹករាវកក្កុកមានតែបបរពីរ-បីគ្រាប់តែប៉ុណ្ណោះ ហើយតម្រូវឲ្យហូបគ្នាពីរនាក់ ។ របបប៉ុណ្ណេះវាមិនគ្រាប់គ្រាន់ទេសម្រាប់រស់ ។ តាំ និយាយថា ក្នុងមួយថ្ងៃៗមានមនុស្ស១៥នាក់ស្លាប់ដោយការបង្អត់អាហារ ។ ប៉ុន្តែចុងភៅនៅក្នុងគុកសង់រូបនេះមិនមានអារម្មណ៍ថា ខ្លួនគាត់ទទួលខុសត្រូវចំពោះការស្លាប់ដោយកង្វះអាហាររបស់មនុស្សរាប់រយនាក់ឡើយ ។

អ្នកសម្លាប់មនុស្សនៅគុកសង់ច្បាស់ជាត្រូវទទួលខុសត្រូវចំពោះការស្លាប់ដោយកង្វះអាហារទាំងនេះ ។ អ្នកដែលរួចរស់ពីគុកនោះនៅចាំបានថា អ្នកសម្លាប់មនុស្សហាក់ដូចជាមានមោទនភាពពេញចិត្តចំពោះការងាររបស់ខ្លួនចំពោះបដិវត្តន៍ ហើយពួកអ្នកទាំងនោះមានការងារច្រើនណាស់ដែលត្រូវធ្វើ ។ ជនដៃដល់សម្លាប់មនុស្សម្នាក់នៅគុកសង់ឈ្មោះ ដាន បានអួតថា «ទោះបីជាមានមនុស្សចំនួន៥០០នាក់ស្លាប់ ក៏មកដល់សព្វថ្ងៃដៃរបស់ខ្ញុំនៅមិនទាន់រោយស្រពន់ឡើយទេ» ។ ទំហំនៃវាលពិឃាតនៅជិតគុកសង់បង្ហាញថាយ៉ាងហោចណាស់ក៏មានប្រជាជនច្រើននាក់ត្រូវបានសម្លាប់នៅទីនោះ ។ **(នៅមានត)** **គ្រេក អេចរេសាន់**

# ការទាមទារប្រវត្តិសាស្ត្រកម្ពុជាមកវិញ
# គណៈកម្មការស្វែងរកការពិត



## (តពីលេខមុន) ប្រធានបទទី១: សន្តិភាព

សន្តិភាពមានតម្លៃសំខាន់បំផុតសម្រាប់ប្រជាជនកម្ពុជា ពិសេសសម្រាប់ប្រជាពលរដ្ឋសាមញ្ញដែលបំពេញការងារជាច្រើនម៉ោងដើម្បីកម្រៃដ៏ស្តួចស្តើងសម្រាប់ចិញ្ចឹមជីវិត ។ ប្រជាជនកម្ពុជាជាច្រើនអស់កម្លាំងកាយចិត្តចំពោះវិវាទនិងការកាប់សម្លាប់បង្ហូរឈាម ចំពោះការបាត់បង់អ្នកដែលខ្លួនស្រឡាញ់ និងចំពោះការរស់នៅក្នុងរបបមួយដែលពោរពេញទៅដោយភាពភ័យខ្លាច និងមានច្បាប់ពុំគ្រប់គ្រាន់ ។ អ្នកដែលបានផ្តល់បទសម្ភាសន៍បានបង្ហាញពីបំណងចង់រស់នៅក្នុងលទ្ធិប្រជាធិបតេយ្យដែលមានស្ថិរភាពដើម្បីឲ្យប្រទេសកម្ពុជាអាចអភិវឌ្ឍដូចបណ្តាប្រទេសផ្សេងៗក្នុងតំបន់អាស៊ីភាគអគ្នេយ៍ ។ ថ្វីបើតុលាការមានការចាំបាច់សម្រាប់ស្ថិរភាពយូរអង្វែងក៏ដោយ ក៏អ្នកដែលបានផ្តល់បទសម្ភាសន៍ខ្លះជឿថា ស្ថិរភាពសម្រាប់រយៈពេលខ្លីនិងរដ្ឋមួយដែលមានសន្តិភាព មានតម្លៃជាងការព្រួយបារម្ភអំពីអនាគតដ៏វែងឆ្ងាយពេក ។

អ្នកផ្តល់បទសម្ភាសន៍ទាំងនោះខ្លាចថាតុលាការដែលពោរពេញដោយការជជែកតវ៉ាចោទប្រកាន់គ្នាហើយពុំផ្តល់លទ្ធផលអ្វីសោះសម្រាប់ជនរងគ្រោះ អាចនាំទៅដល់ការចលាចលផ្នែកនយោបាយខ្លាំងក្លា និងនាំប្រទេសជាតិធ្លាក់ទៅក្នុងភ្លើងសង្គ្រាមជាថ្មី ។ ដោយអ្នកនយោបាយនិងមន្ត្រីរដ្ឋាភិបាលបច្ចុប្បន្នភាគច្រើនធ្លាប់សហការជាមួយខ្មែរក្រហម ឬជាសមាជិកខ្មែរក្រហមតែម្តង ការព្រួយបារម្ភអំពីអស្ថិរភាពនយោបាយដោយការបង្កើតឲ្យមានតុលាការគឺពិតជាច្បាស់ពិតប្រាកដណាស់ ។ ដូច្នេះតុលាការឬគណៈកម្មការស្វែងរកការពិត ត្រូវតែយកមកពិចារណានូវក្តីកង្វល់អំពីស្ថិរភាពនិងសន្តិសុខរបស់ប្រជាជនកម្ពុជា ។

## ប្រធានបទទី២: ការពិតមួយដ៏ពេញលេញ

អ្នកដែលបានផ្តល់បទសម្ភាសន៍ខ្លះគ្រាន់តែចង់ដឹងការពិតអំពីអ្វីដែលបានកើតឡើងក្នុងសម័យខ្មែរក្រហមប៉ុណ្ណោះ ។ ខ្មែរ-

ក្រហមប៉ិនប្រសប់យ៉ាងខ្លាំងក្នុងការលាក់យ៉ាងជិតនូវការបញ្ជាជាខ្មែរសង្ងាត់ និងការបិទបាំងប្រជាជនកម្ពុជាពុំឲ្យដឹងថាអ្នកណាជាអ្នកបង្កើតឲ្យមានរបបប្រល័យពូជសាសន៍ ។ តាមទ្រឹស្តីព្រះពុទ្ធ ការថ្លែងការពិតគឺសំខាន់ចាំបាច់ណាស់ចំពោះតម្លៃសីលធម៌ ហើយការបង្ហាញការពិតអាចធ្វើឲ្យមានការផ្លាស់ប្តូរដ៏សំខាន់ ។ លើសពីនេះកន្លងមកគោលដៅនៃការផ្តន្ទាទោសគឺការអប់រំកែលម្អពុំមែនជាការសងសឹកទេ ។ ការផ្តន្ទាទោសជាទូទៅរួមមានការសារភាពនិងការសុំអត់ឱនទោសពុំមែនការផ្តន្ទាទោសលើរូបកាយ ឬការប្រហារជីវិតនោះឡើយ ។ ដូច្នេះការថ្លែងការពិតពីសំណាក់ឧក្រិដ្ឋជនមានតម្លៃយ៉ាងសំខាន់ចំពោះប្រជាជនកម្ពុជាជាច្រើនលើសលប់ ។

## ប្រធានបទទី៣ៈ ការកំណត់អំពីការទទួលខុសត្រូវ

ក្នុងការសម្ភាសជាច្រើនអ្នកផ្តល់បទសម្ភាសន៍បានលើកឡើងអំពីការទទួលខុសត្រូវចំពោះការបញ្ជា ។ តើនរណាជាអ្នកទទួលខុសត្រូវពិតប្រាកដចំពោះឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម? បញ្ហាការទទួលខុសត្រូវចំពោះការបញ្ជាទទួលការចាប់អារម្មណ៍ជាពិសេសចំពោះប្រជាជនកម្ពុជាដែលស្ថិតនៅក្រោមលទ្ធិផ្តាច់ការនិងរាជានិយមជាយូរមកហើយ ។ ចាប់ពីសម័យដែលមានស្តេចសោយរាជ្យរហូតដល់សម័យអាណានិគមបារាំង សម័យព្រះបាទ នរោត្តម សីហនុ និងសម័យលន់ណុល ប្រទេសកម្ពុជាត្រូវបានដឹកនាំដោយជនផ្តាច់ការជាប់ជាប្រចាំ ។ វាហាក់ដូចជានាំទៅរកការខ្វះចន្លោះនូវការអប់រំត្រឹមត្រូវដែលនឹងត្រូវពិភាក្សានូវចំណុចខាងក្រោម និងភាពងាយស្រួលក្នុងការអូសទាញ ។

ប្រជាជនកម្ពុជាមានប្រពៃណីគោរពកោតខ្លាចមេដឹកនាំខ្លាំងជាងអ្នកនយោបាយពួកបស្ចិមប្រទេសដែលបង្កើតច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិដោយខ្លួនឯង និងសម្រាប់ខ្លួនឯង ។ សូម្បីតែនៅក្នុងពេលដែលរួចផុតពីអំពើប្រល័យពូជសាសន៍និងសង្គ្រាមក៏ដោយ ក៏អ្នកដែលត្រូវបានសម្ភាសជាច្រើននៅតែមានបំណងផ្តល់ការទុកចិត្តចំពោះរដ្ឋាភិបាលថ្មីរបស់កម្ពុជា និងចង់អនុញ្ញាតឲ្យរដ្ឋាភិបាលនេះសម្រេចថាតើត្រូវដោះស្រាយយ៉ាងដូចម្តេចចំពោះឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ។ បញ្ហានេះធ្វើឲ្យ ខាឡូស នីណូ (អ្នកប្រាជ្ញច្បាប់អន្តរជាតិ) លើកជាសំណួរឡើងថា «តើការដាក់តម្លៃរបស់យើងផ្ទាល់តាមរយៈច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិទៅលើប្រជាជនដែលមិនត្រឹមតែមិនរួមចំណែកជាមួយតម្លៃទាំងនេះ ប៉ុន្តែថែមទាំងខ្វះខាតមូលដ្ឋានក្នុងការពិចារណាដើម្បីឲ្យខ្លួនអាចទទួលស្គាល់និងយល់អំពីតម្លៃទាំងនោះ ជាការត្រឹមត្រូវឬទេ?» ។ និយមន័យពីមុនអំពីការទទួលខុសត្រូវចំពោះការបញ្ជាត្រូវការឲ្យមានការពិនិត្យឡើងវិញក្នុងបរិបទនៃប្រទេសកម្ពុជា ដែលដាក់បន្ទុកនៃភ័ស្តុតាងកាន់តែធ្ងន់ធ្ងរចំពោះមេដឹកនាំកំពូល ។ តម្លៃនៃប្រជាជនកម្ពុជាតែងតែខុសពីតម្លៃរបស់ពួកបស្ចិមប្រទេសដែលជាមូលដ្ឋាននៃច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ ។ ឧទាហរណ៍ដូចជា ច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិសង្កត់ធ្ងន់ទៅលើបុគ្គលនិងលទ្ធភាពរបស់បុគ្គលម្នាក់ៗក្នុងការជ្រើសរើសថាតើត្រូវគោរពបញ្ជាដែលមិនស្របច្បាប់របស់មេដឹកនាំយោធាឬទេ ។ ការសន្មតនេះមិនត្រូវបានអនុវត្តចំពោះបញ្ហានៃប្រទេសកម្ពុជាឡើយ ។

អំពើឃោរឃៅព្រៃផ្សៃរបស់ខ្មែរក្រហមបានចោទជាបញ្ហាប្រហាក់ប្រហែលគ្នានេះដែរថា តើត្រូវចាត់វិធានការបែបណាចំពោះការសម្លាប់ជាបុគ្គល ឬការសម្លាប់ទាំងហ្វូងដែលស្ថិតក្នុងស្ថានភាពបង្ខិតបង្ខំ ។ នៅក្រោមច្បាប់ខ្មែរក្រហម ប្រជាជនកម្ពុជាត្រូវបានបង្អត់អាហារនិងបង្ខំឲ្យធ្វើការដូចទាសករ គឺក្នុងលក្ខខណ្ឌមួយដែលអ្នកទាំងនេះពុំមានការគិតគូរដោយឯករាជ្យ ឬសេរីភាពក្នុងការជ្រើសរើសតាមចិត្តចង់ ឬការគិតគូរវែងឆ្ងាយតាមទ្រឹស្តីបានពិតប្រាកដឡើយ ។ នៅពេលដែលការជ្រើសរើសមានតែសម្លាប់អ្នកដទៃ ឬត្រូវអ្នកដទៃសម្លាប់ តើនេះអាចធ្វើឲ្យឃាតកររួចផុតពីការទទួលខុសត្រូវឬទទួលខុសត្រូវក្នុងកម្រិតមួយស្រាលដែរឬទេ? ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ? ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍? តុលាការយោធាអន្តរជាតិក្រោយសង្គ្រាមលោកលើកទី២បានយល់ថា ការបង្ខិតបង្ខំគឺជាការការពារមួយដ៏គ្រប់គ្រាន់ ។ ទោះបីជាយ៉ាងនេះក្តីក្នុងរឿងក្តីថ្មីមួយពាក់ព័ន្ធនឹងអតីតយូហ្គោស្លាវី តុលាការឧក្រិដ្ឋកម្មអន្តរជាតិបានកំណត់ថា ការបង្ខិតបង្ខំអាចសម្រាលទម្ងន់សាលក្រមព្រហ្មទណ្ឌ ប៉ុន្តែពុំអាចការពារឧក្រិដ្ឋកម្មធ្ងន់ធ្ងរដូចជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ ។ ក្នុងករណីប្រទេសកម្ពុជាវិញ វាជាការសមស្របជាងបើធ្វើការផ្តោតតែទៅលើមេដឹកនាំកំពូលៗរបស់ខ្មែរក្រហមចំពោះការផ្តន្ទាទោសឧក្រិដ្ឋជាបុគ្គល ព្រោះ

ស្ថានភាពរស់នៅរបស់អ្នកផ្សេងទៀតអាចធ្វើឲ្យមានការលំបាកក្នុងការកំណត់ថាអ្នកទាំងនោះមានបំណងឧក្រិដ្ឋដែលទាមទារឲ្យមានចំពោះឧក្រិដ្ឋកម្មនេះ ។

## ប្រធានបទទី៤: តួអង្គអន្តរជាតិ

អ្នកដែលបានផ្តល់បទសម្ភាសន៍បានសម្តែងក្តីបារម្ភអំពីការពាក់ព័ន្ធនឹងការគាំទ្ររបស់បរទេសចំពោះរបបខ្មែរក្រហម ។ អ្នកដែលបានផ្តល់បទសម្ភាសន៍ខ្លះប្រកាន់នូវគំនិតពូជសាសន៍និយមដោយពុំជឿថាខ្មែរអាចសម្លាប់ខ្មែរ ហើយលើកឡើងថាមាននរណាម្នាក់ឬកម្លាំងបរទេសនៅពីក្រោយខ្មែរក្រហម ។ ចំណែកអ្នកឯទៀតគ្រាន់តែចង់រកឲ្យឃើញថាតើប្រទេសណាខ្លះដែលគាំទ្រខ្មែរក្រហម ។

ដោយពុំមានចម្លើយងាយណាមួយចំពោះសំណួរថាអ្នកណាគាំទ្រខ្មែរក្រហម ហើយមានការខណ្ឌចែកយ៉ាងច្បាស់រវាងពិរុទ្ធភាពចំពោះការសមគំនិតនិងការមិនធ្វើអន្តរាគមន៍ ដូច្នេះវាត្រូវការការស្រាវជ្រាវបន្ថែមទៀត ។ សហរដ្ឋអាមេរិក ថៃ និងសាធារណរដ្ឋប្រជាមានិតចិន សុទ្ធតែត្រូវបានលើកហេតុផលអះអាងថាគាំទ្រខ្មែរក្រហមផ្នែកហិរញ្ញវត្ថុ ឬផ្នែកនយោបាយ ឬទាំងពីរផ្នែកនេះតែម្តង ។ ប្រជាជនកម្ពុជាខ្លះអះអាងថា ខ្មែរក្រហមពុំអាចស្ថិតនៅក្នុងអំណាចបានទេបើពុំមានប្រទេសផ្សេងៗគាំទ្រ ។ បញ្ហាការគាំទ្រពីខាងក្រៅនេះត្រូវតែពិនិត្យឲ្យបានហ្មត់ចត់ដើម្បីបង្កើតចំណែកមួយនៃការចងចាំប្រវត្តិសាស្ត្ររួមគ្នាមួយនិងការអត់ឱនគ្រាប្រណីទោសក្នុងប្រទេសកម្ពុជា ។ តុលាការតែឯកឯងពុំមានលទ្ធភាពសម្រេចកិច្ចការនេះឡើយ ។

## ប្រធានបទទី៥: ការលើកលែងទោស

បញ្ហាទី៥គឺបញ្ហាលើកលែងទោស ។ នេះជាបញ្ហាដែលមានការចាប់អារម្មណ៍ជាពិសេសក្នុងប្រទេសកម្ពុជាដែលជាប្រទេសកាន់ព្រះពុទ្ធសាសនាយ៉ាងខ្លាំងក្លាជាយូរមកហើយ ។ ទាំងព្រះពុទ្ធសាសនា ទាំងបំណងចង់ឲ្យមានការផ្សះផ្សាជាតិ ហាក់ដូចជាកំពុងធ្វើដំណើរទៅរកការលើកលែងទោស ហើយជិតពាក់កណ្តាលនៃអ្នកដែលបានផ្តល់បទសម្ភាសន៍យល់ថា ការលើកលែងទោសចំពោះអ្នកសារភាពនិងសូមអភ័យទោសក្នុងតុលាការអាចទទួលយកបាន ។ ប៉ុន្តែពាក់កណ្តាលទៀតដែលក្នុងនោះមានទាំងព្រះសង្ឃផងយល់ឃើញផ្សេងទៅវិញថា ឧក្រិដ្ឋកម្មដែលខ្មែរក្រហមបានប្រព្រឹត្តគឺសាហាវយង់ឃ្នងណាស់ ដូច្នេះពុំអាចឲ្យមានការលើកលែងទោសបានទេ ។ បញ្ហានេះបណ្តាលឲ្យមានការលើកឡើងនូវសំណួរដែលមានលក្ខណៈចិត្តសាស្ត្រនិងទស្សនវិជ្ជាដ៏សំខាន់អំពីការកំណត់ព្រំដែននៃការអត់ឱនគ្រាប្រណីចំពោះមនុស្សមានឧក្រិដ្ឋកម្មដ៏សែនរន្ធត់មួយចំនួន ដែលការអត់ឱនចំពោះឧក្រិដ្ឋកម្មទាំងនេះជាដូវការ (លើសពីការលើកលែងទោសជាបុគ្គល) អាចកាត់បន្ថយភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មទាំងនេះ ។



កងទ័ពខ្មែរក្រហម

វាជាការសំខាន់ដែលត្រូវរំឭកឡើងវិញថា ទោះជាអ្នកបានផ្តល់បទសម្ភាសន៍ដែលចុងបញ្ចប់យល់ព្រមលើកលែងទោសក៏ពិតមែន តែអ្នកទាំងនេះទទួលយកវានៅក្រោមលក្ខខណ្ឌថាអ្នកដែលបានរកឃើញថាមានទោសនៅក្នុងតុលាការ(ឬគណៈកម្មការស្វែងរកការពិត) យល់ព្រមទទួលស្គាល់នូវអ្វីដែលខ្លួនបានធ្វើនិងសារភាពនូវទោសកំហុសរបស់ខ្លួន ហើយធ្វើការសុំខមាទោសជាសាធារណៈចំពោះមុខប្រជាជនកម្ពុជាគ្រប់រូប ។ អ្នកសិក្សាជាន់ខ្ពស់មួយចំនួនរួមបញ្ចូលទាំង ឆេរីវ បេស្សិនី ផង បានទាំងនិយាយថា នេះគឺជាវិធីតែមួយគត់ដែលអាចធ្វើឲ្យការលើកលែងទោសមានភាពស្របច្បាប់ ។ នេះគឺដូចអ្វីដែលមន្ត្រីរាជរដ្ឋាភិបាលកម្ពុជាម្នាក់បានថ្លែងថា ការលើកលែងទោសពុំអាចផ្តល់ឬធានាចំពោះមុខតុលាការឡើយ ។ ជនរាល់រូបត្រូវសន្មតថាគ្មានទោសរហូតដល់ត្រូវបង្ហាញថាមានកំហុស ដូច្នេះពុំមានកំហុសអ្វីដែល

ត្រូវអត់ឱនលើកលែងទោសមុនពេលដែលអង្គតុលាការបានពិនិត្យអំពីស្ថានភាពផ្ទាល់របស់ខ្លួន ។ ប្រយោជន៍ដ៏ធំមួយនៃការលើកលែងទោសគឺវាជំរុញជនដែលមានទោសកំហុសឲ្យពន្យល់អំពីអ្វីដែលបានកើតឡើងពិតប្រាកដ និងដាក់ទោសអ្នកដែលមានទោសមួយចំនួនទៀត ។ ប្រសិនបើការសារភាពដោយស្ម័គ្រចិត្តក្នុងតុលាការពុំមែនជាផ្នែកមួយនៃដំណើរការលើកលែងទោសពេលនោះការលើកលែងទោសនឹងបាត់បង់គោលដៅសំខាន់មួយរបស់ខ្លួន ។ ជាចុងក្រោយ ដើម្បីឲ្យការលើកលែងទោសបង្ហាញឲ្យឃើញត្រឹមត្រូវពិតប្រាកដនូវសេចក្តីត្រូវការរបស់គ្រួសារនិង


កម្មាភិបាលខ្មែរក្រហម

អ្នកស្រឡាញ់រាប់អានជនរងគ្រោះការសុំទោសជាសាធារណៈគឺត្រូវធ្វើឡើងជាដាច់ខាត ។ ការលើកលែងទោសពុំមែនប្រើប្រាស់ជាមធ្យោបាយសម្រាប់ធ្វើឲ្យពិរុទ្ធជនពិតប្រាកដរួចផុតពីការផ្តន្ទាទោសនោះទេ ផ្ទុយទៅវិញវាគឺជាវិធីមួយនៃការដោះស្រាយភាពតានតឹងទាំងខាងឧក្រិដ្ឋជនក៏ដូចជាខាងជនរងគ្រោះ ។ ការសារភាពរបស់ជនល្មើសអំពីឧក្រិដ្ឋកម្មរបស់ខ្លួនដែលធ្វើឲ្យខ្លួនរួចផុតពីការផ្តន្ទាទោស ជាការធ្វើឲ្យមានភាពត្រឹមត្រូវតាមច្បាប់ចំពោះការបាត់បង់និងការឈឺចាប់របស់ជនរងគ្រោះ ហើយដាក់ទណ្ឌកម្មខាងផ្លូវចិត្តប្រកបដោយសន្តានុពលចំពោះជនដែលមានទោសកំហុស ។ ទាំងសេចក្តីខ្មាសអៀន ចំពោះសាធារណជន ទាំងការភ្ញាក់ដឹងខ្លួនអំពីឧក្រិដ្ឋកម្មដែលខ្លួនបានប្រព្រឹត្ត សុទ្ធតែរួមចំណែកក្នុងការផ្តន្ទាទោសឧក្រិដ្ឋជន ។ ដូច្នេះការទទួលស្គាល់ ការសារភាពទោសកំហុសក្នុងតុលាការ និងការសុំទោសចំពោះជនរងគ្រោះផ្ទាល់ឬជាសាធារណៈ គឺជាធាតុផ្សំដ៏សំខាន់បំផុត៣នៃការលើកលែងទោស ហើយប្រជាជនកម្ពុជាដែលបានផ្តល់បទសម្ភាសន៍ជឿថា ការលើកលែងទោសមិនអាចផ្តល់ឲ្យដោយពុំមានធាតុផ្សំដ៏សំខាន់ទាំង៣នេះឡើយ ។

អ្នកដែលបានផ្តល់បទសម្ភាសន៍ទាំងនោះគាំទ្រការលើកលែងទោសក្រោមលក្ខខណ្ឌដែលបានលើកឡើងខាងលើ ហើយបានពន្យល់ការអត់ឱនទោសរបស់ខ្លួនតាមទ្រឹស្តីរបស់ព្រះពុទ្ធ ។ ជំនឿថា «ពៀររំងាប់ដោយការមិនចងពៀរ» ត្រូវបានលើកឡើងជាច្រើនលើកច្រើនសានៅក្នុងបទសម្ភាសន៍ ។ វាជាការសំខាន់ដែលត្រូវកត់សម្គាល់ថា ជំនឿទៅលើការលើកលែងទោសតែងតែពុំត្រូវបានរួមបញ្ចូលមេដឹកនាំខ្មែរក្រហមកំពូលៗឡើយ ។ អ្នកដែលបានផ្តល់បទសម្ភាសន៍ម្នាក់បានរំឭករឿងរបស់អង្គលីមា ដែលបានប្រព្រឹត្ត ឧក្រិដ្ឋកម្មដ៏គួរឲ្យរន្ធត់និងខ្ទើមរអើមនៅក្រោមការគ្រប់គ្រងចិត្តនិងការបញ្ជាពីគ្រូរបស់ខ្លួន ។ កូនសិស្សវ័យក្មេងរូបនេះត្រូវបានអត់ឱនទោស ប៉ុន្តែគ្រូរបស់កូនសិស្សនេះពុំត្រូវបានលើកលែងទោសឡើយ ។ អ្នកដែលបានផ្តល់បទសម្ភាសន៍ខាងលើបាន ប្រដូចរឿងនេះទៅនឹងស្ថានភាពរបស់ខ្មែរក្រហមហើយបានទទូចថា ពុំត្រូវផ្តល់ការលើកលែងទោសដល់មេដឹកនាំកំពូលៗរបស់របបនោះឡើយ ។ ដូច្នេះទាំងតាមផ្លូវលោក ទាំងតាមផ្លូវធម៌ ការលើកលែងទោសពុំអាចធ្វើឡើងជាទូទៅឡើយ ។

ជនម្នាក់ក្នុងចំណោមអ្នកដែលបានសង្កត់ធ្ងន់ទៅលើបញ្ហាលើកលែងទោសបានថ្លែងថា ការអត់ឱននិងការត្រាប្រណីទោសគឺជាលក្ខណៈដើមរបស់ខ្មែរ ។ ប្រហែលជាអាចមានការសន្មតឬអំណះអំណាងផ្អែកសង្គមវិទ្យាជាមូលដ្ឋានចំពោះការវែកញែកខាងលើនេះ ប៉ុន្តែតាមរយៈការសម្ភាសនិងសេចក្តីថ្លែងការណ៍មួយចំនួន ការពោលអះអាងខាងលើនេះហាក់ដូចជាផ្អែកទៅលើទស្សនៈពូជសាសន៍និងការកំណត់ផ្អែកជីវសាស្ត្រ ។ គំនិតចង់ឲ្យ

មានការបន្ធូរបន្ថយនេះអាចនាំទៅរកការចោទសួរអំពីសុពលភាពនៃគំនិតនេះ ។ វាអាចជាការសមហេតុផលដែលថាអ្នកដែលបានផ្តល់បទសម្ភាសន៍ឯកភាពចំពោះការលើកលែងទោស ដោយសារច្បាប់នៃប្រទេសកម្ពុជាអនុញ្ញាតឲ្យព្រះមហាក្សត្រប្រទានការលើកលែងទោស ឬប្រហែលជាអ្នកសម្ភាសន៍ផ្តើមជជែកអំពីគំនិតនៃការលើកលែងទោសនេះជាមួយពួកគាត់ ។ អ្នកដែលបានផ្តល់បទសម្ភាសន៍មួយចំនួនបានឲ្យដឹងថា ការលើកលែងទោសអាចទទួលយកបានប្រសិនបើការលើកលែងទោសនោះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ឯអ្នកមួយចំនួនទៀតដើមឡើយថាយល់ព្រមចំពោះការលើកលែងទោស តែក្រោយមកបែរជាបង្ហាញអំពីសេចក្តីប្រាថ្នាដ៏មុតមាំចង់ឲ្យមានការផ្តន្ទាទោសទៅវិញ ។ ខណៈដែលអ្នកផ្តល់បទសម្ភាសន៍សម្តែងឲ្យឃើញថាខ្លួនហាក់ដូចជាយល់ព្រមឲ្យមានការលើកលែងទោស វាជាការសំខាន់ដែលត្រូវកត់សម្គាល់នូវការកន្តល់និងការដាក់លក្ខខណ្ឌទាំងនេះ ។

សំអាងមួយទៀតដែលត្រូវបានប្រើដើម្បីធ្វើការលើកលែងទោស ហើយដែលត្រូវបានប្រើចំពោះការលើកលែងទោសឲ្យ អៀង សារី (សមមិត្តវ៉ាន់) គឺការផ្សះផ្សាជាតិ ។ បញ្ហាដែលគួរឲ្យចាប់អារម្មណ៍នោះគឺការផ្សះផ្សាជាតិពុំត្រូវបានលើកឡើងដោយផ្ទាល់ក្នុងការសម្ភាសដែលពាក់ព័ន្ធនឹងបញ្ហាលើកលែងទោសឡើយ ។ បញ្ហាថាតើការលើកលែងទោសប្រសើរជាងការផ្តន្ទាទោសសម្រាប់គោលដៅស្ថិរភាពនិងសន្តិភាព នៅតែកំពុងត្រូវបានជជែកពិភាក្សានៅឡើយ ។ ការផ្តល់ការលើកលែងទោសដូចដែលបានធ្វើឡើងដោយគណៈកម្មការស្វែងរកការពិតនិងផ្សះផ្សានៅប្រទេសអាហ្វ្រិកខាងត្បូង ជាការលើកទឹកចិត្តឧក្រិដ្ឋជនឲ្យសារភាពអំពីទង្វើដែលខ្លួនបានប្រព្រឹត្ត និងបង្កើតឲ្យមានរូបភាពនៃការពិតមួយដ៏ពេញលេញ ហើយទម្រង់នៃការអត់ឱនទោសនេះអាចបញ្ចប់ការចងពៀរនិងអំពើហិង្សា ។ ទោះបីជាយ៉ាងនេះក្តី ប្រជាធិបតេយ្យមួយដែលមានស្ថិរភាពត្រូវផ្អែកទៅលើគោលការណ៍នៃនីតិរដ្ឋដែលប្រជាពលរដ្ឋត្រូវទទួលខុសត្រូវស្មើៗគ្នាចំពោះអំពើរបស់ខ្លួន ។ នយោបាយលើកលែងទោសគួរតែធ្វើយ៉ាងណាឲ្យមានការកំណត់អំពីការទទួលខុសត្រូវ និងការដាក់ទោសកំហុសទៅតាមការផ្តន្ទាទោសរបស់សង្គមជាជាងការអនុម័តភាពរួចទោសជាទូទៅ ។

អ្នកផ្តល់បទសម្ភាសន៍ដែលមិនយល់ព្រមចំពោះការលើកលែងទោស ភាគច្រើនជាបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ស្ត្រី និងអ្នកនយោបាយ ។ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលដែលបានផ្តល់បទសម្ភាសន៍ បារម្ភអំពីសេចក្តីថ្លៃថ្នូររបស់មនុស្ស និងតម្លៃនៃជីវិតមនុស្ស ។ អ្នកទាំងនេះក៏បានលើកឡើងផងដែរអំពីភាពស្ថិតនៅជាធរមាននៃច្បាប់អន្តរជាតិពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផ្សេងៗទៀត ។ ខុសពីអ្នកនយោបាយដែលអាចមានហេតុផលលាក់កំបាំងចំពោះការជំទាស់នឹងការលើកលែងទោស (ពោលគឺការផ្តន្ទាទោសចំពោះភាគីប្រឆាំងរបស់ខ្លួន) បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលបង្ហាញឲ្យឃើញពីក្តីកង្វល់ដ៏ត្រឹមត្រូវនិងអាចឲ្យជឿបានអំពីផលប៉ះពាល់នៃការលើកលែងទោសចំពោះច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ ។ ដូច្នេះវាជាការល្អជាងបើបង្កើតតុលាការសម្រាប់កាត់ទោសមេដឹកនាំកំពូលៗ ហើយបង្កើតគណៈកម្មការស្វែងរកការពិតសម្រាប់អ្នករំលោភបំពានដែលមានឋានៈតូចតាច ។

នេះគឺជាការថ្លែងបញ្ជាក់ដ៏មានអានុភាពពីហេតុផលនៃការបដិសេធចំពោះការលើកលែងទោសរបស់អ្នកដែលបានផ្តល់បទសម្ភាសន៍ម្នាក់៖ «តើត្រូវអាណិតនរណា? ប៉ុល ពត ឬប្រជាជនកម្ពុជា២លាននាក់? ប្រជាជនកម្ពុជាជាច្រើនទទួលរងការឈឺចាប់អស់រយៈពេល២០ឆ្នាំដោយសារការផ្តន្ទាទោសដ៏តិចតួច ឬគ្មានការផ្តន្ទាទោសទាល់តែសោះ ហើយមានកំហឹងចំពោះយុត្តិធម៌» ។ អារម្មណ៍នេះគូសបញ្ជាក់ឲ្យឃើញពីលទ្ធភាពរបស់អ្នកដែលបានផ្តល់បទសម្ភាសន៍ជាច្រើនក្នុងការទម្លាក់កំហុសដែលបានកើតមានក្នុងរបបខ្មែរក្រហមចំពោះមេដឹកនាំកំពូលនៃរបបនោះ ។ ការបដិសេធការលើកលែងទោសចំពោះមេដឹកនាំកំពូលៗនៃរបបខ្មែរក្រហម អាចធ្វើឲ្យប្រជាជនកម្ពុជារលត់កំហឹងបំភ្លេចការបាត់បង់និងការឈឺចាប់ដែលស្ថិតនៅក្នុងខ្លួនរបស់ពួកគាត់អស់ជាច្រើនឆ្នាំ ហើយការបដិសេធនេះប្រហែលជាអាចរំដោះសមាជិកខ្មែរក្រហមដែលមានឋានៈតូចតាចដែលអនុវត្តតាមបញ្ជាដ៏បង្ខិតបង្ខំរបស់មេដឹកនាំកំពូលៗឲ្យរួចខ្លួន ។ **(នៅមានត)**

**ចាយ៉ា វ៉ាមជី**

## សំឡេងចេញពីផ្ទះ

# ការសម្លាប់រង្គាលនៅបឹងធន្លេសាប

ខ្យល់ត្រជាក់ពីទិសខគ្គរដែលមានប្រភពនៅភ្នំហិមាល័យ លែងធ្វើឲ្យខ្ញុំរងានិងប៉ះពាល់ដល់សុខភាពផ្លូវចិត្តរបស់ខ្ញុំទៀតហើយ ។ ខ្ញុំពេញចិត្តហើយរីករាយ ទោះជាពេលនោះខ្ញុំមានពេលសម្រាប់តែ២-៣ម៉ោង និងពុំមានអ្វីក្នុងពោះបន្តិចក៏ដោយ ។ បន្ទាប់ពីរយៈពេលវែងបានកន្លងផុតទៅ ទីបំផុតខ្ញុំបានជួបជុំគ្រួសាររបស់ខ្ញុំវិញ ។ ការជួបជុំនេះបានធ្វើឲ្យខ្ញុំមានព្រលឹងក្នុងខ្លួន និងមានចិត្តគំនិតគិតគូរឡើងវិញ ។ ខ្ញុំរីករាយក្នុងខណៈពេលដែលនៅទីបំផុតបានជួបជុំគ្រួសារដែលបាត់ជាយូរហើយជាថ្មីម្តងទៀត ។ តើពេលនេះលែងមានបញ្ហាអ្វីទៀតហើយមែនទេ? សូម្បីតែកំពុងស្ថិតនៅក្រោមរបបដ៏គួរឲ្យខ្លាចដែលមានឈ្មោះថា «អង្គការ» នោះ ។

គ្រាន់តែថ្ងៃរះភ្លាម អ្នកយាមចាប់ផ្តើមទាត់ប្រជាជនឲ្យក្រោកឡើងនិងឲ្យធ្វើដំណើរទៅមុខទៀត ។ ពួកអ្នកយាមទាំងនេះជាអ្នកធ្វើឲ្យមនុស្សក្លាយជាទាសករ ត្រួតពិនិត្យលើការងាររបស់មនុស្សផងទាំងពួង និងម្ចាស់ការលើការងាររបស់ខ្លួន ។ ខ្ញុំបានក្រោកឡើងដោយយឺតៗ និងមានសេចក្តីរីករាយដោយដឹងថាអ្វីៗកាលពីយប់នោះពុំមែនជាក្តីសុបិន ។ ក្នុងវ័យ១៥ឆ្នាំ ខ្ញុំមានអាយុច្រើននិងរូបរាងធំល្មម ដោយមិនចាំបាច់ម្តាយរបស់ខ្ញុំត្រូវដឹកដៃខ្ញុំដើរជាមួយគាត់ទៀតនោះទេ ប៉ុន្តែគាត់នៅតែដឹកដៃខ្ញុំហើយមិនព្រមឲ្យខ្ញុំទៅណាឡើយ ។ ខ្ញុំពុំចង់បែកពីឪពុកម្តាយនិងបងប្អូនខ្ញុំទៀតទេ ប៉ុន្តែខ្ញុំត្រូវតែទៅចូលក្រុមរបស់ខ្ញុំ ។ ខ្ញុំបានត្រឡប់ទៅកាន់ជំរំរបស់ខ្ញុំវិញទាំងរួញរាចិត្តដើម្បីជួយការងារឪពុកដ៏ចាស់ជរារបស់នាង សាអ៊ុម ។ យើងបានរួមគ្នាជាក្រុមម្តងទៀតដែលមានសមាជិក១៦នាក់គ្រប់វ័យនិងមានសមត្ថភាពគ្រប់បែបគ្រប់យ៉ាង ។

បន្ទាប់ពីធ្វើដំណើរយ៉ាងលំបាកអស់រយៈពេលជិត២ថ្ងៃ យើងបានទៅដល់កន្លែងមួយដែលមានឈ្មោះថា «ភ្នំតាសួស» មានចម្ងាយប្រហែលមួយគីឡូម៉ែត្រកន្លះខាងត្បូងកែវពួ ។ វាជាតំបន់មួយដែលខ្ញុំស្គាល់ច្បាស់ព្រោះខ្ញុំបានរស់នៅកែវពួ ចាប់តាំងពីប្រទេសកម្ពុជាបានធ្លាក់ទៅក្នុងដៃខ្មែរក្រហម ។ ជាកន្លែងដែលខ្ញុំធ្លាប់រស់នៅកាលពីឆ្នាំ១៩៧៥-៧៦ មុនពេលធ្វើដំណើរដោយថ្មើរជើងដ៏វែងឆ្ងាយទៅកាន់ក្រុងតាប៉ាង ។

តាមអ្វីដែលខ្ញុំមើលឃើញ ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងដោយសារមានការផ្លាស់ប្តូរជាច្រើនដែលកើតមានឡើងនៅតំបន់នេះ ។ ការផ្លាស់ប្តូរមានច្រើនស្ទើរតែរៀបរាប់មិនអស់ ។ កន្លែងសម្គាល់ពីរ-បី ទំនប់ភ្លោះ២នៅដដែល ប៉ុន្តែអ្វីៗផ្សេងទៀតសឹងតែទាំងអស់បានផ្លាស់ប្តូរអស់រលីង ។ មានមនុស្សជាច្រើនត្រូវបានបង្ខំឲ្យធ្វើការនៅការដ្ឋានស្តុកទឹកដ៏ធំនេះ ។ មានមនុស្សយ៉ាងតិចណាស់ក៏ ១៥ ០០០នាក់ដែរ ធ្វើការនៅក្នុងការដ្ឋាននេះ ។ ក្រុមរបស់យើងត្រូវបានពួកខ្មែរក្រហមប្រាប់ឲ្យបោះជំរំនៅកន្លែងណាក៏ដោយឲ្យតែមានដីស្ងួត ប៉ុន្តែមិនឲ្យពួកយើងបែកពីក្រុមឡើយ ។ ក្នុងចន្លោះពេល១ម៉ោងដែលយើងបានទៅដល់ភ្នំតាសួសភ្លាម កម្មាភិបាលអង្គការលើក៏បានមកដល់ដើម្បីនាំកម្លាំងទៅធ្វើការ ។

គ្រប់គ្នាលើកលែងតែ សាអ៊ុម ដែលជិតសម្រាលកូននិងឪពុករបស់នាង បានចុះបំពេញការងារនៅការដ្ឋានភ្លាមៗ ។ សេរី បានទទួលការអនុញ្ញាតឲ្យរកឈើសម្រាប់ការសម្រាលកូន



របស់ សាអ៊ុម ។

យើងមានការហេវហត់និងអស់កម្លាំងជាខ្លាំងបន្ទាប់ពីការធ្វើដំណើរដ៏វែងឆ្ងាយនេះ ។ អង្គការលើពុំអនុញ្ញាតឲ្យពួកយើងសម្រាកមុនពេលពួកយើងចុះការដ្ឋានម្តងទៀតឡើយ ។ ខ្ញុំក៏ហេវហត់អស់កម្លាំងខ្លាំងណាស់ដែរ ។ ខ្ញុំជឿថា គ្រួសាររបស់ខ្ញុំក៏មានអារម្មណ៍បែបនេះដែរចំពោះការសម្រាកនេះ ។ ឪពុកម្តាយ និងបងប្អូនរបស់ខ្ញុំនៅជិតគ្នាប៉ុន្តែពុំជជែកគ្នាច្រើនទេ ។ ពួកគាត់ធ្វើការដូចអ្នកផ្សេងទៀតដែរ ។ មនុស្សជាច្រើនជីកនិងជញ្ជូនដីនិងក្រួសពីរណ្តៅដ៏ជ្រៅនិងគួរឲ្យព្រឺក្បាលនេះ ។ ខ្ញុំមើលទាហានដែលវាយមនុស្សនឹងដំបងដោយសារពួកគាត់ពុំមានកម្លាំងធ្វើការបន្ត ពុំមែនដោយសារពួកគាត់ពុំចង់ធ្វើការទេ ។ វាជាអំពើអាក្រក់ គឺអាក្រក់ជាទីបំផុត ។ អំពើទាសភាពរបស់អង្គការថ្នាក់លើបានឡើងដល់កម្រិតកំពូល ។

គឺនៅភ្នំតាសួសនេះហើយដែលទីបំផុតខ្ញុំបានយល់ច្បាស់ពីជោគវាសនារបស់មនុស្សផងទាំងពួង ។ យើងត្រូវបានទាហានថ្មីមួយក្រុមបង្ខំឲ្យធ្វើការពេញមួយថ្ងៃនិងសឹងតែពេញមួយយប់ទៀតក្នុងរយៈពេល៥ថ្ងៃដ៏ឈឺចាប់ ។ ក្រុមដែលបាននាំពួកយើងពីមុនបានចាកចេញតាំងពីយូរមកហើយ ។ ក្រុមថ្មីនេះមានភាពឃោរឃៅនិងគ្មានក្តីត្រាប្រណីបន្តិចសោះឡើយ ។ ខ្ញុំបានឃើញផ្ទាល់នឹងភ្នែកនូវការបាត់បង់ជីវិតរបស់មនុស្សជាច្រើនដោយត្រូវកម្តៅថ្ងៃខ្លាំង រងទុក្ខដោយជំងឺ ការអស់កម្លាំងពីខ្លួន និងការអត់អាហារ ។ មនុស្សភាគច្រើនស្លាប់ដោយសារទាហានវាយដំ ហើយមនុស្សមិនតិចទេដែលត្រូវបាននាំចេញនៅពេលយប់ទៅកាន់ទីដៅមួយដែលសឹងតែប្រាកដមួយរយភាគរយថាជា «កន្លែងមរណៈ» ។ គ្រប់ពេលវេលា ខ្ញុំតែងបារម្ភថាតើពេលណានឹងដល់វេនពួកយើង ។ ខ្ញុំប្រាថ្នាចង់ឲ្យវាកើតឡើងឆាប់ៗដើម្បីមិនបាច់ទទួលរងការឈឺចាប់ដូចអ្នកដែលយើងបានឃើញផ្ទាល់នឹងភ្នែកស្រាប់ ។

មនុស្សនៅក្នុងក្រុមរបស់ខ្ញុំចាប់ផ្តើមស្លាប់ ហើយធ្លាក់ដូចរុយទៅក្នុងបាតប្រឡាយដែលសុទ្ធតែភក់ ។ សឹងតែពុំមាននរណាម្នាក់ខ្វាយខ្វល់យកអ្នកទាំងនេះទៅកប់ឲ្យបានត្រឹមត្រូវឡើយ ។ ខ្ញុំបានឃើញសាកសព និងមនុស្សជិតស្លាប់គ្រប់ទីកន្លែង ។ យើងទាំងអស់គ្នាអស់កម្លាំងនិងខ្សោយយ៉ាងខ្លាំងពុំអាចធ្វើអ្វីបាន ។ យូរៗម្តង មនុស្សមួយក្រុមក្នុងចំណោមពួកយើងធ្វើការប្រមែប្រមូលសាកសពនៅក្រោមការត្រួតពិនិត្យមើលយ៉ាងហ្មត់ចត់ពីសំណាក់អ្នកយាមប្រដាប់អាវុធ ។ ស្ទើរតែពុំមាននរណាម្នាក់ចូលរួមមរណទុក្ខដល់អ្នកស្លាប់បាត់បង់ជីវិតឡើយ គឺសូម្បីតែអ្នកដែលជាញាតិសន្តានក៏បង្ហាញនូវក្តីរន្ធត់ញាប់ញ័រដ៏តិចតួចប៉ុណ្ណោះ ព្រោះអ្នកទាំងនេះដឹងថាអ្នកដែលបានស្លាប់បាត់បង់ជីវិតនឹងលែងទទួលរងនូវការឈឺចាប់ទៀតហើយ ។ យើងទាំងអស់គ្នាប្រៀបដូចជាក្រុមខ្មោចដែលមានជីវិតដូច្នោះដែរ ។ ជាការពិតណាស់ ខ្ញុំបានគិតថាវាស្រួលជាងនេះខ្លាំងណាស់ បើពួកនោះមកនាំយើងយកទៅសម្លាប់ ។ តើពួកនោះនឹងមកបញ្ចប់ក្តីទុក្ខវេទនារបស់យើងនៅពេលណា? ខ្ញុំរង់ចាំហើយរង់ចាំទៀត ប៉ុន្តែពួកនោះពុំបានមកឡើយ ។

ខ្ញុំត្រូវបានបុករុកយ៉ាងខ្លាំងដោយវត្ថុដ៏ស្រួចមួយ និងត្រូវ



មកទល់បច្ចុប្បន្ននេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានស្រាវជ្រាវរកឃើញទីតាំងសម្លាប់មនុស្សក្នុងរបបខ្មែរក្រហមចំនួន៥៤០កន្លែងរួចមកហើយ ។ ការសិក្សាជាលម្អិតអំពីទីតាំងសម្លាប់ និងប្រព័ន្ធសន្តិសុខខ្មែរក្រហមបាននឹងកំពុងប្រព្រឹត្តទៅ ។ ចំណុចនីមួយៗនៅលើផែនទីនេះ គឺជាចំណុចកំណត់ទីតាំងនៃរណ្តៅសាកសព គុក និងបូជនីយដ្ឋានតម្កល់អដ្ឋិធាតុ ។

បានធ្វើឲ្យភ្ញាក់ពីការងោកងុយនៅក្នុងបាតរណ្តៅដែលមានសុទ្ធតែភក់ ។ ខ្ញុំបានបើកភ្នែកឃើតៗមើលទាហានដែលមានអាយុប្រហែល១០ឆ្នាំដែលនៅតែបន្តរុញខ្ញុំដោយកាំភ្លើងអាកា-៤៧ដែលហាក់ដូចជាធំជាងមាឌរបស់ខ្លួនទៅទៀតនោះ ។ ទាហាននោះមានអាយុមិនលើសពី១២ឆ្នាំទេ គឺយ៉ាងហោចណាស់ក៏អាយុតិចជាងខ្ញុំ៣ឆ្នាំដែរ ប៉ុន្តែធាត់ជាងខ្ញុំច្រើន ។ «ទៅមិត្ត! ទៅឥឡូវនេះ!» ទាហាននោះស្រែកដាក់ខ្ញុំដោយក្រេវក្រោធឲ្យខ្ញុំងើបចេញពីភក់ ។ ខ្ញុំនឹកក្នុងចិត្តថា «ចូលមក ហើយបាញ់ខ្ញុំទៅ!» ។ ខ្ញុំហៀបតែនឹងស្លាប់ទៅហើយ ។ ក្នុងស្ថានការណ៍នោះខ្ញុំពុំមានសង្ឃឹមអ្វីសោះឡើយ ។ ទីបញ្ចប់ខ្ញុំបានប្រឹងទាំងគ្មានកម្លាំងទាញរាងកាយដ៏ស្គមស្គាំងចេញពីភក់ហើយដើរដោយគ្មានកម្លាំងកំហែងក្នុងខ្លួនឆ្ពោះទៅកាន់ក្រុមរបស់ខ្ញុំដែលកំពុងតែត្រូវបានប្រមូលផ្តុំក្នុងនោះក៏មានគ្រួសាររបស់ខ្ញុំដែរ ។ ចុងក្រោយវាជាពេលវេលារបស់យើងដែលត្រូវទៅមុខ ។

ខ្ញុំចាប់មានអារម្មណ៍ច្របូកច្របល់ចំពោះផែនការផ្លាស់ប្តូរកន្លែងភ្លាមៗបែបនេះ ។ ជាធម្មតា យើងត្រូវស្នាក់នៅកន្លែងមួយរាប់អាទិត្យឬរាប់ខែមុននឹងបញ្ជូនទៅកាន់កន្លែងថ្មី ។ ខ្ញុំបានប្រាថ្នាឲ្យកងការពារទាំងនេះមកយកយើងទៅ ពេលនេះពេលវេលាមកដល់ហើយ តែខ្ញុំបែរជាមានគំនិតផ្សេង ។ ទោះបីជាយ៉ាងណាក៏ដោយ ខ្ញុំបានរៀបចំខ្លួនរួចស្រេចបាច់ណាស់ទៅហើយបន្ទាប់ពីរយៈពេល៥ថ្ងៃ៥យប់ដ៏សែនយូរនិងសែនវេទនាដោយពុំបានបរិភោគនិងសម្រាកគ្រប់គ្រាន់ ដើម្បីចាកចេញទោះជាទៅកន្លែងណាក៏ដោយ ។ ខ្ញុំគ្រាន់តែចង់ចាកចេញពីកន្លែងនេះសូម្បីតែវាមានន័យថាជាការទៅរកសេចក្តីស្លាប់ភ្លាមៗក៏ដោយ ។ ការសង្កេតមើលអ្នកផ្សេងរួមទាំងសមាជិកគ្រួសាររបស់ខ្ញុំផង អ្នកទាំងនោះក៏ត្រៀមជាស្រេចដើម្បីចាកចេញដែរ ។ ពុំមានអ្វីអាក្រក់ជាងការដែលកងការពារទាំងនោះបានប្រព្រឹត្តមកលើយើងឡើយ ពិសេសក្នុងរយៈពេល៥ថ្ងៃចុងក្រោយ ។ ពេលនេះលែងមានបញ្ហាអ្វីទៀតហើយ ។

កងការពារទាំងនោះបញ្ជាឲ្យយើងតម្រង់គ្នាជាជួរដែលក្នុងមួយជួរមាន៤នាក់ ។ ប្អូនៗប្រុសរបស់ខ្ញុំបានតោងខ្ញុំយ៉ាងជាប់ ។ អ្នកទាំងនេះហេវហត់និងអស់កម្លាំងគ្រប់គ្នា ។ ប្អូនៗរបស់ខ្ញុំមិនយំដោយគ្រាន់តែអស់កម្លាំងនោះទេ ។ ទាហានមួយក្រុមតូចដែលឃ្លាំមើលពួកយើងមានគ្រប់វ័យ ខ្លះជាកូនក្មេងដែលមានអាយុត្រឹមតែ១០ឆ្នាំប៉ុណ្ណោះ ។ មានតែទាហាន៥នាក់ក្នុងចំណោមទាហានទាំងនេះប៉ុណ្ណោះដែលត្រូវឃ្លាំមើលក្រុមរបស់ខ្ញុំដែលនៅសេសសល់ ។ នៅពេលនោះពួកយើងមានគ្នាតែ៧៩នាក់ប៉ុណ្ណោះ ។ ក្នុងអំឡុងពេល៥ថ្ងៃដ៏គួរឲ្យព្រឺខ្លាចនៅភ្នំតាសួស មានមនុស្ស៨នាក់បានស្លាប់បាត់បង់ជីវិត ក្នុងនោះមានក្មេង៦នាក់ និងបុរសចំណាស់២នាក់ ។ ខ្ញុំឆ្ងល់ថាហេតុអីបានជាមានទាហានតិចបែបនេះ បើចង់សម្លាប់ពួកយើងដែលមានគ្នាដល់ទៅ៧៩នាក់នោះ? ជានិច្ចកាលខ្ញុំជាមនុស្សដែលចង់ចេះចង់ដឹងម្នាក់សូម្បីតែក្នុងពេលនេះក៏ដូច្នេះដែរ ។

ទាហានចំណាស់ជាងគេម្នាក់ដែលមានឈ្មោះថា កុំ បានមកឈរមុខយើងហើយនិយាយយ៉ាងខ្លាំងៗដើម្បីឲ្យគ្រប់គ្នាបានឮអ្វីដែលគាត់និយាយ ។ គាត់បាននិយាយយ៉ាងសាមញ្ញនិងយ៉ាងច្បាស់ថា «អង្គការលើកំពុងតែបញ្ជូនអ្នកទាំងអស់គ្នាទៅបឹងទន្លេសាបដើម្បីចាប់ត្រី ។ នៅទីនោះនឹងមានចំណីអាហារគ្រប់គ្រាន់សម្រាប់បរិភោគ» ។

រំពេចនោះមនុស្សចាប់ផ្តើមមានព្រលឹងក្នុងខ្លួនវិញហើយចាប់ផ្តើមជជែកគ្នាអំពីពត៌មាននេះ ។ យើងទាំងអស់គ្នាសង្ស័យចំពោះពត៌មានដែលហាក់ដូចជាមិនអាចជឿបាននេះ ។ ទោះបីជាយ៉ាងណាក៏ដោយ បញ្ហានេះអាចសមហេតុផលបើតាមយើងភាគច្រើនដែលធ្លាប់ប្រកបរបរនេសាទនៅបឹងទន្លេសាប ។ ទាហានទាំងនោះបានប្រាប់យើងចំអ្វីដែលយើងចង់ដឹងៈ ចំណីអាហារ ឱកាសចាប់និងបរិភោគត្រីស្រស់ៗនៃបឹងទន្លេសាប ឱកាសរួចផុតពីក្តីទុក្ខវេទនានៅភ្នំតាសួស ។ តែអ្វីដែលនិយាយគឺល្អពេករហូតមិនអាចឲ្យជឿបាន ។ ដំណឹងនេះធ្វើឲ្យខ្ញុំវង្វេងវង្វាន់ពេញទី ។ ប្រហែលជាខ្ញុំមានក្តីកង្វល់បន្តិចបន្តួច ប៉ុន្តែអ្នកនៅក្នុងក្រុមផ្សេងទៀតក៏មានក្តីកង្វល់នេះដែរ ។ យើងត្រូវរង់ចាំមើលថាតើអ្វីនឹងកើតឡើងក្នុងពេលអនាគតចំពោះពួកយើង ។

អ្នកឃ្លាំមើលបាននាំយើងទៅតាមផ្លូវមួយពោរពេញទៅដោយភក់ដែលខ្ញុំធ្លាប់បានឆ្លងកាត់ទៅកាន់បឹងទន្លេសាបដែលស្ថិតនៅប្រហែល១០គីឡូម៉ែត្រពីទីនោះ ។ ពេលចុងក្រោយដែលខ្ញុំ

ដើរកាត់ផ្លូវនេះគឺមួយឆ្នាំមុននេះនៅពេលដែលខ្ញុំស្ថិតនៅក្នុងកងចល័តមួយទៀត ។ យើងបានសម្រាកជាច្រើនលើកក្នុងចម្ងាយផ្លូវដ៏វែងឆ្ងាយនេះ ។ ប្រហែលកងការពារទាំងនោះចង់ប្រាប់យើងអំពីការពិតឬ? យើងហាក់ដូចជាកំពុងធ្វើដំណើរក្នុងទិសដៅមួយដ៏ត្រឹមត្រូវ ។ ពួកនោះមានតែគ្នា៥នាក់ប៉ុណ្ណោះ ។ កងការពារទាំងនោះពុំមានលទ្ធភាពសម្លាប់យើងដែលមានគ្នា៧៩នាក់ទាំងអស់ទេ ពិតទេ?

បន្ទាប់ពីដើរបានប្រហែល៥គីឡូម៉ែត្រ បុរសប្រដាប់អាវុធបានឲ្យយើងឈប់រង់ចាំឲ្យអ្នកដែលនៅក្នុងក្រុមផ្សេងទៀតមកទាន់ ។ គ្រួសាររបស់ខ្ញុំអង្គុយកាន់ដៃគ្នាដោយពុំមាននិយាយអ្វីមួយម៉ាត់ ។ នៅលើផ្ទៃមុខមនុស្សគ្រប់គ្នាពោរពេញដោយក្តីបារម្ភ ។ បងស្រីរបស់ សាអ៊ុម ម្នាក់បានហុចបាយមួយដុំចុងក្រោយឲ្យខ្ញុំ ។ ខ្ញុំបានញាត់បាយមួយដៃចូលមាត់ខ្ញុំ ហើយហុចទៅឲ្យប្អូនប្រុសខ្ញុំដែលកំពុងតែឃ្លានយ៉ាងខ្លាំង ។ គ្រប់ៗគ្នាសុទ្ធតែទន់ដៃទន់ជើងក្រោយពីការធ្វើដំណើរលើដងផ្លូវជិត៥គីឡូម៉ែត្រមក ។ មានក្មេងម្នាក់ស្លាប់នៅតាមផ្លូវ ។ ក្រោយពីមានការស្មុគស្មាញរញ៉េរញ៉ៃមួយសន្ទុះមក ពួកទាហានក៏ឲ្យម្តាយរបស់ក្មេងដែលស្លាប់នោះកប់សាកសពកូនរបស់គាត់ ។

កងការពាររបស់យើងចង់ឲ្យយើងធ្វើដំណើររូតរះមុនពេលថ្ងៃលិច ។ កងការពារបានឲ្យអ្នកដែលធ្វើការបានទាំងចាស់ទាំងក្មេងមកប្រមូលផ្តុំគ្នានៅមុខក្រុមរបស់ខ្លួន ។ ក្រោយមកកងការពារបានប្រាប់ឲ្យយកសម្ភារធ្វើការផ្សេងៗដូចជាកាំបិតពូថៅដែលខ្លួនយកមកតាម ។ កងការពារនិយាយថា អ្នកទាំងនេះគឺជាអ្នកដែលត្រូវនាំមុខគេក្នុងការលើកទំនប់ជំនួសឲ្យយើងទាំងអស់គ្នា ។

បន្ទាប់មក អ្នកដែលត្រូវទទួលការងារទាំងនោះក៏តម្រង់ជួរមួយជួរដោយកាន់នូវឧបករណ៍ធ្វើការងាររៀងៗខ្លួន ។ ខ្ញុំតាមមើលបង សេរី ព្រមទាំងបងប្រុសទាំងពីររបស់ខ្ញុំពេលដែលគាត់ចេញទៅតម្រង់ជួរទាំងចិត្តស្មុគស្មាញ ។ ឪពុកខ្ញុំមានវ័យចំណាស់ណាស់ទៅហើយ ហើយមិនអាចដើរចូលតម្រង់ជួរទាន់គេឡើយ ពេលនោះកម្លាំងទាំងអស់ដ៏ចាកចេញចោលគាត់ ។

កងការពារម្នាក់និយាយអំពីខ្ញុំទៅកាន់សមមិត្តរបស់វាថា «ម្នាក់នេះស្គមពេក ហើយខ្សោយណាស់ មិនអាចចូលរួមជាមួយយើងបានទេ» ។

ពេលនោះបង សេរី ក៏លាប្រពន្ធរបស់ខ្លួនឈ្មោះ សាអ៊ុម ដែលកំពុងមានផ្ទៃពោះផង ។ ខ្ញុំក៏នៅជិតទីនោះដែរពេលនោះ ។ ពេលនោះបង សាអ៊ុម ស្ងាត់មាត់ឈឹង ហើយបន្ទាប់មកទឹកមុខដ៏ក្រៀមក្រំរបស់គាត់ក៏ប្រែជាធម្មតាវិញក្រោយពីខ្ញុំបានអះអាងថា ខ្ញុំនឹងជួយមើលខុសត្រូវចំពោះគាត់ ។

បន្តិចក្រោយមកក្រុមពលកម្មនោះក៏បាត់ស្រមោលឈឹងនៅក្រោមផ្ទៃមេឃដ៏ខ្មៅងងឹតសូន្យឈឹង ។ ពេលនោះគឺជាពេលចុងក្រោយដែលខ្ញុំលែងមានឱកាសបានជួបបងប្រុសព្រមទាំងមនុស្សផ្សេងទៀតជារៀងរហូត ។ មេឃកាន់តែងងឹតនិងត្រជាក់ទៅៗ ។ មូសកំណាចនៅឯបឹងទន្លេសាបចាប់ផ្តើមចេញមកគ្របដណ្តប់រាត្រីកាល ។ ប្រហែល៣០នាទីក្រោយមក កងការពារពីររូបដែលនាំយកក្រុមនោះទៅក៏ត្រឡប់មកវិញ ហើយក៏ប្រមូលសមមិត្តរបស់ខ្លួនប្រជុំដាក់ផែនការ ។ មនុស្សម្នាក់ឬពីរនាក់នៅក្នុងក្រុមរបស់ខ្ញុំបានលួចស្តាប់ព្រឹត្តិមានដែលមិនគួរឲ្យជឿ ។ ពត៌មាននេះក៏បានលេចឮសុសសាយដល់ក្រុមទាំងមូល ។ ក្រោយមកខ្ញុំបានឮពួកវាដូចជានិយាយថា «អា២-៣នាក់នោះបានរួចទៅហើយ» ។ ឃ្លានេះមានន័យថា បុរសទាំងអស់បានស្លាប់លើកលែងតែ២-៣នាក់ប៉ុណ្ណោះ ដែលអាចរត់រួច ។

នៅម៉ោងប្រហែល៧-៨ល្ងាច យើងក៏ត្រូវបានបញ្ជាឲ្យធ្វើដំណើរទៅមុខទៀត ។ ពេលនោះក្មេងៗដែលនៅមានកម្លាំងនៅក្នុងខ្លួននៅឡើយបានស្រែកនិងយំយ៉ាងខ្លាំងបណ្តាលមកពីការអត់ឃ្លាន ការអស់កម្លាំង និងមូសខាំ ។ ទន្ទឹមនឹងសម្រែករបស់ក្មេងៗខ្ញុំក៏បានឮសំឡេងយំខ្សឹកខ្សួលស្តាយស្រណោះនូវមនុស្សដែលខ្លួនស្រឡាញ់ហើយបាត់បង់ទៅ ។ បង សាអ៊ុម និងម្តាយរបស់ខ្ញុំក៏មានការសោកសង្រេងដូចគ្នានេះដែរ ។ ពេលនោះខ្ញុំមានការងឿងឆ្ងល់អំពីសភាពការណ៍ទាំងមូលទោះបីជាមានការលេងល្បិចពីក្រោយខ្នងយើងក៏ដោយ ។ ប្រសិនបើយើងមិនស្លាប់ដោយសារការបង្អត់អាហារ ការអស់កម្លាំង ឬមូសខាំ ក៏ដៃរបស់ទាហានអង្គការថ្នាក់លើសម្លាប់យើងដែរ ។ **(នៅមានត)**

**យិមស៊ុត រ៉ាណាឌិត**

# មិនអាចបំភ្លេចបាន

ថ្ងៃ២០ ឧសភា គឺជាថ្ងៃដែលពុំអាចបំភ្លេចបាន ។សហស្សម័យ ឈានមកដល់ ឯវ័យជាកុមារភាពត្រូវរំកិលទៅមុខដោយឥតប្រណី ប៉ុន្តែស្រមោលអតីតកាលនៅតែមកលងអារម្មណ៍ខ្ញុំឲ្យនឹកឃើញ ជានិច្ចនូវសំណោកដ៏ឈឺចាប់របស់ស្ត្រីខ្មែរ និងកុមារកំព្រាជាច្រើន នាក់នៅលើវេទិកាគុកសង់ក្នុងស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល នាថ្ងៃ ២០ ឧសភា ឆ្នាំ១៩៨៥ ។ រយៈកាល១៥ឆ្នាំ កន្លងទៅពិតមែន ប៉ុន្តែក្តីឈឺចាប់របស់ស្ត្រីមេម៉ាយនិងកុមារកំព្រារាប់ពាន់នាក់ដែល បានរៀបរាប់ទាំងទឹកភ្នែកនៅតែដក់ក្នុងអារម្មណ៍របស់ខ្ញុំជានិច្ច ។ កាលនោះ (១៩៨៥) ខ្ញុំទើបតែអាយុ១៣ឆ្នាំប៉ុណ្ណោះ ប៉ុន្តែខ្ញុំនៅចាំ បានថាជារៀងរាល់ឆ្នាំឲ្យតែដល់ថ្ងៃ ២០ ឧសភា ប្រជាជនទាំងអស់ បានធ្វើពិធីបុណ្យមួយរំឭកដល់វិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ទៅ ដោយអំពើឃោរឃៅរបស់ពួកខ្មែរក្រហម ។

ដោយមានការចូលរួមពីសំណាក់ប្រជាជនគ្រប់ស្រទាប់ វណ្ណៈមានតាំងពីព្រះសង្ឃ ទាហាន សិស្ស និងកុមារកំព្រាជាច្រើន រយនាក់មកពីមណ្ឌលបុរីហុងគ្រី មកជួបជុំគ្នានៅគុកសង់ ។ គុកសង់ ជាគុកមួយក្នុងចំណោមគុកជាច្រើនទៀតស្ថិតនៅក្នុងភូមិភាគនិរតី ។ គុកនេះជាកន្លែងប្រមូលផ្តុំ សម្លាប់ និងកន្លែងធ្វើទារុណកម្មអ្នកទោស របស់ពួកខ្មែរក្រហមដែលត្រូវបានចោទថាក្បត់ ។ ដោយហេតុដូច្នេះ ទើបគណៈកម្មការរៀបចំត្រូវបានយកកន្លែងនេះធ្វើពិធីចងកំហឹង គឺរំឭកឡើងវិញនូវអនុស្សាវរីយ៍ដ៏ឈឺចាប់របស់ប្រជាជនដែលបាន ជួបប្រទះក្នុងរយៈកាល៣ឆ្នាំ ៨ខែ និង២០ថ្ងៃ ។

មុននឹងធ្វើវិយោគកថា គណៈកម្មការបាននិមន្តព្រះសង្ឃ មកសូត្របង្សុកូលនិងមានពិធីរាប់បាត្រដើម្បីបញ្ជូនផលបុណ្យឲ្យទៅ ព្រលឹងអ្នកស្លាប់ឲ្យទៅកាន់សុគតិភព ។ ក្រោយពីពិធីរាប់បាត្រចប់ សព្វគ្រប់តំណាងគណៈកម្មការក៏បានឡើងអានសុន្ទរកថា ស្តីពីការធ្វើ បុណ្យថ្ងៃ២០ ឧសភា ថាជាថ្ងៃប្រវត្តិសាស្ត្រមួយដែលប្រជាជន កម្ពុជាយើងពុំអាចបំភ្លេចបាននូវរបបដ៏សែនឃោរឃៅនេះ ។ ក្នុង រយៈកាលតែជាងបីឆ្នាំ ប៉ុល ពត បានធ្វើឲ្យប្រទេសទាំងមូលក្លាយ ទៅជាឈាមនិងទឹកភ្នែក ។ មហាវិនាសកម្មដ៏សែនព្រៃផ្សៃបាន កើតឡើងពេញផ្ទៃប្រទេស ប្រជាជនត្រូវពួកវាបណ្តេញចេញពីទី ប្រជុំជនទៅនៅក្នុងព្រៃស្មសាន បង្ខំឲ្យធ្វើការជាទម្ងន់គ្មានពេល ឈប់សម្រាក ។ ចំណីអាហារពុំសមនឹងកម្លាំងធ្វើការ ។ យុវជន ក្មេងៗក្លាយទៅជាមនុស្សចាស់ជរាគួរឲ្យអាសូរ ។ គ្រប់ហេដ្ឋារចនា សម្ព័ន្ធទាំងអស់ត្រូវបំផ្លាញ សាលារៀន មន្ទីរពេទ្យ ក្លាយទៅជា កន្លែងគុក ឬទ្រុងជ្រូក ។ ខ្មែរក្រហមបានធ្វើទារុណកម្មលើប្រជាជន កម្ពុជាយ៉ាងវេទនាបំផុតដោយយកដង្កាប់ដកក្រចក រួចជ្រលក់ អាល់កុល ចងព្យួរជ្រលក់ក្នុងពាងទឹក ដុតដែកក្តៅចាក់ចូលទៅក្នុង សាច់ ចងឆ្កាង ពន្លះសាច់ អារ-កនឹងធាងត្នោត កប់ទាំងរស់ ចាក់សម្លាប់នឹងចំពុះទុង បើស្ត្រីវិញត្រូវពួកវារំលោភយ៉ាងព្រៃផ្សៃ បំផុត ។ល ។ ក្រោយពីតំណាងគណៈកម្មាធិការអានសុន្ទរកថាចប់ មានកុមារកំព្រាម្នាក់បានឡើងសូត្រកំណាព្យថ្លែងពីទុក្ខសោកប្រជាជន យើងដែលជួបប្រទះក្នុងរបបនេះ ។ បន្ទាប់មកប្រជាជននិងកុមារ កំព្រាជាច្រើននាក់ បានឡើងរៀបរាប់ឡើងវិញពីទុក្ខវេទនានិងការ និរាសព្រាត់ប្រាសគ្នារវាងបងប្អូននិងឪពុកម្តាយ ។ កាលនោះខ្ញុំនៅ ចាំបានថាមានអ៊ំស្រីចំណាស់រៀបរាប់ទាំងទឹកភ្នែកនូវអំពើឃោរឃៅ របស់ពួកខ្មែរក្រហមមកលើក្រុមគ្រួសាររបស់គាត់ គឺកូនស្រីគាត់ ម្នាក់ត្រូវស្លាប់យ៉ាងវេទនានិងខ្លោចផ្សាបំផុត អ៊ំស្រីឃើញផ្ទាល់នឹង ភ្នែកនូវអំពើឃោរឃៅអមនុស្សធម៌ដែលក្នុងលោកពុំដែលជួប ប្រទះ ។ ទោះបីថា ហ៊ីត្លែរ សាហាវ ប៉ុន្តែហ៊ីត្លែរពុំបានសម្លាប់ប្រជាជាតិ របស់ខ្លួនទេ គឺសម្លាប់តែពួកជនជាតិជ្វីហ្វប៉ុណ្ណោះ ។ ខ្មែរក្រហមបាន សម្លាប់ជាតិឯង ប្រជាជនឯង គ្មានធម៌មេត្តា ។ អ៊ំស្រីបានបន្តថា កូនរបស់អ៊ំត្រូវស្លាប់ដោយការចាប់រំលោភពីសំណាក់ពួកឈ្លបក្នុង ភូមិចំនួន៤នាក់ មុននឹងរំលោភពួកវាបានយកខ្សែទៅចងដៃ ចងជើង ដោយសម្រាតសម្លៀកបំពាក់ចោល ។ ក្រោយពីចាប់រំលោភរួច ពួកវាបានយកចំពុះទង់ទៅចាក់សម្លាប់ចំយោនី ។ គ្មាននរណាម្នាក់ ដែលមិនស្រក់ទឹកភ្នែកទេក្នុងចំណោមមនុស្សរាប់ពាន់នាក់ទៅ អង្គុយស្តាប់មិទ្ទិង សូម្បីតែព្រះសង្ឃក៏ក្តុកក្តួលក្នុងចិត្តដែរ ។ ខ្ញុំសែន សង្វេគក្នុងចិត្តពេកក្រៃនៅពេលឃើញកុមារកំព្រាជាច្រើនបានឡើង សាស័ព្ទទុក្ខសោករបស់ខ្លួន ពីការនិរាសព្រាត់ប្រាសឪពុកម្តាយ ពួក ខ្មែរក្រហមបង្ខំឲ្យទៅរស់នៅឆ្ងាយដាច់ស្រយាល បង្ខំឲ្យធ្វើការជាទម្ងន់ ឯម្ហូបអាហារពុំបានផ្តល់ឲ្យហូបគ្រប់គ្រាន់ ។ ក្រោយពីឡើងសាស័ព្ទ ទុក្ខសោករបស់ប្រជាជននិងកុមារកំព្រាចប់ គណៈកម្មការបានយក រូបទីងមោង ប៉ុល ពត អៀង សារី ខៀវ សំផន ដុតជានិមិត្តរូប នៃការរលំរលាយរបបនេះ ។ ស្របជាមួយសម្រែកជយឃោសរបស់ ប្រជាជន «ជយោ! បក្សប្រជាជនកម្ពុជាដ៏រុងរឿង» ។ ក្រោយពី ចប់ពិធី អង្គមិទ្ទិងត្រូវបានរំសាយ ប្រជាជនទាំងអស់បានវិលទៅ

លំនៅឋានរៀងៗខ្លួនដោយពាំនាំយកទុក្ខសោកនិងពុំអាចបំភ្លេចបាននូវអំពើឃោរឃៅអមនុស្សធម៌របស់ពួកប៉ុលពតមកលើប្រជាជនខ្មែរអស់ជាច្រើនម៉ឺននាក់ ។

រឿងអតីតកន្លងផុតអស់រយៈពេល២៥ឆ្នាំទៅមែន ប៉ុន្តែសេចក្តីសោកសង្រេងនិងក្តីឈឺចាប់នៅតែដក់ជាប់ក្នុងក្រអៅបេះដូងខ្មែរគ្រប់រូបឲ្យនឹកឃើញជានិច្ចនូវរបបព្រៃផ្សៃមួយដែលកើតឡើងដោយស្នាដៃមេដឹកនាំខ្មែរតែប៉ុន្មានរូបធ្វើឲ្យខ្មែរទូទាំងប្រទេសវេទនាដោយសារខ្លួន ។ យើងម្នាក់ៗពុំនឹកស្មានថាមានរបបដែលគ្រប់គ្រងដោយសត្តិវិច្ឆានបែបនេះកើតឡើងសោះ ។ គិតទៅរឿងរ៉ាវក្នុងលោកពិតជាពិបាកស្មានមែន រឿងអ្វីៗកើតឡើងដោយឥតព្រៀងទុក ។ យើងមិននឹកស្មានថាមានឈ្មោះ ប៉ុល ពត ដែលល្បីល្បាញខាងបំផ្លាញនិងកាប់សម្លាប់ចារទុកជាប្រវត្តិសាស្ត្រដល់ពិភពលោកយ៉ាងដូច្នេះទេ ។ ទោះបីបច្ចុប្បន្នរឿងរ៉ាវទាំងឡាយបានកន្លងផុតទៅក៏ដោយ ប៉ុន្តែថ្ងៃណាក៏ពុំតែសំឡេងរហឹមផុសចេញពីសតិសម្បជញ្ញៈដែលលាន់រងំក្នុងអារម្មណ៍ ហើយតែងតែជជីកសួរថា «ហេតុអ្វីបានជាខ្មែរធ្វើដូច្នេះ ខ្មែរក្រហមអីក៏ឃោរឃៅម្ល៉េះ?» ។ ប្រជាជនម្នាក់ៗត្រូវទទួលរងរបួសផ្លូវចិត្ត រងទុក្ខខ្លោចផ្សាដោយសារតែមេដឹកនាំខ្មែរមួយក្តាប់តូចធ្វើឲ្យមនុស្សរាប់សែននាក់ស្លាប់យ៉ាងសែនវេទនា ។ ជីវិតជាយុវវ័យត្រូវងងឹតសូន្យសុងគ្មានពន្លឺ ថ្ងៃណាក៏ស្គាល់តែទុក្ខ ។ ដួងព្រលឹងនៃកុមារកំព្រារាប់សែននាក់បានស្រែកដង្ហោយហៅរកទីជម្រកកក់ក្តៅ ។ បុព្វហេតុទាំងនេះបានបណ្តាលឲ្យភាពស្រទន់របស់ខ្មែរប្រែក្លាយទៅជាភាពឃោរឃៅអមនុស្សធម៌រហូតដល់សព្វថ្ងៃ ។ អនុស្សាវរីយ៍ក្នុងអតីតកាលត្រូវកប់បាត់សូន្យសុងក្នុងរវាលពិឃាតបីឆ្នាំប្រាំបីខែ ម្ភៃថ្ងៃ ។ វីរជនដ៏ពិសិដ្ឋជាច្រើនត្រូវស្លាប់យ៉ាងអណោចអធ័ម ខ្ញុំគ្មានពាក្យឯណាមករៀបរាប់ឲ្យអស់ពីទំហំទុក្ខរបស់ប្រជាជនខ្មែរគ្រប់រូបដែលត្រូវរងគ្រោះសែនវេទនាបានទេ ។ **រ៉អែម សុខឃីម**

កណ្តៀង,ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០០

សូមគោរពជូនមកឯកឧត្តម ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

ខ្ញុំបាទ សៅ ដារឿន អភិបាលស្រុកកណ្តៀង ខេត្តពោធិសាត់ បានទទួលនូវទស្សនាវដ្តី «ស្វែងរកការពិត» ទី១,២,៣,៤,៥ ជាបន្តគ្នារបស់មជ្ឈមណ្ឌលឯកសារកម្ពុជារួចមកហើយ ។ ខ្ញុំសូមសម្តែងនូវអំណរគុណជាពន្លឹកចំពោះឯកឧត្តមដែលជានាយកមជ្ឈមណ្ឌលហើយដែលយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការផ្ញើសៀវភៅដ៏ល្អយ៉ាងនេះមកអាជ្ញាធរដែនដីឃុំស្រុកយើងខ្ញុំ ។ ខ្ញុំបាទបានឆ្លៀតពេលអានហើយមានការស្ញប់ស្ញែងចាប់អារម្មណ៍យ៉ាងខ្ពស់ចំពោះខ្លឹមសារអត្ថបទទាំងអស់ដែលចុះក្នុងទស្សនាវដ្តី «ស្វែងរកការពិត» នេះដោយយល់ឃើញដូចតទៅ÷

១) សៀវភៅនេះពិតជាមានប្រយោជន៍ឆ្លុះបញ្ចាំងការពិតហើយបានអង្រួនចិត្តអ្នកអានឲ្យញាប់ញ័រផងរំភើបចិត្តផងនិងស្ម័គ្រចិត្តគាំទ្រផង÷

- ញាប់ញ័រដោយរំឭកដល់រឿងជាក់ស្តែងដ៏ស្អុតរន្ធត់មិននឹកស្មានដល់នូវសោកនាដកម្មបង្កឡើងដោយរបបប្រល័យពូជសាសន៍បីឆ្នាំប្រាំបីខែម្ភៃថ្ងៃ ។

- រំភើបៗក្នុងចិត្តព្រោះស្រាប់តែបានឆ្លងគ្រោះថ្នាក់ផុតនាឆ្នាំ១៩៧៩ទាំងក្តីបារម្ភបំផុត ។ រំភើបចិត្តដោយបានមជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានឯកឧត្តមជាអ្នកដឹកនាំបានបង្កើតសៀវភៅឯកសារដ៏ត្រឹមត្រូវយ៉ាងនេះឡើងដែលជាឯកសារពិតប្រាកដមិនអាចបន្លំបានអំពីព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រដ៏ជូរចត់ពិតៗរបស់ប្រជាជាតិខ្មែរ (១៩៧៥-៧៩) ដែលជាភ័ស្តុតាងនាពេលបច្ចុប្បន្ននិងទៅអនាគតក្នុងការបំភ្លឺជូនមតិជាតិនិងសកលលោក ។

- ស្ម័គ្រចិត្តគាំទ្រដោយសៀវភៅនេះអាចផ្សព្វផ្សាយបានទូលាយឆ្ងាយ ហើយការពិតនឹងត្រូវជ្រួតជ្រាបដល់ស្រុករក្រោយ ។ ហេតុនេះសូមឲ្យសៀវភៅនេះចុះឲ្យដល់មូលដ្ឋាន ។

២) សៀវភៅ «ស្វែងរកការពិត» នេះមានតម្លៃមានប្រយោជន៍ឥតអ្វីប្រៀបប្រដូចបាន ។ មានតម្លៃគ្រង់ថាមិនជារឿងប្រឌិតនិងបានផ្តល់នូវមេរៀនពិសោធន៍ដែលកើតពីអំពើអាក្រក់សម្លាប់ជាតិឯងរបស់មាគ៌ាដឹកនាំប្រល័យពូជសាសន៍របស់ក្រុម ប៉ុល ពត ។ កូនខ្មែរជំនាន់នេះជំនាន់ក្រោយត្រូវប្រមែប្រមូលព្រលឹងឧត្តមគតិខ្មែរដើម្បីឯកភាពជាតិ កុំឲ្យសង្គមធ្លាក់ដល់រណ្តៅមរណៈម្តងទៀតឲ្យសោះ ។ ខ្ញុំសូមកោតសសើរដោយស្មោះអស់ពីដួងចិត្តចំពោះឯកឧត្តមនិងសហការីដែលមានជំហរឥតល្អៀង ស្វែងរកការពិតជូនប្រជាជាតិដ៏ល្អនិងកម្សត់របស់យើង ។ ខ្ញុំមានកំណាព្យរំឭកប្រវត្តិខ្លោចផ្សាដើម្បីចំណងដៃចំពោះមជ្ឈមណ្ឌលឯកសារកម្ពុជា ។ សូមឯកឧត្តមទទួលដោយការគោរពពីខ្ញុំ ។ **សៅ ដារឿន**

**កំណាព្យខ្មែរក្រហម**

# ទិដ្ឋភាពថ្មីនៃជនបទកម្ពុជានារដូវវស្សា

ផ្គរលាន់គ្រឹមៗ គ្រហឹមជាប់ ភ្លៀងធ្លាក់ញឹកញាប់ជោគជាំដី ស្រោចលើដំណាំលូតលាស់ខ្ចី ទាំងចាស់ទាំងថ្មីល្អក្រៃលែង ។

ទេសភាពជនបទប្រែប្រួលថ្មី បំព្រងប្រិមប្រិយល្អចែងចាំង វាលស្រែមានភ្លឺមាំខ្វាត់ខ្វែង ប្រឡាយត្រង់វែងទឹកហូរខ្លាយ ។

ទំនប់អាងធំទប់ខ្ពស់មាំ មានទឹកគគ្រាំរលោមសាយ មានទ្វារបិទបើកចូលប្រឡាយ យកទឹកចែកចាយទៅស្រោចស្រែ ។

ស្រែជីកត្រង់វែងច្រើនសិបគីឡូ ក៏មានទឹកហូរជាប់ខ្លាំងដែរ ក្បាលដាប់ដងស៊ីងហូរបង្វែរ បម្រើស្រែរាប់ពាន់ហិកតា ។

កសិករយើងទូទាំងប្រទេស ស្មារតីវៃឈ្លាសចាត់ចែងការ វាយសម្រុកធ្វើស្រែវស្សា តាមទិសអង្គការដ៏ត្រឹមត្រូវ ។

បងប្អូនសប្បាយរីករាយណាស់ ប្រុសស្រីក្មេងចាស់ប្រយុទ្ធក្តៅ ភ្ជួររាស់ដកស្ទូងជាទូទៅ ពីដើមរដូវបានខ្លាំងក្រៃ ។

ក្នុងថ្នាលសំណាបពណ៌បៃតង លូតលាស់បំព្រងមានវែងខ្ចី បងប្អូនកំពុងតែញាប់ដៃ ឃ្មាតខ្មីដកបានកណ្ដាប់ហែ ។

ដឹកតាមរទេះទូកសែងរែក យកទៅចាយចែកបន្ទាន់ដែរ ផ្ដល់ទៅក្រុមស្ទូងជាប់ហូរហែ ពាសពេញផ្ទៃស្រែច្រើនកន្លង ។

បងប្អូនខាងស្ទូងលឿនរហ័ស រៀបឆ្លាស់ត្រណោតរត់ជួរត្រង់ ញាប់ដៃស្មើគ្នាគ្មានបង្អង់ ផ្ចិតផ្ចង់វាយសម្រុកយ៉ាងសកម្ម ។

ដំណាំដាំដុះច្រើនហិកតា ខ្លះផ្លែខ្លះផ្កាជាប់ប្រចាំ បងប្អូនខិតខំមើលថែទាំ និងពង្រីកដាំពេញចម្ការ ។

ជុំវិញផ្ទះមិនទំនេរដី ដំណាំដាំថ្មីពេញក្នុងច្បារ ដំណាំហូបផ្លែបន្លែបង្ការ ទីណាក៏ដុះលូតលាស់ល្អ ។

នៅក្នុងរោងសិប្បកម្មគ្រប់ផ្នែក ទាំងឈើទាំងដែកក៏ឈូឆរ បងប្អូនប្រយុទ្ធធ្វើឧបករណ៍ របស់របរសន្ទឹកសន្ទាប់ ។

បងប្អូនប្រយុទ្ធធ្វើការងារ គ្រប់ពេលវេលាប្រញឹកជាប់ សម្រុកការងារដូចកងទ័ព សន្ទាប់វាយខ្លាំងពេលសង្គ្រាម ។

គ្រប់ភូមិស្រុកតំបន់ភាគ បងប្អូនម្នាក់ៗមិននៅស្ងៀម ធ្វើការដោយមានះព្យាយាម និងត្រៀមម្ចាស់ការទាំងសព្វមុខ ។

ទិដ្ឋភាពនៅរដូវវស្សា ចលនាធ្វើស្រែក្ដៅគគុក ឯករាជ្យម្ចាស់ការពេញបន្ទុក សព្វមុខការងារកសាងជាតិ ។

កែប្រែកម្ពុជាជាទីស្នេហា ឲ្យរឹតស្រស់ថ្លាល្អថែមទៀត នៅទូទាំងផ្ទៃប្រទេសជាតិ កសាងបានស្អាតលឿនលោតផ្លោះ ។


**កត់ត្រាចងក្រងជាឯកសារ**

**កញ្ញា សើ សាយ្យាណា**



***ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុក និងឃុំ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ទស្សនាវដ្តីចំនួន១០០០ក្បាលជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល***

*មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!*

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.



A magazine of the Documentation Center of Cambodia: Searching for the Truth! Number 8, August 2000

Funded by the Royal Ministry of Foreign Affairs, Oslo, Norway, Section for the Human Rights and Humanitarian Assistance; and the Canada Funds, Canadian Embassy, Phnom Penh, Cambodia